# សម្ភាសន៍ជាមួយ យិន អាត ភេទប្រុស អាយុ៦៦ឆ្នាំ

## មុខងាររសម័យខ្មែរក្រហមៈ“ប្រធានសាលាបង្រៀនបច្ចេកទេសកសិកម្មមជ្ឈិម”

## មានស្រុកកំណើត នៅភូមិឈូកខ្សាច់ ឃុំឈូកខ្សាច់ ស្រុកបាភ្នំ ខេត្តកំពង់ធំ

## សព្វថ្ងៃរស់នៅភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី

## ០២:៣០:២២

## ៨៣ ទំព័រ

បូលីៈ ជាដំបូងខ្ញុំសុំស្គាល់ឈ្មោះអ៊ំ?

អាតៈ ខ្ញុំឈ្មោះ យិន អាត សមាជិកក្រុមប្រឹក្សាស្រុក ។

បូលីៈ បាទ! អ៊ំធ្វើជាសមាជិកហ្នឹងតាំងពីឆ្នាំណាមកអ៊ំ?

អាតៈ គិតទៅវា ៣ឆ្នាំហើយ ។

បូលីៈ សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយអ៊ំ?

អាតៈ ខ្ញុំ ៦៦ឆ្នាំ ។

បូលីៈ អ៊ំកើតឆ្នាំប៉ុន្មានដែរ?

អាតៈ ១៩៤០ ។

បូលីៈ បាទ! អ៊ំមានស្រុកកំណើតនៅណាដែរ?

អាតៈ ស្រុកកំណើតខ្ញុំនៅខាងកំពង់ធំ ។

បូលីៈ ស្រុកអីគេអ៊ំ?

អាតៈ បាទ! ស្រុកបាភ្នំ ឃុំឈូកខ្សាច់ ។

បូលីៈ ភូមិ?

អាតៈ ភូមិឈូកខ្សាច់ ឃុំឈូកខ្សាច់ ស្រុកបាភ្នំ ខេត្តកំពង់ធំ ។

បូលីៈ អ៊ំមានគ្រួសារឈ្មោះអីដែលអ៊ំ?

អាតៈ គ្រួសារឈ្មោះ ឃីម ឃីម ។

បូលីៈ សព្វថ្ងៃគាត់នៅជាមួយអ៊ំទេ?

អាតៈ បាទ! នៅ ។

បូលីៈ បានកូនប៉ុន្មានដែរអ៊ំ?

អាតៈ កូន៣នាក់ ។

បូលីៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

អាតៈ ប្រុស១នាក់ ស្រី២នាក់ ។

បូលីៈ សព្វថ្ងៃនៅក្នុងបន្ទុកអ៊ំទាំងអស់ ឬក៏ការចេញខ្លះហើយអ៊ំ?

អាតៈ ការចេញបានពីរនាក់ហើយ ស្រីៗ នៅប្រុស១នាក់ នៅរៀនសព្វថ្ងៃថ្នាក់ទី១២ ។

បូលីៈ នៅរៀនវិទ្យាល័យយើងត្រពាំងប្រាសាទនេះអ៊ំ?

អាតៈ បាទៗ!

បូលីៈ អ៊ំមានបងប្អូនទាំងអស់ប៉ុន្មាននាក់?

អាតៈ បងប្អូនខ្ញុំ៥នាក់ ។

បូលីៈ ៥នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

អាតៈ ស្រី២នាក់ ប្រុស ៣នាក់ ។

បូលីៈ គាត់នៅរស់ទាំងអស់គ្នា?

អាតៈ ស្លាប់អស់៣នាក់ ។

បូលីៈ ស្លាប់អស់៣នាក់ នៅសល់២នាក់អញ្ចឹង?

អាតៈ បាទ! នៅសល់ខ្ញុំម្នាក់ ហើយប្អូនស្រីម្នាក់ ។

បូលីៈ ស្រីហ្នឹងគាត់នៅណាអ៊ំ?

អាតៈ គាត់នៅស្រុកកំណើត ។

បូលីៈ កំពង់ធំ?

អាតៈ នៅស្រុកបារាយ ខេត្តកំពង់ធំ ។

បូលីៈ អ៊ំដែលបងប្អូនស្លាប់៣នាក់ហ្នឹង គាត់ស្លាប់នៅសម័យណាដែរអ៊ំ?

អាតៈ គាត់ស្លាប់នៅសម័យរដ្ឋកម្ពុជា គាត់ធ្វើចៅហ្វាយស្រុករដ្ឋកម្ពុជា ដោយគាត់មានជម្ងឺ ពេលនោះ គាត់មកធ្វើចៅហ្វាយស្រុកនៅខាងកំពង់ធំនេះ ខាងប្រាសាទសំបូរនេះ ដល់អញ្ចឹងទៅគាត់ឈឺៗ ទៅក៏ព្យាបាលមិនជា រហូតស្លាប់ទៅ ។ ហើយបងមួយទៀតស្រីនោះគាត់មានរោគប្រចាំកាយ គាត់ព្យាបាលមិនជា ជំនាន់នោះយើងខ្វះខាត ជំនាន់យើងពី៧១-៧២-៧៣-៧៤ គឺយើង កំពុងតែច្របូកច្របល់ប្រទេសជាតិយើង អញ្ចឹងយើងគ្មានការព្យាបាលគាត់ គ្មានថ្នាំសង្កូវអី ក្នុងរយៈកាលហ្នឹងគឺពិបាកណាស់ ពិបាកសភាពការណ៍ប្រទេសយើងហែកហួរដោយសង្គ្រាម មិនមានការព្យាបាលបានម៉ត់ចត់ គាត់ក៏ស្លាប់ទៅ ។ បាទ! បងមួយទៀតនោះ បងទី៣ ដែល

ស្លាប់ក្រោយគេនេះគាត់គឺថា អាការៈឲ្យគាត់ឡើងឈាម គាត់ធ្វើជាមេឃុំឈូកខ្សាច់ហ្នឹង ដល់គាត់ឡើងឈាមអញ្ចឹងទៅគាត់ស្លាប់ទៅ ។

បូលីៈ លើសឈាម?

អាតៈ បាទ! អញ្ចឹងបងប្អូនខ្ញុំសុទ្ធតែបម្រើរដ្ឋឲ្យកម្ពុជាទាំងអស់ ។

បូលីៈ ប៉ុន្មាននាក់ដែលចូលបដិវត្តន៍អ៊ំ?

អាតៈ តែខ្ញុំម្នាក់ឯង ។

បូលីៈ តែអ៊ំម្នាក់ទេ?

អាតៈ បាទ!

បូលីៈ ខ្ញុំសួរគាត់ទៅហ្នឹងតែម្ដងទៅ អ៊ំចូលបដិវត្តន៍ឆ្នាំណាដែរ?

អាតៈ ឆ្នាំ១៩៧២ ។

បូលីៈ ចូលនៅកន្លែងណាអ៊ំ?

អាតៈ ចូលនៅឃុំបារាយហ្នឹង ។

បូលីៈ ហេតុអីបានជាអ៊ំចូលពេលហ្នឹង?

អាតៈ ជំនាន់កាលនោះ ប្រាប់ប្អូនឯងតាមត្រង់ទៅគឺថា ទស្សនៈពេលនោះអាចថាមានទស្សនៈ ខ្ញុំនៅរៀនផង ប្រសិនបើឈប់រៀនទៅខ្ញុំមានទស្សនៈថាស្រលាញ់សម្ដេចឪយើង សម្ដេចតាទួតយើង ។ អញ្ចឹងគេធ្វើរដ្ឋប្រហារទម្លាក់សម្ដេចតាទួតអញ្ចឹងទៅ ក៏មានទស្សនៈគាត់អំពាវនាវឲ្យចូលព្រៃក៏មានការតស៊ូដើម្បីរបទេសយើងវាមានសុខសន្តិភាពមកវិញដូចជំនាន់គាត់អញ្ចឹង មិននឹកស្មានថា បច្ចុប្បន្នវាទៅជាអញ្ចឹងវាហួសចិត្តលែងនិយាយកើត ។

បូលីៈ អ៊ំរៀនបានថ្នាក់ទីប៉ុន្មាន មុនពេលអ៊ំចូលធ្វើបដិវត្តន៍?

អាតៈ ថ្នាក់ទី៨ ។

បូលីៈ ទី៨ ចាស់?

អាតៈ បាទ! ទី៨ ចាស់ ។

បូលីៈ ទី៨ ចាស់ ស្មើនឹងទី៥ គេឥឡូវ ។ ចុះរហូតមកដល់បច្ចុប្បន្នអ៊ំនៅតែស្រឡាញ់សម្ដេចឪទៀតឬ យ៉ាងម៉េច?

អាតៈ ទស្សនៈខ្ញុំនៅតែពេញចិត្តនឹងគាត់ដែរ ព្រោះជំនាន់ហ្នឹងគាត់ធ្វើឲ្យប្រទេសកម្ពុជាយើងមានភាពរុងរឿង ប្រជាជនពេលនោះគឺសំបូរសប្បាយ ដោយសារការគ្រប់គ្រងដឹកនាំរបស់គាត់ ។

បូលីៈ បាទ! អ៊ីមានការសោកស្តាយ ចំពោះរឿងដែលព្រះអង្គអំពាវនាវឲ្យចូលព្រៃ អ៊ីមានការខឹង សម្បាររឿងហ្នឹងទេ ឬក៏មិនខឹងទេ?

អាតៈ អត់ខឹងទេ! បាទ! ពេញចិត្តពេញថ្លើមនឹងចូលតាមការអំពាវនាវរបស់គាត់ របស់សម្តេច ។

បូលីៈ អញ្ចឹងកាលដែលអ៊ីចូលហ្នឹងគឺចូលដោយស្ម័គ្រចិត្ត?

អាតៈ បាទ! ចូលដោយស្ម័គ្រចិត្ត ។

បូលីៈ មានគេមកឃោសនា ឬក៏មកណែនាំពន្យល់ ឬក៏មកបង្ខិតបង្ខំ?

អាតៈ អត់ទេ! កាលនោះគឺខ្ញុំមានវិទ្យុហើយបើកវិទ្យុ កាលហ្នឹងគាត់ចាក់សម្លេងមកតាមវិទ្យុអំពាវនាវ ទៅ ។

បូលីៈ វិទ្យុអីគេអ៊ី?

អាតៈ វិទ្យុយើងធម្មតាយើងហ្នឹង អាវិទ្យុបើកសម្លេងហ្នឹង ។

បូលីៈ ចុះប៉ុស្តិ៍អី ប៉ុស្តិ៍អាមេរិចកាំង ឬក៏ប៉ុស្តិ៍អី?

អាតៈ បាទ! ប៉ុស្តិ៍កាលហ្នឹងគឺប៉ុស្តិ៍ប៉េកាំង ។

បូលីៈ វិទ្យុប៉ុស្តិ៍ប៉េកាំង?

អាតៈ បាទ!

បូលីៈ អ៊ូ! លេខប៉ុន្មានអ៊ីមានចាំទេ?

អាតៈ អត់មានចាំទេ ។

បូលីៈ ១០៧.៥ អីអញ្ចឹង?

អាតៈ បាទ! អត់ចាំទេៗ ។

បូលីៈ អត់ចាំទេ ។ ដែលអ៊ីបើកស្តាប់ហ្នឹងគឺបើកស្តាំនៅពេលណា ម៉ោងបាយពេលល្ងាច ឬក៏ពេល ណា?

អាតៈ បាទ! វាច្រើនតែម៉ោង៨ហ្នឹង ។

បូលីៈ ៨ យប់?

អាតៈ បាទ!

បូលីៈ វិទ្យុហ្នឹងគេផ្សាយជាភាសាខ្មែរ ឬជាភាសាចិន?

អាតៈ ផ្សាយភាសាខ្មែរ ។

បូលីៈ រយៈពេលប៉ុន្មានម៉ោងផ្សាយ ។

អាតៈ រយៈពេល កាលហ្នឹងដូចជាពេល១ម៉ោង ។

បូលីៈ ឧទាហរណ៍ថា វិទ្យុវីអូអេ គេផ្សាយជាភាសាខ្មែរមួយថ្ងៃ ១ម៉ោង ពេលយប់ ពេលព្រឹកកន្លះម៉ោងអញ្ចឹងអ៊ំ!

អាតៈ បាទៗ!

បូលីៈ ចុះវិទ្យុក្រុងប៉េកាំងផ្សាយជាភាសាមួយថ្ងៃប៉ុន្មាន?

អាតៈ មួយម៉ោង ។

បូលីៈ មួយម៉ោងដែរ?

អាតៈ បាទ!

បូលីៈ កាលហ្នឹងសម្តេចអំពាវនាវហ្នឹងសម្តេចព្រះអង្គផ្ទាល់ឬសម្តេច?

អាតៈ បាទ! សម្តេចព្រះអង្គផ្ទាល់ ។

បូលីៈ ព្រះអង្គតែម្តង?

អាតៈ បាទ! ព្រះអង្គតែម្តង គេចាក់យកកាសែតហ្នឹងមកចាក់ ។

បូលីៈ បាទ! រយៈពេលដែលព្រះអង្គស្រែកពេលហ្នឹង ប្រហែលជាប៉ុន្មាននាទី?

អាតៈ អ៊ើ! យូរដែរប្អូន ។

បូលីៈ ដល់មួយម៉ោងពេញ ឬយ៉ាងម៉េច?

អាតៈ អ៊ើ! មិនដល់មួយម៉ោងពេញទេ ។ តែជិតជាងកន្លះម៉ោង ។

បូលីៈ ជាងកន្លះម៉ោង?

អាតៈ បាទ! ជិតមួយម៉ោងតាមមើល៍!យូរដែរ ។

បូលីៈ បាទ! លោកនិយាយអីខ្លះអ៊ំ?

អាតៈ អ៊ើ! មិនចាំទេ គ្រាន់តែចំណុចដែលសំខាន់គឺថា ការដែលធ្វើរដ្ឋប្រហាររបស់ លន់ ណុល កន្លងទៅហ្នឹងគឺដូចថា គាត់និយាយថាដូចយកជាតិទៅឲ្យស្លាប់អញ្ចឹង គាត់អំពាវនាវឲ្យកូនចៅហ្នឹងខំធ្វើការតស៊ូដោយចូលទៅព្រៃម៉ាកគីដើម្បីតស៊ូរំដោះប្រទេសរបស់យើង មិនមែនធ្វើដើម្បីធ្វើកុម្មុយនីស្តអត់ទេ ។

បូលីៈ អត់មាននិយាយរឿងប៉ះពាល់កុម្មុយនីស្តសោះតែម្តង?

អាតៈ បាទ! អត់និយាយប៉ះពាល់សោះ ។

បូលីៈ និយាយតែមួយគឺរំដោះប្រទេសជាតិ?

អាតៈ បាទ! គឺរំដោះប្រទេសជាតិ រំដោះប្រជាជនរបស់យើងពីរបបប៉ុល ពត ពីរបបអាមេរិច ។

បូលីៈ អត់ទាន់ប៉ុល ពត ទេអ៊ំកាលហ្នឹង ក្រែងរបប លន់ នល់?

អាតៈ បាទ! អត់ទាន់ប៉ុល ពត ទេ របប លន់ នល់ ប្រលំ ។

បូលីៈ លន់ នល់ និងអាមេរិចកាំង?

អាតៈ បាទ! លន់ នល់ និងអាមេរិចកាំង ។

បូលីៈ អ៊ំអាចចាំចំណុចអីសំខាន់ផ្សេងក្រៅពីចំណុចហ្នឹងទេអ៊ំ អាចនឹកបន្តិចក្រែងលោចាំ ខ្លឹមសាររបស់ព្រះអង្គដែលមានបន្ទូលពេលហ្នឹង?

អាតៈ ខ្លឹមសារដែលខ្ញុំដកជាប់អារម្មណ៍នោះគឺ ចាំបានដូចនិយាយខាងដើមមិញអញ្ចឹង ចាំបានតែគាត់អំពាវនាវអញ្ចឹង គឺឲ្យកូនចៅទាំងអស់ហ្នឹង គឺទាំងប្រុសទាំងស្រីហ្នឹង ពិសេសគឺយុវជនយុវនារី ។

បូលីៈ អ៊ូ! យុវជន និងយុវនារី?

អាតៈ យុវនារី ហើយនឹងបញ្ញាជនគ្រូបង្រៀនអីហ្នឹង ។

បូលីៈ អ៊ូ! បញ្ញាជនគ្រូបង្រៀនដែរ?

អាតៈ បាទ! ឲធ្វើការតស៊ូដោយចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូ ។

បូលីៈ លោកមានប្រាប់ថា ចូលទៅហ្នឹងចូលទៅជាមួយពីណាទេ?

អាតៈ អត់ទេ! អត់មានចូលទៅណាទេ ។

បូលីៈ អត់ទាន់ដឹងទេ?

អាតៈ បាទ! ចូលទៅនឹងគឺថា ទស្សនៈខ្ញុំយល់ខ្លួនខ្ញុំៗយល់ថា សម្តេចឪហ្នឹងជាអ្នកគ្រប់គ្រងហ្នុង ។

បូលីៈ អត់ដឹងថា ប៉ុល ពត ទេអញ្ចឹង?

អាតៈ អត់ដឹង ប៉ុល ពត ទេ ។ ដឹងថាសម្តេចឪហ្នឹងលោកអ្នកគ្រប់គ្រងដឹកនាំចលនាហ្នឹង ។

បូលីៈ បាទ! លោកមានបានមានបន្ទូលពីរឿង លន់ ណុល ក្បត់ចេះក្បត់ចុះពីរឿងមួយពីរទេកាលហ្នឹង?

អាតៈ ទេ! ខ្ញុំចាំបានប៉ុនតែក្នុងហ្នឹងនិយាយ ។

បូលីៈ មាននិយាយដែរ?

អាតៈ បាទ! មាននិយាយ ធ្វើរដ្ឋប្រហារដោយសារអាមេរិច ដោយសារអីៗអញ្ចឹង អាមេរិចអីញុះញង់ឲ្យ លន់ នល់ ធ្វើរដ្ឋប្រហារហ្នឹងគឺមាននិយាយជំនាន់ហ្នឹង រហូតដល់មានការអំពាវនាវឲ្យបងប្អូនធ្វើការតស៊ូចូលម៉ាកគីហ្នឹងឯង ។

បូលីៈ បាទ! ពេលដែលលោកអំពាវនាវឲ្យចូលព្រៃម៉ាកគី អ៊ំក៏ចូល?

អាតៈ បាទ!

បូលី៖   ប៉ុន្តែសួរថា ចូលទៅខាងណា អ៊ីដឹងទៅខាងណាទេ?

អាត៖   ខ្ញុំអត់ដឹងថាចូលទៅខាងណាទេ ប៉ុនទស្សនៈខ្ញុំតែចូលដើម្បីរំដោះប្រទេស និងប្រជាជន ហើយបានសុខសប្បាយវិញគឺសម្តេចគ្រប់គ្រងប្រទេស តែប៉ុនហ្នឹងឯង សម្រាប់ទស្សនៈខ្ញុំ ។

បូលី៖   ប៉ុនអ៊ីដឹងថា តើព្រៃម៉ាកគឺហ្នឹងនៅកន្លែងណាទេ នៅម្តុំណាទេ?

អាត៖   ពេលនោះខ្ញុំមិនដឹងទេ តែឃើញគេទៅ ចេះតែគ្នាទៅៗស្រាប់ទៅជួបអ្នកគេដូចថាគេទទួលយើងដូចខ្ញុំកងទ័ពគេមកទទួលខ្ញុំទៅចូលក្នុងអង្គភាពកងទ័ពអញ្ចឹងយើអណ៉ា ។

បូលី៖   អ៊ូ! ពេលដែលចេញទៅហ្នឹងចេញទៅប៉ុន្មាននាក់?

អាត៖   ពេលខ្ញុំចេញទៅៗពីរនាក់ទេ ។

បូលី៖   តែពីរនាក់ទេ?

អាត៖   បាទ! បន្តមកទៀតគេចេញទៅច្រើនទៀត ប៉ុនជំនាន់ខ្ញុំតែពីរទេ ។

បូលី៖   ជំនាន់អ៊ីពីរនាក់ ពីណាម្នាក់ទៀតអ៊ី?

អាត៖   ម្នាក់ទៀតហ្នឹងស្លាប់បាត់ហើយ ។

បូលី៖   គាត់ត្រូវជាអ៊ីនឹងអ៊ី?

អាត៖   គាត់ត្រូវជាជីដូនមួយនឹងខ្ញុំ ។

បូលី៖   ទៅជាមួយជីដូនមួយអញ្ចឹង?

អាត៖   បាទ! ជិដូនមួយ ។

បូលី៖   ដែលអ៊ីចូលទៅដល់ដំបូងចូលទៅកងខាងណាវិញ?

អាត៖   ខ្ញុំចូលទៅដំបូងហ្នឹង ខ្ញុំចូលទៅឃុំ ចូលទៅឃុំគេទទួលយក ។

បូលី៖   មេឃុំតែម្តង?

អាត៖   បាទ! មេជំនាន់កាលនោះគេហៅថា គេចាត់តាំងជាឃុំ ឃុំរបស់គេហ្នឹងគឺគេទទួលយកទៅៗគេរៀបចំជាអង្គភាពគេហៅថាអង្គភាពគេបញ្ជូនទៅស្រុកទៀត គេមានស្រុករបស់គេៗរៀបចំហើយខ្ញុំចូលទៅជាកងទ័ពស្រុក ។

បូលី៖   ៧០ប៉ុន្មានអ៊ី កងទ័ពស្រុក?

អាត៖   ជំនាន់នោះ ចុង៧២ ហើយ ។

បូលី៖   កំពង់ធំ នៅក្រោមការគ្រប់គ្រងរបស់ លន់ នល់ឬខាងកងទ័ពរំដោះអីទៅ?

អាត៖   ខាង លន់ នល់ ទេ ។

បូលី៖   ខាង លន់ នល់?

អាតៈ បាទ!

បូលីៈ ចុះអ៊ីពេលធ្វើដំណើរចេញទៅ ពេលដែលអ្នកផ្សេងទៀតចេញទៅហ្នឹង ខាង លន់ នល់ គេអត់មានឃាត់ឃាំងអីទេ?

អាតៈ ខាងហ្នឹងអត់មាន លន់ នល់ នៅទេតំបន់ខ្ញុំ ក្រោយរដ្ឋប្រហារហើយអត់ លន់ នល់ នៅតែទីក្រុង ។

បូលីៈ ទីរួមខេត្ត?

អាតៈ ទីរួមខេត្ត ។

បូលីៈ បារាយណ៍ នេះអត់ទេ?

អាតៈ បារាយណ៍ អត់ទេ! តាំងគោកក៏អត់ដែរ កំពង់ថ្ម អត់ដែរ តាំងក្រសាំង អត់ដែរ សន្ទុកក៏អត់ដែរ នៅតែទីរួមខេត្តទេ ។ បាទ! ហើយខាងនេះមានកំពង់ចាម នៅតែទីរួមខេត្តកំពង់ចាម ហើយព័ទ្ធភ្នំអីបន្តិចតែប៉ុណ្ណឹងទេ ហើយក្រៅពីហ្នឹងគឺមានត្រឹម ទៅខាងភ្នំពេញនោះមានតែត្រឹមកំពង់ចម្លងភ្នំពេញតែម្តង ក្រៅពីហ្នឹងគឺតំបន់ត្រួតត្រាដោយពួកចលនាគេតស៊ូ ។

បូលីៈ ចលនារំដោះហើយ?

អាតៈ បាទ!

បូលីៈ លឿនណាស់គិតទៅ?

អាតៈ បាទ!

បូលីៈ ពេលដែលអ៊ីចូលទៅដំបូងអ៊ីចូលទៅខាងទីពស្រុក?

អាតៈ បាទ!

បូលីៈ ស្រុកបារាយណ៍ហ្នឹងតែម្តង?

អាតៈ ស្រុកបារាយណ៍ ។

បូលីៈ បាទ! ពីណាគេគណៈស្រុកពេលហ្នឹង?

អាតៈ គណៈស្រុកពេលនោះឈ្មោះ កែវ ។

បូលីៈ កែវ?

អាតៈ បាទ! ឈ្មោះ កែវ ។

បូលីៈ គេរៀបចំចាត់តាំងជាស្រុកហើយអញ្ចឹង?

អាតៈ បាទ! ពេលនោះគេរៀបចំជាស្រុកហើយ ។

បូលីៈ នៅក្នុងភូមិភាគអ៊ី?

អាតៈ   អាហ្នឹងអត់ទាន់មានភូមិភាគទេ  ក្រោយមកបានគេបង្កើតជាភូមិភាគ ។

បូលីៈ   បាទ!  ឆ្នាំប៉ុន្មានអ៊ំ?

អាតៈ   ឆ្នាំ  ១៩៧៣ ។

បូលីៈ   ៧៣  បានបង្កើតភូមិភាគ?

អាតៈ   បាទ!  ខ្ញុំមិនដឹងច្បាស់ដែរ  តែក្រោយមកបានមានគេនិយាយថា  ភូមិភាគៗអញ្ចឹងតែម្តង ។

បូលីៈ   បាទ!  ពេលដែលអ៊ំចូលទៅហ្នឹងអ៊ំអត់ដែលឮភូមិភាគទេ?

អាតៈ   បាទ!  ប៉ុនការពិតគេរៀបចំយ៉ាងម៉េចអ៊ំមិនដឹងទេ ។

បូលីៈ   ហើយ  កែវ  ហ្នឹងគណៈស្រុកអញ្ចឹង ។

អាតៈ   បាទ!  គណៈស្រុកជិតទាន់នោះ ។

បូលីៈ   ចុះប្រធានខាងយោធាពីណាគេ  កងទ័ពស្រុកនោះណា៎?

អាតៈ   ប្រធានកងទ័ពរសុកឈ្មោះ  ហ៊ុំ ។

បូលីៈ   កែវ  នឹង  ហ៊ុំ  ពីណាធំជាង?

អាតៈ   កែវ  ធំជាងព្រោះគេប្រធានស្រុក  ហ៊ុំ  គាត់ទទួលខុសត្រូវខាងយោធា ។

បូលីៈ   ហ៊ុំ  អាចថាជាគណៈស្រុកតែទទួលខាងយោធា?

អាតៈ   បាទៗ!

បូលីៈ   កែវ  ហ្នឹងលេខាស្រុកហើយអញ្ចឹង?

អាតៈ   បាទ!  លេខាស្រុក ។

បូលីៈ   មួយគណៈស្រុកមានប៉ុន្មាននាក់អ៊ំ?

អាតៈ   មួយគណៈស្រុកហ្នឹង  ខ្ញុំក៏ក្តាប់ខាងស្រុកគេមិនបានដែរ  មិនដឹងជាគេរៀបចំគ្នាគេមានប៉ុន្មាននាក់ទេ  អាហ្នឹងនិយាយការពិតជាក់ស្តែង! ។

បូលីៈ   បាទអ៊ំបាទ!

អាតៈ   ព្រោះយើងកងទ័ព  យើងអត់ដឹងថាកិច្ចការរបស់គេយ៉ាងណា!  អត់ដឹង ។

បូលីៈ   រដ្ឋបាលគេ ។

អាតៈ   រដ្ឋបាលគេអ៊ំអត់ដឹងទេ   គ្រាន់តែគេបញ្ជូនអ៊ំឲ្យទៅនៅកងទ័ព   គេនៅតែហាត់យុទ្ធសាស្រ្តរបស់កងទ័ពតែប៉ុណ្ណោះឯង ។

បូលីៈ   ដូចជាអីខ្លះហាត់ហ្នឹង?

អាតៈ ហាត់ហ្នឹងដូចជា ដោះកាំភ្លើង ដូតកាំភ្លើង លាងកាំភ្លើង វិធីដោះ វិធីលាង ជំហាន១ ជំហាន ២ទៅ គេឲ្យយើងហាត់លូន ហាត់ក្រាប ហាត់ក្បាលខ្ពស់ទាប ឲ្យលូនក្រោមខ្សែលួស ខ្សែអីហ្នឹង ។

បូលីៈ ពីណាមកបង្ហាត់ពេលហ្នឹង?

អាតៈ កាលនោះមានបងប្អូនជនជាតិវៀតណាម ហៅថា ខ្មែរនៅវៀតណាម ពីដើម ។

បូលីៈ បាទ!

អាតៈ អ៊ូ! មិនខ្មែរនៅវៀតណាមទេ ហៅខ្មែរភាគខាងជើង ។

បូលីៈ ប៉ុនខ្មែរ ឬក៏យួន?

អាតៈ ខ្មែរៗ ។

បូលីៈ មិនមែនយួនទេ?

អាតៈ បាទ! ខ្មែរតែម្ដង គេហៅខ្មែរជំនាន់យៀកមិញ កាលនោះគេមានគោលការណ៍យ៉ាងម៉េចខ្ញុំក៏ អត់ដឹងទេ គេមានគោលការណ៍យកខ្មែរយើងទៅបង្ហាត់បង្រៀនយុទ្ធសាស្ត្រគេយ៉ាងណាក៏ខ្ញុំ អត់ដឹងដែរ ។ ប៉ុនដល់ពេលសភាពប្រទេសយើងអញ្ចឹងគឺស្រាប់តែខ្មែរយើងចេញមក រាប់ពាន់ នាក់មិនតិចទេ សុទ្ធតែអ្នក គេហៅជំនាន់ភាសាគេហៅថា កម្មាភិបាល! ។

បូលីៈ បាទ!

អាតៈ កម្មាភិបាលបច្ចេកទេសខាងយោធា ខាងស៊ីៗហ្នឹង គឺគេមកទាំងអស់សុទ្ធតែខ្មែរ ។

បូលីៈ ចុះមានជនជាតិយួនទេអ៊ំ?

អាតៈ អត់មានទេ! ពេលនោះអត់ទេ ។

បូលីៈ មានតែខ្មែរភាគខាងជើង?

អាតៈ បាទ! យួនៗមានតែបេះ យួនចូលមកតែម្ដងៗ ចូលទាំងទ័ពចូលទាំងជំនាញការណ៍វាទាំងអស់ វាមកនៅកងវា មកជួយវ៉ៃ ប៉ុន្តែខ្មែរយើងកងទ័ពរបស់ខ្មែរដោយឡែក ។

បូលីៈ អញ្ចឹងកងទ័ពខ្មែរឈរមួយដុំ កងទ័ពយួនឈរមួយដុំ?

អាតៈ បាទ!

បូលីៈ អត់មានឡូកលំគ្នាទេ?

អាតៈ អត់ឡូកលំគ្នាទេ ។ តែសុំបញ្ជាក់ប្អូនឯងបេះដែរ ដល់ខ្ញុំមកឡើងពីស្រុកមកភូមិភាគ ខ្ញុំចូលកង ទ័ពភូមិភាគ គេបញ្ជូនខ្ញុំ គេត្រូវការភូមិភាគ គេត្រូវការរើសទ័ពទៅទៀតគេឲ្យខ្ញុំមកភូមិភាគ៤ ។

បូលីៈ ភូមិភាគអីគេអ៊ំ?

អាតៈ ភូមិភាគ៤ ។

បូលីៈ ភូមិភាគ៤?

អាតៈ បាទ! ដែលមានកែវ ៣ក ។

បូលីៈ គេហៅភូមិភាគអញ្ចឹងតែម្តង?

អាតៈ បាទ! ភូមិភាគ៤ ។

បូលីៈ មិនមែនឧត្តរទេអ៎ី?

អាតៈ បាទ! ភូមិភាគឧត្តរអញ្ចឹងហើយ តែឈ្មោះ ភូមិភាគ៤ ។

បូលីៈ លេខភូមិភាគ៤?

អាតៈ លេខភូមិភាគ៤ ។

បូលីៈ (សុំបើកឯកសារជូនអ៊ំមើល) ប៉ុនភូមិភាគនេះរៀបក្រោយ៧៥ទេ ប៉ុនចាំមើលអ៊ំមើល់តើមែនឬយ៉ាងម៉េច នេះភូមិភាគឧត្តរអ៊ំ?

អាតៈ បាទ ។

បូលីៈ ភូមិភាគឧត្តរគេហៅថា ភូមិភាគ៣០៣ ដែលពីដំបូងឡើយហ្នឹងមាន កុយ ធួន ហៅធុច ហ្នឹងជាអ្នកដឹកនាំ?

អាតៈ បាទ! ក្រោយមកគេកែទៅជាភូមិភាគ៣០៤ វិញ ។

បូលីៈ ក្រោយមកកែទៅជាភូមិភាគ៣០៤ វិញអ៊ំ?

អាតៈ បាទ!

បូលីៈ ចុះម៉េចអ៊ំថាមិញភូមិភាគ៤?

អាតៈ បាទ! ភូមិភាគ៤ ខ្ញុំចូលមកដឹងគេប្រកាសថាភូមិភាគ៤អញ្ចឹងតែម្តង ។

បូលីៈ មិនមែន៣០៤ទេ?

អាតៈ អ៊ូ! ៣០៤ ។

បូលីៈ ៣០៤?

អាតៈ បាទ ៣០៤ ។

បូលីៈ ប៉ុនយើងហៅតែកន្ទុយៗ ភូមិភាគ៤អញ្ចឹងទៅ?

អាតៈ បាទ! ៣០៤ ។

បូលីៈ ៣០៤ អ៊ំ?

អាតៈ បាទ! ៣០៤ ។

បូលី៖ បាទ! នៅក្នុងនេះម៉េចបានគេដាក់៣០៣?

អាត៖ ៣០៤ហ្នឹងៗ

បូលី៖ អ៊ំមានដែលឮឈ្មោះ ៣០៣ទេ?

អាត៖ ៣០៣ មានតែខាង តាកែវ ៗ

បូលី៖ ខាងតាកែវ និរតី?

អាត៖ និរតី ៗ ប៉ុនអានោះ៣០៤ ៗ

បូលី៖ បាទ! ព្រោះនៅក្នុងនេះគេដាក់អក្សរ៣០៣ ណា៎អ៊ំ?

អាត៖ ៣០៣ អត់មានទេ ៗ

បូលី៖ បាទ! អញ្ចឹងបានន័យថាអានេះអាចបោះពុម្ពខុសក៏ថាបានដែរអញ្ចឹង ៗ អញ្ចឹងអ៊ំមិនដែលឮឈ្មោះ៣០៣ទេ?

អាត៖ បាទ! មានតំបន់មាន ៗ

បូលី៖ ៣០៤ពេលហ្នឹងអ៊ំស្ថិតនៅក្រោម អ្នកណាគេមេភូមិភាគ?

អាត៖ ភូមិភាគហ្នឹងគឺ តាមខ្ញុំដឹងគឺដែលខ្ញុំមករៀនឈ្មោះ កែ ពក ៗ

បូលី៖ កែ ពក?

អាត៖ បាទ! គាត់មេបញ្ជាការភូមិភាគ ហើយជាមេបញ្ជាការកងទ័ពភូមិភាគ ៗ មេបញ្ជាការភូមិភាគផង មេបញ្ជាការកងទ័ពភូមិភាគផង ៗ

បូលី៖ បានន័យថាពេលហ្នឹង កុយ ធួន គាត់មានតែឈ្មោះថាជាអ្នកដឹកនាំទេអញ្ចឹង?

អាត៖ បាទ!

បូលី៖ អំណាចដាក់ស្ដែងគឺនៅលើ កែ ពក ហើយអញ្ចឹង ព្រោះ កែ ពក គាត់កាន់ទ័ពភូមិភាគ ៗ

អាត៖ បាទ!

បូលី៖ ទ័ពភូមិភាគហ្នឹងគេហៅថាជាកងពលអីដែរអ៊ំ?

អាត៖ នៅទេ!

បូលី៖ អត់ទាន់ទេ?

អាត៖ បាទ!

បូលី៖ នៅត្រឹមណា?

អាត៖ នៅត្រឹមវរសេនាធំ ៗ

បូលី៖ បានវរសេនាធំហើយ?

អាតៈ បាទ! នៅវរសេនាតូច ក្រោយមកបានកែទម្រង់ទៅវរសេនាធំ កងទ័ពច្រើនបេះតែឡើងបន្តិច ៗ ដល់រំដោះប្រទេសហើយបានកើតជាកងពល រំដោះប្រទេសឆ្នាំ៧៥ បានរៀបចំជាកងពល ។

បូលីៈ អ៊ំនៅវរលេខប៉ុន្មាន?

អាតៈ ខ្ញុំលេខ ៧០៧ ។

បូលីៈ តូច ឬធំ?

អាតៈ វរសេនាធំ៧០៧ ។

បូលីៈ វរសេនាធំ៧០៧ របស់ភូមិភាគខត្តរអ៊ំ?

អាតៈ បាទ! ខត្តរ ។

បូលីៈ មានតែមួយហ្នឹងអ៊ំ?

អាតៈ មានកងគេច្រើនទៀត លេងកងគេ តែខ្ញុំនៅកងហ្នឹង ។

បូលីៈ កង៧០៧ហ្នឹង?

អាតៈ បាទ! ៧០៧ហ្នឹង ហើយមានកងគេច្រើនទៀត មិនមែនតែមួយកងហ្នឹងទេ បួនដប់កងនោះតែខ្ញុំចាំវាមិនអស់ ។

បូលីៈ មានច្រើនកងអញ្ចឹងអ៊ំ?

អាតៈ បាទ! ច្រើនកង យី! ទ័ពច្រើនណាស់ជំនាន់នោះ ព្រោះអារម្មណ៍យុទ្ធជនម្នាក់ៗចង់រំដោះប្រទេស ដើម្បីឲ្យស្ដេចមកគ្រប់គ្រង ។

បូលីៈ បាទ! ឲ្យមានស្ដេច?

អាតៈ បាទ!

បូលីៈ អ្នកណាគេប្រធានមេកងវរសេនាធំ៧០៧?

អាតៈ ឈ្មោះ ហឿង ហើយនឹង ចន ។

បូលីៈ ហឿង មេ?

អាតៈ ហឿង មេ, ចនអនុវរសេនាធំ ។

បូលីៈ ចន អនុ?

អាតៈ បាទ!

បូលីៈ បែងចែកជាប៉ុន្មានវរសេនាតូច៧០៧ហ្នឹងអ៊ំ?

អាតៈ ៧០៧ហ្នឹងវា វរសេនាធំនោះមាន៣វរសេនាតូច ។

បូលីៈ   បាទ! មានអីខ្លះ?

អាតៈ   មានគេចែកជា៣វរសេនាតូច ។

បូលីៈ   លេខប៉ុន្មាន?

អាតៈ   កាលនោះវាមានលេខ៤១, ៤២ និង៤៣ ។

បូលីៈ   អ៊ំនៅវរសេនាតូចលេខប៉ុន្មានកាលហ្នឹង?

អាតៈ   ខ្ញុំនៅទីបញ្ជាការវរសេនាតូចលេខ៤១ ។

បូលីៈ   ៤១ ពីណាគេប្រធានកាលហ្នឹងអ៊ំ?

អាតៈ   ៤១ វរសេនាតូចហ្នឹងឈ្មោះ ប៉ាន់ ហ្នឹងប្រធាន ។

បូលីៈ   ចុះអនុរបស់ ប៉ាន់?

អាតៈ   អនុរបស់ ប៉ាន់ ហ្នឹង ម៉ន ។

បូលីៈ   ចុះ៤២?

អាតៈ   ៤២ ស្គាល់គេមិនអស់ទេអូន ភ្លេចឈ្មោះអស់ហើយ ។

បូលីៈ   ៤៣ ស្គាល់ទេអ៊ំ?

អាតៈ   ៤៣ ក៏អត់ស្គាល់ដែរ ។

បូលីៈ   បាទ! អ៊ំស្គាល់តែរបស់អ៊ំ?

អាតៈ   បាទ! ស្គាល់តែអង្គភាពរបស់ខ្លួនឯង ។

បូលីៈ   ចុះកងពល៤១៧ហ្នឹង អាចចេញពីវរសេនាធំហ្នឹងទេ មើល៍ទៅ?

អាតៈ   កងពល ខ្ញុំសុំនិយាយប្រវត្តិបន្តិច ។

បូលីៈ   បាទ! អញ្ជើញ ។

អាតៈ   បាទ! ខ្ញុំកាលដើមឡើយ និយាយឲ្យខ្លីទៅ កាលដើមឡើយគេរំដោះប្រទេស ហើយគេដកខ្ញុំដូចថាយើងវា ដូចថាឪពុកខ្ញុំពីដើមមកប្រវត្តិគាត់ធ្វើក្រាំ ធ្វើជំទប់ ប្រវត្តិខ្ញុំមិនសូវល្អ គេក៏ដកខ្ញុំទៅផ្នែកកសិកម្មរបស់មជ្ឈិមគេ ។ គេបញ្ជូនខ្ញុំពីកំពង់ចាមហ្នឹង គេដកខ្ញុំឲ្យមកនៅកំពង់ចាម ។

បូលីៈ   ឆ្នាំប៉ុន្មានដកមកកំពង់ចាម ។

អាតៈ   តាមចាំ៧៥ ។

បូលីៈ   រំដោះហើយ?

អាតៈ   រំដោះហើយ ៧៥ ខែ៥ ។

បូលីៈ   អញ្ចឹងអ៊ំមានបានវៃចូលមកភ្នំពេញទេ?

អាតៈ   វ៉ៃចូលមកភ្នំពេញបាន ប៉ុន្តែគ្រាន់តែគេរំដោះភ្នំពេញហើយ គេដកខ្ញុំមកនេះវិញ ។

បូលីៈ   កំពង់ចាម បណ្តោយ?

អាតៈ   បាទ! មកកំពង់ចាម អត់បានរៀបចំអីដូចគេហឹកហាក់អីអត់ ។

បូលីៈ   អ៊ូ! ខ្ញុំសុំទៅសួរកន្លែងវ៉ៃចូលបន្តិចអឺពេលដែលអឺវ៉ៃចូលមកហ្នឹង វ៉ៃតាមផ្លូវណា?

អាតៈ   ខ្ញុំវ៉ៃខាងព្រែកក្តាម ។

បូលីៈ   តាមផ្លូវជាតិលេខ៥អញ្ចឹង?

អាតៈ   បាទ! តាមផ្លូវជាតិលេខ៥ ។

បូលីៈ   កាត់តាមវត្តគ្រោះ?

អាតៈ   បាទ! ឆ្លងទន្លេហ្នឹងមក ។

បូលីៈ   ឆ្លងទន្លេ?

អាតៈ   បាទ! មកវ៉ៃព្រែកព្នៅ ។

បូលីៈ   អ៊ូ! មកវ៉ៃនៅព្រែកព្នៅ?

អាតៈ   បាទ! ព្រោះទីតាំងវានៅព្រែកព្នៅ ។

បូលីៈ   ទីតាំងរបស់ លន់ នល់?

អាតៈ   បាទ!

បូលីៈ   ស្គាល់មេទេ មេខាង លន់ នល់?

អាតៈ   អ៊ើ! អត់ស្គាល់ ។

បូលីៈ   វ៉ៃប៉ុន្មានថ្ងៃបែកព្រែកព្នៅ?

អាតៈ   វ៉ៃតែមួយយប់ ។ ប៉ុនមុននឹងវ៉ៃអាហ្នឹង ទាល់តែវ៉ៃប្រសិទ្ធិសិន វ៉ៃប្រសិទ្ធិច្រើនលើកច្រើនសារ ណាស់ កងខ្ញុំមានកងគេទៅវ៉ៃភ្នំប្រសិទ្ធិ ព្រោះទីតាំងកាំភ្លើងធំវានៅហ្នឹង ។

បូលីៈ   នៅលើភ្នំតែម្តង?

អាតៈ   បាទ! នៅខាងលើភ្នំហ្នឹង វ៉ៃបានតាមចិត្ត ធ្វើប្រតិបត្តិ ទៅវ៉ៃរំដោះអាហ្នឹងហើយបានពួកខ្ញុំហ្នឹង គេបញ្ជាឲ្យទៅវ៉ៃនៅព្រែកព្នៅ ។

បូលីៈ   ពីណាគេអ្នកទៅវ៉ៃប្រសិទ្ធិ?

អាតៈ   វ៉ៃប្រសិទ្ធិ កាលនោះខ្ញុំមិនដឹងដែរ ។ ប៉ុនបែកមុខសញ្ញាគ្នាទៅវ៉ៃ មានកងពលគេផ្សេងៗទៀត ៥-៦-៧ កងពលទៅវ៉ៃហ្នឹង រួមជាមួយខាងនិរតី មានច្រើនកងពលណាស់ទៅវ៉ៃភ្នំប្រសិទ្ធិ ។

បូលីៈ   វ៉ៃប៉ុន្មានថ្ងៃបានបែកភ្នំប្រសិទ្ធិ?

អាត: ភ្នំប្រសិទ្ធិ កាលហ្នឹងដូចប៉ុន្មានទេ ជិតមួយអាទិត្យនោះ ។
បូលី: វ៉ៃយូរណាស់?
អាត: បាទ! ខ្ញុំនេះវ៉ៃតែមួយយប់ទេ ព្រែកព្នៅ វ៉ៃពីបចូលមកក្រុងភ្នំពេញតែម្តង ។
បូលី: ភ្នំប្រសិទ្ធិ ម៉េចបានវ៉ៃយូរម៉្លេះអ៊ី?
អាត: អាហ្នឹងទីតាំងវាវឹងមាំ ទីតាំងអាវុធគ្រាប់រំសេវអីនៅហ្នឹងទាំងអស់ យុទ្ធភ័ណ្ឌរបស់វា ទីតាំងកាំភ្លើងធំ រថក្រោះអីនៅហ្នឹង ។
បូលី: បន្តក់ពីលើមកតែម្តង?
អាត: បាទ! ចុះបើយើងឡើងមើលឃើញទាំងអស់ ចេញពីណាក៏ឃើញដែរ ។
បូលី: បាទ! មួយជុំវិញហ្នឹងមើលឃើញទាំងអស់?
អាត: បាទ! មើលឃើញទាំងអស់ ចុះវាបញ្ហាបាន អញ្ចឹងទៅវ៉ៃយកអាហ្នឹងមុនយុទ្ធសាស្ត្ររបស់វា ។
បូលី: ដល់វ៉ៃបែកអាហ្នឹងហើយ បានយើងវ៉ៃព្រែកព្នៅតាមក្រោយ?
អាត: បាទ! វ៉ៃជុំវិញភ្នំពេញបណ្តោយ ។
បូលី: តែមួយយប់អ៊ីចូលដល់ភ្នំពេញតែម្តងអញ្ចឹង?
អាត: បាទ!
បូលី: ចូលមកហ្នឹង ចូលមកតាមជិនាមាត់ទន្លេរហូត ឬយ៉ាងម៉េច?
អាត: បាទ! ជិនាមាត់ទន្លេរហូត មានកងគេៗចូលមកខាងរបស់ខ្ញុំទៀត ខាងនិរតី បញ្ចឹម ពិសេសអីគេខាងភូមិភាគនិរតី ។
បូលី: ចូលមកហ្នឹងមានទាហាន លន់ នល់ ស្ទាក់បាញ់តាមផ្លូវទេ ពេលចូលមកហ្នឹង?
អាត: អត់ទេ ។
បូលី: បែកព្រែកព្នៅហើយ?
អាត: បាទ! អត់ទេ ។
បូលី: អញ្ចឹងព្រែកព្នៅហ្នឹងក្រវ៉ាត់ចុងក្រោយហើយអញ្ចឹង?
អាត: បាទ! ចុងក្រោយហើយ ។
បូលី: ដល់ពេលចូលមកដល់អ៊ី?
អាត: ចុះព្រែកព្នៅហ្នឹង ចូលបន្តិចមកលេខ ៦ ហើយ ។
បូលី: បាទ!
អាត: កន្លែងឃ្លាំងប្រេង លេខ១ហ្នឹងកៀនស្អានជ្រោយចង្វារហ្នឹង ។

បូលី៖ ហើយពេលដែលអ៊ំចូលមកដល់អ៊ំឃើញទិដ្ឋភាពក្នុងក្រុងយ៉ាងម៉េចទៅ ប្រជាជនអី?

អាត៖ ខ្ញុំបានចូលទៅរយៈពេល២ថ្ងៃ ប៉ុនមិនបានដើរទៅណាទេ គ្រាន់តែចូលទៅមុខសញ្ញាខ្នងឯង នៅហ្នឹង ។

បូលី៖ នៅម្តុំណាទៅដល់?

អាត៖ ខ្ញុំចូលទៅនៅម្តុំព្រែកព្នៅហ្នឹងហើយ ខ្ញុំមកស្ពានជ្រោយចង្វារ គេឲ្យមកប្រចាំការនៅហ្នឹង ។

បូលី៖ ជុំវិញស្ពានជ្រោយចង្វារហ្នឹង?

អាត៖ បាទ! ជុំវិញស្ពានជ្រោយចង្វារ ហើយនឹងស្ងាតចាស់ ។

បូលី៖ អ៊ូ! ស្ងាតចាស់ដែរ?

អាត៖ បាទ ។

បូលី៖ ពេលហ្នឹង ពេលដែលចូលដល់ភ្នាមមិនថ្ងៃ១៧អ៊ំ?

អាត៖ បាទ ។

បូលី៖ ពេលហ្នឹងគេមិនជម្លៀសប្រជាជនចេញភ្នាម?

អាត៖ បាទ! នៅទេអូន ៣ថ្ងៃក្រោមមកទៀត ។

បូលី៖ ៣ ថ្ងៃក្រោយទៀត?

អាត៖ បាទ!

បូលី៖ ពេលហ្នឹងអ៊ំមានបានបទបញ្ជាអី ឲ្យជម្លៀសប្រជាជនទេពេលហ្នឹង?

អាត៖ ពេលហ្នឹងគឺគេមានផែនការណ៍ជម្លៀសប្រជាជនចេញមកក្រៅគឺគេខ្លាច យន្តរវាទម្លាក់ យន្តហោះអាមេរិចវាទម្លាក់ ព្រោះគេក្តាប់ចាប់បានតាមតេអូរថា វាបញ្ជាឲ្យយន្តហោះមកទម្លាក់ បាទ! អញ្ចឹងពេលនោះខ្ញុំមិនដឹងថា ផែនការណ៍គេយ៉ាងណាទេ ប៉ុន្តែខ្ញុំដឹងថា ពេលនោះគឺខាង ថ្នាក់លើហ្នឹង យើងហៅថ្នាក់លើ ខាងអង្គការគេហ្នឹងគេត្រូវការជម្លៀសប្រជាជន ។

បូលី៖ គេប្រាប់អញ្ចឹងតែម្តង?

អាត៖ បាទ! គេប្រាប់អញ្ចឹងតែម្តង ។ ពេលនោះខ្ញុំក៏ត្រូវគេដកមកនៅកំពង់ចាមដែរ ។

បូលី៖ បាទ! ប៉ុនអាផែនការណ៍ជម្លៀសហ្នឹងគេប្រាប់ថាដូចម្តេចអ៊ំពេលហ្នឹង?

អាត៖ ផែនការណ៍ជម្លៀសគេប្រាប់ដូចនិយាយមិញហ្នឹងអញ្ចឹង គេថាគេអ្នកមកផ្សាយហ្នឹងគេថា ឲ្យកង ទ័ពទាំងអស់ធ្វើការជម្លៀសប្រជាជន ព្រោះតាមការក្តាប់របស់គេ តាមតេអូ តេអីគេថា ពួក អាមេរិចហ្នឹងគេមានផែនការណ៍ទម្លាក់កម្ទេចក្រុងភ្នំពេញតែម្តង ដើម្បីជៀសវាងកុំឲ្យប៉ះពាល់ ដល់ប្រជាពលរដ្ឋបងប្អូន គឺសុំឲ្យបងប្អូនជម្លៀសចេញ ជម្លៀសខ្លួនចេញសិនៗ! ។

បូលី៖	បាទៗ! ហើយអ៊ំនៅបានតែពីរថ្ងៃគេដកអ៊ំមកវិញ?

អាត៖	បាទ!

បូលី៖	អ៊ំមកវិញហ្នឹងមានឃើញប្រជាជនដើរតាមផ្លូវទេ?

អាត៖	មានៗខ្លះ ។

បូលី៖	មានដែរ?

អាត៖	បាទ! មានអ្នកខ្លះគេមិនទាន់បានប្រាប់ផង គេរត់ចេញខ្លះហើយ គេភ័យគេ ។

បូលី៖	បាទ! ស្ថានភាពពេលហ្នឹងអ៊ំមើលឃើញមានលក្ខណៈយ៉ាងម៉េចពេលអ៊ំដើរចេញមកហ្នឹង?

អាត៖	ទេ! ដូចធម្មតា មនុស្សដើរចេញមកដូចមិនមានអី អើ! វាធម្មតាទេវាទឹកមុខបងប្អូនភ័យព្រួយវាបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួន ផ្ទះសម្បែងស្អីៗហ្នឹង ខ្លះគ្នាភ័យខ្លាចអញ្ចឹងទៅមកតែខ្លួន ។

បូលី៖	បាទ! អត់បានយករបស់របរអីមកតាម?

អាត៖	បាទ! រហូតដល់ខ្ញុំធ្វើដំណើរមកក្រុងកំពង់ចាម ហ្នឹង ក្រុងកំពង់ចាមក៏ដូចគ្នា ។

បូលី៖	ជម្លៀសដែរ?

អាត៖	បាទ!

បូលី៖	ជម្លៀសទៅខាងណាវិញកំពង់ចាម?

អាត៖	កំពង់ចាម ជម្លៀសទៅតាមស្រុកជិតៗហ្នឹង ។

បូលី៖	កំពង់ចាម ជាមួយភ្នំពេញខាងណាជម្លៀសមុន?

អាត៖	ភ្នំពេញ ជម្លៀសមុន ។

បូលី៖	ភ្នំពេញមុន?

អាត៖	បាទ!

បូលី៖	កំពង់ចាម ពេលណាបានជម្លៀស?

អាត៖	ក្រោយមកបានជម្លៀស ។

បូលី៖	ប្រហែលជាប៉ុន្មានថ្ងៃ ក្រោយមក?

អាត៖	ប្រហែលជាមួយអាទិត្យ ។

បូលី៖	មួយអាទិត្យក្រោយមក?

អាត៖	បាទ! មួយអាទិត្យបានដាច់ ។ ព្រោះខ្ញុំនៅបាន ៣-៤ថ្ងៃគេឲ្យមកកំពង់ចាមហ្នឹង មកហ្នឹងគេចាប់ផ្ដើមវៃអាហ្នឹងរំដោះចេញតែម្ដង ។

បូលីៈ ហ៎! កំពង់ចាមក្រែងវ៉ៃបានមុនភ្នំពេញ?

អាតៈ អត់ទេ! កំពង់ចាមក្រោយ ក្រោយមកទៀតបានសៀមរាប ។

បូលីៈ សៀមរាប?

អាតៈ បាទ!

បូលីៈ អ៊ូ! អញ្ចឹងនៅទីរួមខេត្តកំពង់ចាម នៅខ្លាំងដែរអញ្ចឹង?

អាតៈ បាទ! ខ្លាំងដែរ ។

បូលីៈ រំលំភ្នំពេញមុនអញ្ចឹង?

អាតៈ បាទ! គេមិនចង់វ៉ៃអាចំណុចនេះទេ គេទៅវ៉ៃយកបេះដូងមុន ។ បើកាលណាបេះដូងហើយ អាអស់ហ្នឹងខ្លាំងអីទៀតអាសៀមរាបអី ។ ឃើញទេយុទ្ធសាស្ត្ររបស់គេអញ្ចឹង ។ ហែងមានអីខ្លាំងបើមេៗនៅភ្នំពេញនោះរត់អស់ទៅហើយ គ្មានអ្នកណាឲ្យទៀត ។

បូលីៈ មានអីបញ្ហាទៀត ។

អាតៈ មានអីបញ្ហាទៀត អានេះចុះចាញ់ឯង អស់នេះដូច ។

បូលីៈ ដូចគេដៃជើងគេកាត់សរសៃរបោលអស់?

អាតៈ បាទ! លើកដៃខ្លួនឯង នេះជាយុទ្ធសាស្ត្ររបស់គេ ។

បូលីៈ កំពង់ចាម ជម្លៀសក្រោយភ្នំពេញមួយអាទិត្យ ។

អាតៈ បាទ! មួយអាទិត្យ ។

បូលីៈ ដូចបាត់ដំបងដែរ! ជម្លៀសក្រោយភ្នំពេញមួយអាទិត្យដែរ?

អាតៈ បាទ! ដូចគ្នាសៀមរាប ។

បូលីៈ សៀមរាបដូចគ្នាដែរ?

អាតៈ បាទ! គេអត់ទាន់វាយទេ កំពង់ធំ កំពង់អី ក៏គេអត់ទាន់វាយដែរ គេឲ្យលើកដៃខ្លួនឯងតែម្តងដូចគ្នា គេវាយយកតែមួយហ្នឹង រួមទៅក្នុងវាយយកតែអាមួយហ្នឹង ។

បូលីៈ (ស្តាប់ពុំបាន) ។

អាតៈ ខេត្តទាំងអស់អត់វាយទេ យកទៅភ្នំពេញទាំងអស់ ។ អស់ភ្នំពេញហើយ គេកាត់យកទៅមានអីគ្មានអីបញ្ហា គ្មានអីសម្រួលទៅណា មិនលើកដៃមិនបាច់វាយទេ ។

បូលីៈ ហើយអ៊ឹ គេឲ្យមកកំពង់ចាម មកធ្វើអ្វី?

អាតៈ ក្រោយមកដូចខ្ញុំនិយាយតាំងពីដើមមកថា ក្រោយមកបានខ្ញុំដឹងទេណា ដឹងថាខ្ញុំវាជាប់និន្នាការអីចេះចុះដូចខ្ញុំនិយាយពីដើមមិញ ឪពុកម្តាយទេ ខ្ញុំគ្មានអីទេ ថ្នាក់ទី៧ ពួកនេះតាអ៊ុំអស្សារ្យទេ

ប៉ុន្តែខាងនោះមិនដឹងជាយ៉ាងម៉េច ខ្ញុំវាយល់មិនដល់ដែរ ។ ក្រោយមកបានខ្ញុំដឹងថា ស្គួរពួកម៉ាកអីទៅថាហ៊ុមហែងជាប់និន្នាការឪពុកហែងចេះចុះគេអ្នកត្រង់ណា ប្រាប់! គេអ្នកដឹកនាំអញ្ចឹងទៅបានគេដកមក ។ ខ្ញុំមកនៅហ្នឹងប្រហែលជា១អាទិត្យ កំពង់ចាមប្រហែលជា១អាទិត្យ គេដកខ្ញុំ គ្រាន់តែគេរៀបចំ ទេ១អាទិត្យអី! ប្រហែលជាប់ជា១ខែ ជិត២ខែនោះយូរដែរមិនមែន១,២អាទិត្យ គ្រាន់តែខ្ញុំនៅហ្នឹង រហូតដល់ខ្ញុំមកបោសសំអាត កំទេចកំទីរោងចក្រវាយបាក់បែកអី កាលជំនាន់បាញ់គ្នាហ្នឹង បោសសំអាតរោងចក្រតំបាញកំពង់ចាមហ្នឹង ។ នាំកម្មករអីទៅ បោសសំអាតកំទេចកំទីហ្នឹង គ្រាប់រំសេវ គ្រាប់អី សំអាតអស់ ។ បាទ! យូរដែរ ប្រហែលជាជាប់១ខែ, ២នោះ ។

បូលី: ពីភ្នំពេញមកកំពង់ចាម អ៊ឹជិះអីមក?

អាត: ខ្ញុំជិះម៉ូតូ ។

បូលី: ម៉ូតូ ម៉ាកអីគេអ៊ឹ?

អាត: ម៉ាក យើងកាលនោះវា(ស្តាប់ពុំបាន) ?

បូលី: CL អី?

អាត: បាទ! CL.

បូលី: ប៉ុន្មាននាក់មក?

អាត: មកតែឯង ។

បូលី: អញ្ចឹង?

អាត: បាទ! មកតែឯង ។

បូលី: ពីណាបញ្ជាឲ្យអ៊ឹមក?

អាត: កែ ពក អ្នកបញ្ជាមក ។

បូលី: តាពកតែម្តង?

អាត: បាទ!

បូលី: ហើយមកអញ្ចឹង គេមានលិខិតស្នាមអីត្រឹមត្រូវទេ?

អាត: កាលខ្ញុំមកនោះអត់ទេ! គ្រាន់តែប្រាប់ហៅថា នែ៎កគេនិយាយភាសាថាមិត្តឯងត្រូវផ្លាស់ពីហ្នឹងទៅកំពង់ចាម ។ ភារកិច្ចទុកឲ្យគេ យើងអត់មាននិយាយតវ៉ាអីកើតទេ ។

បូលី: ប៉ុនអត់មានក្រដាសស្នាម ក្រដាសអីអ៊ឹ អត់ខ្លាចថាកងទ័ពខ្មែរក្រហមដែលនៅយាមតាមផ្លូវហ្នឹងយល់ច្រលំថាអ៊ឹជាទាហានលន់ នល់ បន្លំធ្វើខ្មែរក្រហមជិះម៉ូតូចេញអីទេ?

អាតៈ   អត់ទេ! កងខ្ញុំគេស្គាល់អស់ ។

បូលីៈ   សុទ្ធតែកងអឹ?

អាតៈ   បាទ!

បូលីៈ   យាមតាមផ្លូវ?

អាតៈ   បាទ! យាមតាមផ្លូវ សុទ្ធតែកងខ្ញុំ គេស្គាល់ខ្ញុំ ។

បូលីៈ   អឹឋានៈជាអីនៅក្នុងកងអឹ?

អាតៈ   ខ្ញុំវាកាលនោះ ខ្ញុំនៅវរសេនាតូច ។

បូលីៈ   អនុសេនាតូច?

អាតៈ   បាទ!

បូលីៈ   ប្រធានអនុសេនាតូច?

អាតៈ   បាទ! ប្រធានអនុសេនាតូច

បូលីៈ   ហើយធ្វើម៉េចបានអឺដឹងថាមកដល់ កំពង់ចាមអឹជួបនរណា ពីណី?

អាតៈ   មកហ្នឹង មកជួបប្រធានមន្ទីរគេនៅកំពង់ចាមហ្នឹង ។

បូលីៈ   បន្ទាយអីគេអឹ?

អាតៈ   បន្ទាយរបស់ភូមិភាគគេហ្នឹង ។

បូលីៈ   ភូមិភាគអីគេ?

អាតៈ   ភូមិភាគបូព៌ា ។

បូលីៈ   ភូមិភាគ៣០៤?

អាតៈ   ភូមិភាគ៣០៤ គេនៅប្រចាំនៅហ្នឹង ព្រោះគេមានគេអូ និយាយគ្នា ព្រោះកាលនោះ(ស្តាប់ពុំបាន) ព្រោះអាមេរិកកាំង ទៅនិយាយគ្នាតែម្តង ។ គ្រាន់តែមកដល់ ទទួលខ្ញុំ! គេឲ្យស្នាក់នៅប្រហែលជា១អាទិត្យ បានគេរៀបចំឲ្យខ្ញុំមក កន្លែងរោងចក្រ ។ នៅហ្នឹងបានប្រហែល១ខែ, ២ខែក្រោយមកទៀត បានគេដកខ្ញុំមកបាត់តំបង ។

បូលីៈ   មកបាត់ដំបងទៀត?

អាតៈ   អូ! ឥលូវ សុំត្រឹមកំពង់ចាមសិន ។

បូលីៈ   ពេលដែលអឹមក តា ពកគាត់នៅភ្នំពេញ?

អាតៈ   បាទ! គាត់ទៅរួមកន្លែងការងារ ។

បូលីៈ   មិនមែននៅកំពង់ចាមទេ?

អាត៖ បាទ!

បូលី៖ ចុះពីណាគ្រប់គ្រងមន្ទីរភូមិភាគ?

អាត៖ កាលនោះ វាមន្ទីរភូមិភាគវា ពេលនោះគឺ មានភ្លេចឈ្មោះហើយ ភ្លេចឈ្មោះគាត់ហើយ រកនឹកមើលមិឃើញ ។ នឹកអញ្ចឹងទៅ នឹកឃើញតែមុខគាត់ ។

បូលី៖ គាត់នៅរស់ទេ?

អាត៖ គាត់ស្លាប់បាត់ហើយ ។

បូលី៖ គាត់ប្រធានមន្ទីរភូមិភាគ ។

អាត៖ ប្រធានមន្ទីររបស់ភូមិភាគ ។

បូលី៖ ប្រធានមន្ទីររបស់ភូមិភាគ! មិនមន្ទីរភូមិមែនមន្ទីរភូមិភាគទេ?

អាត៖ ភូមិហ្នឹង ក្រោយមកអឹពក គាត់នៅដែរ! កែ ពកនៅហ្នឹង ។

បូលី៖ អញ្ចឹងមន្ទីរភូមិភាគ៣០៤នៅកំពង់ចាមនេះ មិនមែនកំពង់ធំនេះទេ?

អាត៖ បាទ! នៅក្រុងបណ្តោយ ។

បូលី៖ ប៉ុនអាគារមួយណា អាគារមុខសាលាខេត្ត ឬអី?

អាត៖ អាគារជិត មិនមែនសាលាខេត្តទេ អាគារឈៀងណាំស្ពី អាគារអីមិនដឹង ជិតអាផ្ទះសំណាក់ ផ្លូវ កាលនោះវាផ្លូវទី២ អាផ្លូវទី២មក ផ្លូវមាត់ទន្លេយើងហ្នឹង ។

បូលី៖ អាចស្មានដឹង មានសួនច្បារមានអី?

អាត៖ បាទ! អត់មានទេ ។ ផ្ទះគេ វីឡាគេធំណា ភូមិគ្រឹះគេតែម្តង ផ្ទះគេរបៀបជាភូមិគ្រឹះតែម្តង ។

បូលី៖ អតីតជាអ្វីអាគារហ្នឹង ដឹងទេ?

អាត៖ មិនទេ! ខ្ញុំភ្លេចបាត់អត់ហើយ ។

បូលី៖ បាទ!បែបភ្លៀងអីទេ?

អាត៖ ទេ! មិនមែនទេ! វាយូរឆ្នាំទៅហើយ ។

បូលី៖ បាទ! យូរមកហើយ ។ ហើយអឹមកទទួលបន្ទុកអីគេមកកំពង់ចាមហ្នឹង?

អាត៖ ខ្ញុំទទួលបន្ទុកនែក៉ ខាងកាលនោះគេហៅថាសមាជិកគេរៀបចំផ្នែករបស់គេណា គេរៀបចំផ្នែក ផ្នែកខាងខស្សរាហកម្ម ។

បូលី៖ ខស្សរាហកម្ម?

អាត៖ បាទ!

បូលី៖ ធ្វើអីខ្លះទៅ ខស្សរាហកម្ម?

អាត៖ ខស្សរាហកម្មជំនាន់នោះវាមិនទាន់មានរូបរាងទេ តែគ្រាន់ថាយើងមានឈ្មោះខស្សរាហកម្មអញ្ចឹង ហើយ គេបញ្ជូនយើងឲ្យបោសសំអាតនៅកន្លែងរោងចក្រ ព្រោះយើងផ្នែកហ្នឹង ខស្សរាហកម្ម ៗ ដឹកនាំកម្លាំងមក១០០ ទៅ២០០នាក់ បោសសំអាត ហើយបោះទីតាំងនៅរោងចក្រហ្នឹង ៗ

បូលី៖ ដើម្បីអីបោះទីតាំង?

អាត៖ ដើម្បីបោសសំអាតនៅហ្នឹង ៗ

បូលី៖ គ្រាន់តែបោសសំអាតតែប៉ុណ្ណឹង?

អាត៖ បាទ! ខាងធ្វើផ្ទះធ្វើអីឲ្យកម្មកររស់នៅ?

បូលី៖ មានរោងចក្រអ្វីខ្លះ កាលហ្នឹងអឹ?

អាត៖ រោងចក្រតំបាញ តំបាញក្រណាត់ ៗ

បូលី៖ តំបាញ់ក្រណាត់?

អាត៖ បាទ! នៅកំពង់ចាម ៗ

បូលី៖ ក្រៅពីក្រណាត់មានអីផ្សេងទៀតទេ?

អាត៖ មានតែក្រណាត់ ៗ

បូលី៖ មានតែក្រណាត់ហ្នឹងមួយគត់?

អាត៖ បាទ! ក្រណាត់មួយ ៗ កាលនោះយើងមិនទាន់សម្បូរណា រោងចក្រមានតែកំពង់ចាម ហើយហ្នឹង បាត់ដំបងទេ ជំនាន់នោះ ៗ

បូលី៖ កំពង់ចាមក្រណាត់?

អាត៖ កំពង់ចាមក្រណាត់ ៗ

បូលី៖ អញ្ចឹងបាត់ដំបង?

អាត៖ បាត់ដំបង ក៏ក្រណាត់ ៗ

បូលី៖ ក្រណាត់ដែរ?

អាត៖ បាទ!(សើច) ៗ ជំនាន់សីហនុសម្តេច ៗ

បូលី៖ យើងត្បាញក្រណាត់អីខ្លះ?

អាត៖ ខ្ញុំមិនច្បាស់អីខ្លះទេថា ពីមុនមកគេធ្វើក្រណាត់អីៗ គ្រាន់តែឃើញរូបភាពរបស់គេដែលមានហ្នឹងណា ជាភួយ ជាក្រមា ជាក្រណាត់សអីយើងធម្មតា ៗ

បូលី៖ ហើយយើងបានអីត្បាញទៅ? សូត្រអីយកមកពីណា?

អាតៈ  អត់មានសូត្រអីផង អំបោះ ។

បូលីៈ  អំបោះ! យកមកពីណាអំបោះហ្នឹង?

អាតៈ  យកពីណាៗ ខ្ញុំអត់ដឹងដែរ?

បូលីៈ  មិនដឹងថាគេនាំចូល ឬក៏បង្កើតដោយខ្លួនឯង?

អាតៈ  អត់ដឹង!

បូលីៈ  អត់ដឹងទេណ៎អ៊ឺ?

អាតៈ  (ស្តាប់ពុំបាន) ។

បូលីៈ  អ៊ឺក្តៅហេ៎?

អាតៈ  អត់អីទេ ៗ ហ៊េ៎អីទេខ្ញុំនោះ ។

បូលីៈ  យើងអាចបន្តិចទៀតបានទេ? បើវាដេញយើង យើងរត់ទៅនោះ ។

អាតៈ  នោះក្រោយផ្ទះគេនោះ អត់មាននរណានៅទេ(ដើរទៅរកកន្លែងម្លប់) ។

បូលីៈ  អញ្ចឹង អ៊ឺមានប្រសាសន៍ថាអ៊ឺ នៅកំពង់ចាមបានតែប្រហែល១ខែ ២ខែ បានអ៊ឺបញ្ជូនអ៊ឺទៅបាត់ដំបងទៀត ។ ទៅធ្វើអីនៅបាត់ដំបងហ្នឹង?

អាតៈ  ទៅរៀនកសិកម្ម រៀនសាលាបច្ចេកទេសកសិកម្ម ។

បូលីៈ  នៅបាត់ដំបងមានសាលាអ៊ឺ?

អាតៈ  បាទ! សាលាបច្ចេកទេសកសិកម្ម របស់ជប៉ុន អតីតរបស់ជប៉ុន ។

បូលីៈ  រៀនរបៀបអីខ្លះធ្វើស្រែ ឬយ៉ាងម៉េច?

អាតៈ  ធ្វើស្រែ! ធ្វើតែស្រែមួយមុខ ។ ធ្វើស្រែហ្នឹង វាមានមុខជំនាញរបស់វា មានមុខជំនាញបច្ចេកទេសគេណា ។ មានធ្វើដី មានពិធីផ្សំពូជ បង្កាត់ពូជ ថែទាំសត្វល្អិត គីមី ខត្តុនិយមមើលធាតុអាកាសសមស្របហ្នឹងដំណាំស្រូវ បច្ចេកទេសខ្ពស់ដែរ ។

បូលីៈ  សាលានៅម្តុំណា? សាលាកសិកម្ម?

អាតៈ  សាលាកសិកម្មហៅមេច្បារ ។

បូលីៈ  គេហៅមេច្បារ?

អាតៈ  បាទ! មេច្បារនៅក្នុងថ្មគោល ។

បូលីៈ  ថ្មគោលឯនោះ?

អាតៈ  ថ្មគោលនៅភ្នំតូច ភ្នំធំ ។

បូលីៈ  មិនមែនទីរួមខេត្តទេ?

អាតៈ  មិនមែនទេ ។ នៅចន្លោះថ្មគោល និងភ្នំធំ គឺមេប្បារហ្នឹងឯង ។

បូលីៈ  ហើយអ្នកណា ជាអ្នកបង្រៀន?

អាតៈ  បង្រៀនគឺចិនជំនាន់ ។

បូលីៈ  គ្រូចិនហេ៎?

អាតៈ  បាទ! គ្រូចិន ។

បូលីៈ  ហើយស្ដាប់ម៉េចទៅអ៊ី?

អាតៈ  មានគេអ្នកបកប្រែ ។

បូលីៈ  មានឋីបក?

អាតៈ  មានឋីបកខ្មែរ ។ កូនកាត់ចិនគេចេះភាសាចិន បកប្រែ ។

បូលីៈ  ប៉ុន្មានអ្នកគ្រូចិន?

អាតៈ  ចិនវា៣០នាក់! ចិនគេធ្វើកសិកម្ម ។

បូលីៈ  រៀបប៉ុន្មានថ្ងៃ?

អាតៈ  ហេ៎!  រៀនមិនថ្ងៃទេ អូន រាប់ឆ្នាំ ។ ខ្ញុំរៀន៣ឆ្នាំ នៅហ្នឹង ។

បូលីៈ  ហា៎! បានន័យថាសម័យខ្មែរក្រហមទាំងមូល អ៊ំរៀននៅហ្នឹងរហូត?

អាតៈ  បាទ! នៅហ្នឹងរហូត ។

បូលីៈ  អត់បានចេញធ្វើការ ធ្វើអីសោះ?

អាតៈ  បាទ! អត់ព្រោះ ខ្ញុំគេឲ្យធ្វើប្រធាន ។

បូលីៈ  ប្រធានសាលាហ្នឹងតែម្ដង?

អាតៈ  បាទ! ប្រធានសាលា ។

បូលីៈ  បើប្រៀបធៀបមកឥលូវ អ៊ីជាសាកលវិទ្យាធិការហើយនេះ ។

អាតៈ  បាទ! ប្រធានសាលាជំនាន់នោះ ។

បូលីៈ  គេហៅអេ៎ ឈ្មោះផ្លូវការគេហៅអីគេ?

អាតៈ  សាលាជំនាន់នោះ?

បូលីៈ  បាទ!

អាតៈ  គេហៅសាលាបង្រៀនបច្ចេកទេសកសិកម្មមជ្ឈិម ។

បូលីៈ  សាលាបង្រៀន!

អាត៖ បច្ចេកទេសកសិកម្មរបស់មជ្ឈិម ។ ភាសាគេជំនាន់ហ្នឹង ពាក្យថាមជ្ឈិមជំនាន់ហ្នឹង ជាន់ខ្ពស់ ហើយជំនាន់ហ្នឹងលេខ១ ។

បូលី៖ ហើយអ៊ីមេគ្រូហើយនេះ?

អាត៖ អត់ទេ! គេឲ្យធ្វើប្រធាន មិនមែនមេគ្រូទេ គ្រូចិនទេអ្នកបង្រៀន ។

បូលី៖ ប៉ុនមេសាលាហើយ?

អាត៖ បាទ! មេសាលា ។

បូលី៖ អ៊ីជាប្រធានណ៎?

អាត៖ បាទ! ជាប្រធានសាលា ។

បូលី៖ ហើយអ្នកដែលត្រូវរៀនបច្ចេកទេស ទូទាំងប្រទេសមករៀនសាលាហ្នឹង ឬក៏រៀនតែល្អម?

អាត៖ ទូទាំងប្រទេស ទូទាំងតំបន់ ។

បូលី៖ ទូទាំងប្រទេស មករៀនហ្នឹង ទាំងអស់គ្នា?

អាត៖ មករៀនហ្នឹងទាំងអស់ ។

បូលី៖ មានកូនសិស្សប្រហែលជាប៉ុន្មាននាក់ដែរ?

អាត៖ ប្រហែលជា២០០នាក់ ។

បូលី៖ សរុបទាំងអស់ហេ៎?

អាត៖ បាទ! អាហ្នឹងគេដកយកមកមួយៗ តាមខេត្តមក វាសរុបមកជុំខ្ញុំហ្នឹង វា២០០នាក់ ។

បូលី៖ ហើយសិស្សអាម្នាក់ៗហ្នឹង រៀនប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

អាត៖ សិស្សម្នាក់ៗ រៀនមួយឆ្នាំ ។

បូលី៖ មួយឆ្នាំគត់?

អាត៖ បាទ! ១ឆ្នាំគត់ ។

បូលី៖ រៀនបច្ចេកទេសហ្នឹង?

អាត៖ បាទ!

បូលី៖ រៀនហើយ! បានឲ្យវិលទៅខេត្តវិញ?

អាត៖ បាទ!

បូលី៖ គ្រប់គ្រាន់ទេ រៀន២០០នាក់ អីគ្រប់គ្រងខេត្ត មួយប្រទេសទាំងមូល?

អាតៈ ពេលនោះ ខ្ញុំក៏មិនដឹងដែរ គ្រាន់តែដឹងថា កម្រិតនៃការអប់រំ ការបំពាក់បំប៉នហ្នឹងជាបន្តបន្ទាប់ ដូចថាឆ្នាំនែក! ពួកសិស្សរៀនអាវគ្គទី១នេះ ត្រូវចេញទៅចូលវគ្គទី២ទៀត សិស្សថ្នាក់វគ្គទី២ ទៀត។ វគ្គទី២ចេញទៅ សិស្សចូលថ្នាក់វគ្គទី៣ទៀត។

បូលីៈ មួយវគ្គ មួយឆ្នាំ?

អាតៈ បាទ! ១វគ្គ ១ឆ្នាំ។

បូលីៈ អញ្ចឹងមករៀន សុទ្ធតែកម្មាភិបាលហើយអញ្ចឹង? កម្មាភិបាលធំហើយអញ្ចឹង?

អាតៈ បាទ! កម្មាភិបាលធំៗ។ ថ្នាក់អនុកសិកម្មតំបន់អី ខាងកសិកម្មនោះ ឬក៏កម្រិតទាប ត្រឹមមេឃុំ។

បូលីៈ មេឃុំហ៎អឺ?

អាតៈ បាទ!

បូលីៈ កាលហ្នឹងគេហៅមេឃុំ ឬក៏ប្រធានសហករណ៍?

អាតៈ ហៅប្រធានសហករណ៍។

បូលីៈ កាលហ្នឹង អត់មានឃុំទេអឺ?

អាតៈ អត់ទេ! មានតែប្រធានសហករណ៍។ ការពិតឃុំគេមាន បើប៉ុន្តែនៅក្នុងឃុំគេនោះ គេមានសហករណ៍គេច្រើនណាស់ ព្រោះខ្ញុំវា ដូចប្រវត្តិខ្ញុំនិយាយអំបាញ់មិញអញ្ចឹង ខ្ញុំវានិយាយ ខ្ញុំពីមុន ខ្ញុំនៅយោធា ក្រោយពីយោធាគេដក ខ្ញុំមកនៅរោងចក្រ ដកពីរោងចក្រមក គេឲ្យមករៀនកសិកម្ម ដល់អញ្ចឹងខាងមូលដ្ឋាន ខ្ញុំអត់ជាប់ស្អិតទេ ខ្ញុំអត់បាននៅ មិនដែលចុះប្រលូក។

បូលីៈ អឺមានជំនាញអី បានគេឲ្យអឺមកធ្វើប្រធានសាលាកសិកម្មហ្នឹង?

អាតៈ បាទ!

បូលីៈ ម៉េចបានគេដកអឺមកខាងកសិកម្ម អឺធ្លាប់មានជំនាញអីពីមុនមក?

អាតៈ ហ៊ូ! គឺកែ ពក ធ្លាប់ធ្វើការស្រុកទេសគាត់នៅជិតខ្ញុំហ្នឹងដែរ ប៉ុនប្រវត្តិខ្ញុំអ្នកធ្វើស្រែ ធ្វើចម្ការឪពុកម្តាយ ដល់អញ្ចឹងទៅក៏គាត់ដកខ្ញុំទៅរៀនកសិកម្មហ្នឹង។

បូលីៈ ផ្ទះអឺ នៅជិតផ្ទះកែ ពក?

អាតៈ ឆ្ងាយពីគ្នាដែរ។ ប៉ុន្តែ គាត់ធ្លាប់ដឹងពីប្រវត្តិឪពុកម្តាយខ្ញុំ។

បូលីៈ ធ្លាប់រាប់អានគ្នាទេ?

អាតៈ បាទ! ពីមុនធ្លាប់រាប់អានគ្នាដែរ។

បូលីៈ មានជាប់សាច់ឈាមទេ? មានជាប់បងប្អូនទេ?

អាតៈ  ខ្ញុំ

បូលីៈ  បាទ!

អាតៈ  បាទ! ជាប់ដែរ ពីមុនមក ។

បូលីៈ  ត្រូវជាយ៉ាងម៉េច?

អាតៈ  ជាប់ខាងប្រពន្ធ ជាប់ប្រពន្ធគាត់ ។

បូលីៈ  ខាងប្រពន្ធគាត់ហ៎?

អាតៈ  បាទ!

បូលីៈ  ប្រពន្ធគាត់ឈ្មោះ អីគេអ៊ឹ?

អាតៈ  ឈ្មោះសឿន ប្រពន្ធកែពក ។

បូលីៈ  ស្អីសឿនទៅ?

អាតៈ  ទេ! មិនចាំឈ្មោះទេប្អូន   ចាំតែកូនគាត់ទេ ។

បូលីៈ  បាទ! យាយសឿនអញ្ចឹងហ៎?

អាតៈ  យាយសឿនៗ ។

បូលីៈ  យាយនៅយាយទេ យាយសឿន?

អាតៈ  នៅអន្លង់វែងហ្នឹង ។

បូលីៈ  នៅអន្លង់វែង ។ នៅម្តុំណាអ៊ឹ?

អាតៈ  ម្តុំសាលាបង្រៀន កែងសាលាបង្រៀន ។

បូលីៈ  សាលា វិទ្យាល័យអន្លង់វែង?

អាតៈ  ខាងកើតហ្នឹង ជាប់មន្ទីរគណៈបក្សហ្នឹង តាមថ្នល់ជាតិហ្នឹង ។

បូលីៈ  អញ្ចឹងហ៎?

អាតៈ  បាទ!

បូលីៈ  ចាំមើល ខ្ញុំមានឱកាស ខ្ញុំទៅជួបគាត់បន្តិច ឈ្មោះ យាយសឿនណ៎?

អាតៈ  បាទ!

បូលីៈ  យាយសឿន ប្រពន្ធ កែ ពក នៅទល់មុខសាលាវិទ្យល័យអន្លង់វែង ។

អាតៈ  ទល់មុខអី នៅខាងកើតគណៈបក្សអញ្ចឹងហ្នឹងណា ។

បូលីៈ  ខាងកើតមន្ទីរបក្ស?

អាតៈ  បាទ! បើអញ្ចឹងទៅរកអាទល់មុខ ទៅចំកន្លែងឃ្លាំងសម្ភារនៃក៏ ភស្តុភាររបស់អគ្គបញ្ជាការ ។

បូលីៈ  មិនមែនយាយមឿន ប្រពន្ធតា ពេជ្រ ចៀមទេ?

អាតៈ  ទេ! យាយមឿនហ្នឹង គាត់នៅជ្រុងនេះ នៅជ្រុងគ្នានេះ ។

បូលីៈ  នៅក្បែរៗគ្នា?

អាតៈ  នៅក្បែរ ។

បូលីៈ  គាត់នៅជាមួយនរណា?

អាតៈ  នរណា?

បូលីៈ  យាយសឿនណា?

អាតៈ  យាយសឿន?

បូលីៈ  បាទ!

អាតៈ  ទេមិនដឹងនៅឯណា នៅជាមួយនរណាទេសព្វថ្ងៃ ។

បូលីៈ  គាត់មានកូនប៉ុន្មាននាក់អ៊ី?

អាតៈ  គាត់មិនដឹងជាមានកូនប៉ុន្មាននាក់ទេ!ភ្លេចបាត់ហើយ ចាំមិនបានអស់ទេ ។

បូលីៈ  កាលពីសម័យ តា ពក គាត់ធ្វើប្រធានភូមិភាគអញ្ចឹង យាយសឿន គាត់ធ្វើអី?

អាតៈ  ទេ! មិនដឹង ដូចជាអត់មាការងារអីទេ ។

បូលីៈ  កាន់តំបន់ កាន់អីទេកាលហ្នឹង? ប្រធាននារី ប្រធានអីទេ?

អាតៈ  អត់! អត់មានធ្វើអីទេ ។ គាត់ជាប្រពន្ធ ជា ចៀមហ្នឹង ប៉ុនជំនាន់នោះឥទ្ធិពលណាស់ប្អូន ។ ឧបមាថាប្តីធំ ប្រពន្ធក៏ធំដែរ ហើយគេគោរពតាមហ្នឹង ។ ប៉ុន្តែអត់មានតួនាទីអីទេ មិនមែនដូចបច្ចុប្បន្នណា ប្រពន្ធលោកនេះធ្វើចេះ ធ្វើចុះ! អត់មានធ្វើអីទេ ។ គណៈតំបន់គេផ្សេង អាហ្នឹងយើងនិយាយជាក់ស្តែងណា ។ គ្មានតួនាទីអី ភារកិច្ចអី កាកបាទអីៗ អត់ទេ ។

បូលីៈ  អត់មានទេ?

អាតៈ  បាទ! កិច្ចការនារីអីអត់មានទេ ។

បូលីៈ  មិនដូចឥលូវទេ?

អាតៈ  បាទ!

បូលីៈ  អ៊ឹ! នៅសាលារបស់អ៊ី នៅសាលាប៉ុណ្ណា ប៉ុន្មានអាគារ?

អាតៈ  សាលាហ្នឹង វា២ជាន់ ។

បូលីៈ  កំពស់២ជាន់ ។ ប៉ុន្មានបន្ទប់?

អាតៈ  អាគារ វាមានអាគារ ២អាគារ ។

បូលី៖ ២អគារ ។ ១អាគារមានប៉ុន្មានបន្ទប់ទៅអ៊ី?

អាត៖ ១អាគារមួយនោះគេហៅថា អាគារបច្ចេកទេស ។ អាគារបច្ចេកទេសនោះ គឺសម្រាប់យើងទៅពិសោធន៍កន្លែងផ្សេងៗកិច្ចការផ្សេងៗ រួចអាគារ១នោះទៀត អាគារសម្រាប់បើកវគ្គខាងទ្រឹស្តី ។

បូលី៖ ពិសោធន៍ដាក់ស្តែង និងទ្រឹស្តី?

អាត៖ បាទ! វាមាន៣ ។ ទី១គឺ សាលាបង្រៀនខាងទ្រឹស្តី ទី២គឺថាពិសោធន៍ដាក់ស្តែងខាងវិទ្យាសាស្ត្រ ទី៣គឺចុះដាក់ស្តែងធ្វើពលកម្ម ។

បូលី៖ ទ្រឹស្តី ពិសោធន៍ និងដាំដុះយកតែម្តង ។

អាត៖ ដាំដុះយកតែម្តង ដាក់ស្តែងតែម្តង ។

បូលី៖ ដាក់ស្តែងមែនទែនហ្នឹង ។

អាត៖ បាទ!

បូលី៖ ហើយគ្រូចិនគេនៅឯណាអ៊ី?

អាត៖ គ្រូចិនគេមានផ្ទះគេនៅ ។

បូលី៖ ជិតៗហ្នឹងដែរ ។

អាត៖ ផ្ទះគេទៅ ផ្ទះខ្ញុំអញ្ចឹង ១ជួរ ។

បូលី៖ ហើយគ្រូចិនហ្នឹង មានប្រពន្ធកូន?

អាត៖ អត់! ប្រពន្ធកូន គេអត់មានទេ ។

បូលី៖ មានគ្រូខ្មែរទេ?

អាត៖ គ្រូខ្មែរយើងអត់ទេ ។

បូលី៖ មានអ្នកបកប្រែ?

អាត៖ មានអ្នកបកប្រែ ។

បូលី៖ ហើយការហូបចុកគ្រូចិននឹង នរណាគេអ្នកគ្រប់គ្រង ។

អាត៖ អាហ្នឹងគេហៅភូមិភាគ ក្រុមពួកតាម៉ុក ។

បូលី៖ ពាយព្យ?

អាត៖ ពាយព្យបាទ!

បូលី៖ នរណាគេ មេគេនៅពាយព្យ?

អាត៖ តាម៉ុកហ្នឹងឯង ។

បូលីៈ តាម៉ុកក្រែងនៅនិរតីអ៊ី?

អាតៈ អត់ទេ! ក្រោយមកដកមកនៅហ្នឹង ។

បូលីៈ ក្រោយមកដកមកនៅពាយព្យ ។ តែមុនដឹបួងមក? មុនតាម៉ុកមក

អាតៈ មុនតាម៉ុកមកនែក៏! តាញឹម, រស់ញឹម ។

បូលីៈ រស់ ញឹម ឬញឹម រស់?

អាតៈ ទេ! ដូចជា រស់ ញឹម ទេ ។ គាត់ត្រូវជាជន្ទងរបស់ សោ ភឹម ។

បូលីៈ ជន្ទងរបស់សោ ភឹម?

អាតៈ បាទ!

បូលីៈ ចុះអនុរបស់តាញឹមនរណាគេ?

អាតៈ ស្គាល់គេមិនអស់ទេអូន ។ វាភ្លេចហើយកាលហ្នឹង កាលមុនស្គាល់ ទេឥលូវវាភ្លេច ។ កាលនោះស្គាល់ទាំងអស់ហ្នឹង ព្រោះខ្ញុំដឹកនាំធំដែរ វាស្គាល់គេអស់ប៉ុនវាភ្លេចអស់ទៅណា ។

បូលីៈ អ៊ីដែលឮសួរ គេហៅតាញឹម តាទះ តាទាត់ អីទេ បានន័យថាតែគាត់ឃើញ (ស្តាប់ពុំបាន) គាត់ទះគេចះ ទះស្មាណា ។ បើតាមួយទៀតឲ្យតែឃើញគេ គាត់ទាត់ចេះ ។ ដល់អញ្ចឹង គេហៅគាត់តែ តាទះ តាទាត់ ។

អាតៈ គាត់និយាយញាប់ ដាប់មាត់ពឹប១ ។

បូលីៈ ត្រដិត ឬក៏ញាប់?

អាតៈ អត់ត្រដិតទេ! គ្រាន់តែគាត់និយាយញាប់ញាប់ពឹប១រាងមិនមែនត្រដិត ។

បូលីៈ គាត់មនុស្សរូបរាងយ៉ាងម៉េច?

អាតៈ តាញឹម គាត់មនុស្សរូបរាង ធាត់ក្រអាញ ហើយខ្មៅស្រអែម ។

បូលីៈ ខ្មៅស្រអែម?

អាតៈ បាទ!

បូលីៈ ខ្ពស់ ឬទាបអ៊ី?

អាតៈ ទេ! រាងមធ្យម ។

បូលីៈ មួយល្មម?

អាតៈ បាទ! មិនខ្ពស់ មិនអី ។

បូលីៈ ប្រពន្ធគាត់ឈ្មោះអីពីមុន?

អាតៈ ភ្លេចដែរបាត់ហើយ មិនស្គាល់ទេ ស្គាល់តែគាញឹមទេ។ និយាយមិនស្គាល់ប្រពន្ធអីគ្រាន់ តែឥលូវភ្លេចទៅមិនដឹងឈ្មោះអី។ ស្គាល់ទាំងកូនអីទៀត ប៉ុនភ្លេចអស់ហើយ។

បូលីៈ ហើយគ្រូចិនហ្នឹងដែលមកនៅបង្រៀនហ្នឹង គាត់មកនៅឆ្នាំនៅ៣ឆ្នាំ ឬគាត់ដោះដូរគ្នា ចិនខ្មែរៗ?

អាតៈ គាត់នៅជាប់។

បូលីៈ គាត់នៅជាប់តែម្តង?

អាតៈ គាត់នៅជាប់។ មានចិនគេរៀបចំជាកម្មុយនីស គេមានប្រព័ន្ធរបស់គេ គេមានប្រធានរបស់គេអ្នកគ្រប់គ្រង ប្រធានអនុសេនាតូចគេមួយៗគ្រប់គ្រង។

បូលីៈ អ៊ូ! មកមួយអនុសេនាតូចតែម្តងអី?

អាតៈ ដូចថាប្រធានអនុសនាតូចគេមានគ្នា៣០នាក់អញ្ចឹង ប្រធានគេមួយគេគ្រប់គ្រង។

បូលីៈ ឈ្មោះអីគេប្រធានអី?

អាតៈ តាភឹង! ស្លាប់បាត់ហើយ។

បូលីៈ ប៉ុនគាត់មិនមែននៅស្រុកខ្មែរណាអី?

អាតៈ ហ៎! គាត់ទៅស្រុកចិនហើយ គាត់ស្លាប់ គាត់ចាស់តាំងពីជំនាន់នោះទៅហើយ ស្លាប់បាត់ហើយជំនាន់នោះមិនរស់ទេ។

បូលីៈ ប៉ុនគាត់មិនមែនស្លាប់នៅស្រុកខ្មែរណាអី?

អាតៈ ហ៎! គាត់ទៅស្រុកចិនហើយ ប៉ុនគាត់ស្លាប់ គាត់ចាស់តាំងពីជំនាន់នោះទៅហើយ។

បូលីៈ គាត់ចាស់ហើយណ៎?

អាតៈ ចាស់ហើយ! តាំងពីខ្ញុំនៅក្មេងៗនោះ កោងហើយ។

បូលីៈ ហ៊ូ! តាភឹង កោងហើយ។ ប៉ុនតាភឹងហ្នឹង ជាអ្នកគ្រប់គ្រងទាំងអស់នៅហ្នឹង?

អាតៈ បាទ! មានរបបគេត្រឹមត្រូវណាស់។

បូលីៈ ពីណាគេឲ្យ?

អាតៈ ចិន! ១អាទិត្យគេហៅប្រជុំ ១អាទិត្យទៅប្រជុំ។ ហើយល្ងាចឡើងគឺ ពេលគេថាក្រោយពីហូបបាយ ហូបអីហើយគឺត្រូវជួបជុំគ្នា ទាំង៣០នាក់ គឺស្តាប់។ ជាអចិន្ត្រៃតែម្តង។

បូលីៈ ស្តាប់ជុំគ្នាតែម្តង?

អាតៈ បាទ!ស្តាប់ជុំគ្នាតែម្តង ដាក់ប្រជុំកណ្តាលវាល។

បូលីៈ មិនមែនទៅដេកបន្ទប់រាងខ្លួន ហើយស្តាប់រាងខ្លួនទេ?

អាត៖ អត់ទេ! ស្ដាប់ជុំ ។

បូលី៖ អឺ មានដែលចូលរួមប្រជុំហ្នឹងគេទេ?

អាត៖ ប្រជុំជាមួយចិនណា ។

បូលី៖ ចិនហ៎?

អាត៖ ចិនគេមិនដែលហៅយើងប្រជុំ ព្រោះផ្ទៃក្នុងគេ គេមិនដែលហៅយើងប្រជុំ ។ កិច្ចការប្រជុំអី ដែលមានកិច្ចការអីទាក់ទង ទៅហ្នឹងបច្ចេកទេស យើងកោះអញ្ជើញគេមកប្រជុំ ឲ្យគេបំភ្លឺ បច្ចេកទេសណា ដូចជាសិក្ខាកាមរៀនហ្នឹង សុំឲ្យគេបញ្ចេញមតិទៅ ឆ្ងល់រឿងអីៗ ឧបមាថា ឆ្ងល់បច្ចេកទេសណា គេហៅបច្ចេកទេសហ្នឹងមក ព្រោះបច្ចេកទេសមួយៗអញ្ចឹង ។ ១ ឬក៏២ នាក់ អត់មានអ្នកនេះទៅរៀនអានោះ ហើយអានោះអត់មានទៅរៀនអានេះ អត់ទេ ។ ឧបមា ថា គ្រឿងខ្មៅគេធ្វើតែខ្មៅទេ អត់មានចេះស្អីទៀតទេ ។

បូលី៖ ត្រូវជំនាញ ។

អាត៖ ដូចថាជំនាញថាខ្មៅទៅធ្វើកង់ ទៅធ្វើឯណា! គឺអត់ទេ ។ អាបច្ចេកទេសរៀនដូចគ្នា រៀនមួយ ថតៗអញ្ចឹង ។

បូលី៖ ចុះអ្នកបកប្រែភាសាខ្មែរពីណាគេ?

អាត៖ ឈ្មោះ ចិន ។

បូលី៖ ឈ្មោះ ចិនដែរ?

អាត៖ ខ្មែរយើងនៅបាត់ដំបង ។

បូលី៖ ប៉ុន្មានអ្នកបកប្រែអឺ?

អាត៖ អ្នកបកប្រែតែ២នាក់ទេ ។

បូលី៖ តែ២នាក់ទេណ៎?

អាត៖ បាទ!

បូលី៖ ប៉ុន្តែ២នាក់ហ្នឹងនៅបាត់ដំបងទាំងអស់?

អាត៖ បាត់ដំបងទាំងអស់ ។

បូលី៖ ខ្មែរកាត់ចិន?

អាត៖ ខ្មែរកាត់ចិន ។ អាហ្នឹងខ្មែរស្រុកយើង កាលពីជំនាន់សីហនុមុន គេបើកជាសាលាបង្រៀនភាសា ចិនណា ។ អញ្ចឹងគេកូនចិន គេបានរៀនភាសាចិន គេចេះទៅ ។ ដល់ស្រុកអញ្ចឹង ក៏គេមាន ជំនាញ គេស្រាវជ្រាវគេហៅបម្រើការងារ ។

បូលី៖ មានគេចោទថាជនក្បត់ជនអីនៅក្នុងសាលាហ្នឹង មានចាប់អីទេណ៎ អ្នកធ្វើការនៅក្នុងសាលាគេចាប់អីទេ?

អាត៖ មានតា!

បូលី៖ គេចោទថាម៉េច?

អាត៖ គេចោទថានៅជិតនាន់ខ្ញុំគ្រប់គ្រងហ្នឹង គេហៅថាមជ្ឈិម គេហៅថាក្រសួងសន្តិសុខរបស់មជ្ឈិមហ្នឹង ។ ទៅសុំយកមនុស្ស ទៅសុំយកអានោះ ឈ្មោះ"ក" ឈ្មោះ"ខ" ប៉ុនខ្ញុំមិនឲ្យ ។

បូលី៖ អត់ឲ្យយ៉ាងម៉េចទៅអ៊ឺ គេមិនខឹងទេអ៊ឺ អ៊ឺអត់ឲ្យអញ្ចឹង?

អាត៖ ខ្ញុំមិនឲ្យ គេខឹងៗទៅ ខ្ញុំថាមិនឲ្យទេ អ្នកឯងចង់យ៉ាងម៉េចក៏ដោយ កូនសិស្សខ្ញុំកំពង់រៀន ។ ជួនកាលម៉ោង៦យប់មក បើកឡានខុបមក តែខ្ញុំមានសន្តិសុខ សម្រាប់ការពារខ្ញុំ និងបរទេស ។

បូលី៖ ប៉ុន្មាននាក់អ៊ឺសន្តិសុខ?

អាត៖ ៦០នាក់ ។

បូលី៖ ច្រើនដែរ?

អាត៖ បាទ! យាមយើងជុំវិញទាំងអស់ ។ ហើយ(ស្តាប់ពុំបាន) តែមួយទេ ។ មានប៉ុស្តិ៍កុងត្រូលអីមកត្រង់ តែមកខ្ញុំប្រាប់ហើយថាពេលផុតពីម៉ោង៧ មិនបាច់មកទេ ។ ណាមានការអី ក៏មិនឲ្យចូលទេ យើងមិនឲ្យចូលទេ ។

បូលី៖ អ៊ឺថាមានអ្នកខ្លះមកទាំងម៉ោង១យប់ឡើង?

អាត៖ បាទ!

បូលី៖ មករកអីអ៊ឺ?

អាត៖ មកសុំមនុស្សហ្នឹងណា ។ ពួកយើងមិនឲ្យចូល គេត្រលប់មកវិញ ។ អ្នកខ្លះតែអត់មានដូវការទេ ដូចគេអត់ថាមានគំនុំ មានអីអ្នកស្រុក អ្នកភូមិគេមក ។ វាអញ្ចឹងណាមនុស្ស បេះតែមានសិទ្ធយកមនុស្សទៅវាយចោល នេះនិយាយការពិតណាអូន ដូចថាខ្លួនពីមុនមកធ្លាប់មានគំនុំ យើងបានតួនាទីតំណែង បច្ចុប្បន្នអី ជាគណៈតំបន់ អនុអី សមាជិកប្រធានមន្ទីរអីក៏ឆ្លៀតឱកាសអីក៏មកយក ឃើញសភាពការណ៍ច្របូកច្របល់ មនុស្សអញ្ចឹង ព្រោះកាលហ្នឹងវាមានអាច្បាប់ទម្លាប់អីណាអត់ទេ ។ អញ្ចឹងបានមនុស្សទៅតាអាណាធិបតេយ្យ ប៉ុន្តែដល់យើងរឹងដែរណាអត់ហ៊ាន ។ ពួកខ្ញុំ២ ទៅ៣នាក់ អត់មានទៅ(ស្តាប់ពុំបាន) ខ្ញុំអត់ឲ្យ មជ្ឈិមណាមក ក៏មិនឲ្យក៏អត់ឲ្យដែរ ។

បូលី៖ អ៊ឺអត់ខ្លាចតា ពក ថាឲ្យទេ?

អាតៈ  អត់ទេ! អត់មានតា ពក ទេ ៗ ពេលនោះតាពកគ្រប់គ្រង ៗ តា ពក គ្រាន់តែមានសិទ្ធគ្រប់គ្រងបញ្ជូនគេ ទៅដល់កន្លែងហ្នឹងតាម៉ុក មជ្ឈិមគេគ្រប់គ្រងផ្ទាល់កាលនោះ ៗ ដល់តាម៉ុក ដល់ថ្នាក់មជ្ឈិម ៗ

បូលី៖  តាម៉ុក អ្នកបញ្ជាឲ្យចាប់វិញ?

អាតៈ  តាម៉ុក អ្នកបញ្ជា ខ្ញុំត្រូវតែទៅជួបគាត់ ៗ បាទ! អត់ទាន់ឲ្យចាប់ទេ ខ្ញុំទៅនិយាយសិន ទៅសួរហេតុផលសិន បាទ! មនុស្សហ្នឹងយ៉ាងម៉េច បានបញ្ជាឲ្យចាប់ ទៅនិយាយសិន ជូនការវាថាហ៎ប្រវត្តិពីណាមក ខ្ញុំថាតាឯងចេះតែជឿគេប្រវត្តិពីណាមកមនុស្សកុំពង់តែរៀន ទៅចាប់យ៉ាងម៉េច ៗ រៀនមិនទាន់ចប់ផង ទៅមានប្រវត្តិពីណាមក ៗ បាទ! គាត់ថាហ៎ អញ្ចឹងឲ្យវានៅរៀនទៅ ឃើញទេ! បើតាមអាពួកនោះវាយកទៅបាត់ ៗ យើងតស៊ូដើម្បីការពារ កូនសិស្សរបស់យើងណា ៗ អត់មាលខិតមួយទេ មួយកើតសភាពការណ៍រហូតដល់ទៅដល់យួនចូលមក ៗ

បូលី៖  អញ្ចឹង អ៊ីការពារបានច្រើនណាស់អ៊ី?

អាតៈ  បាទ! អត់មាននថាអីទេខ្ញុំ ៗ

បូលី៖  អ៊ីអត់ខ្លាចតាម៉ុកទេ? គេខ្លាចគ្រប់គ្នា?

អាតៈ  អត់ខ្លាចទេ ៗ

បូលី៖  តាម៉ុកកាចណាស់ណា?

អាតៈ  កាច! កាចទទួលស្គាល់ថាកាច ៗ ប៉ុន្តែយើងត្រូវតែរកចំណុចត្រូវនិយាយជាមួយគាត់ ឧបមាថា ដូចខ្ញុំនិយាយមុិញថា មនុស្សម៉ោង១ ម៉ោងអីមកចាប់អញ្ចឹង ហើយថាមានការអី ថាតាម៉ុក មកបញ្ជាឲ្យឲ្យចាប់ ៗ ខ្ញុំថាបើតាម៉ុក បញ្ជាមកចាប់ ចាំព្រឹកសិន យប់ចេះអញមិនឲ្យទៅទេ ឯងប្រាប់អាមកយកវិញឲ្យមកទៅ! ទៅវិញបាត់ទៅ ដល់មកព្រឹកខ្ញុំជួបតា ជួបតាខ្ញុំសួរតាមុនស្សហ្នឹងយ៉ាងម៉េច បានឲ្យគេមកចាប់ទាំងយប់អញ្ចឹង វាយ៉ាងម៉េច! តាថាអញមានឲ្យវាទៅយប់ឯណា មនុស្សហ្នឹង វាមានប្រវត្តិចេះៗ ស្អីក៏ដោយមនុស្សកំពង់តែរៀន អត់ត្រូវការឲ្យមនុស្សទៅចាប់យកទេ ទៅហៅអាហ្នឹងមកស្ដីឲ្យទៀត ហែងទៅចាប់គេយប់ អាណាអាណី អាណាឲ្យពួកឯងទៅចាប់ ៗ បើយើងទាន់ដែរ យើងខ្លាចគេដែរ គេយកកូនចៅទៅបាត់ ការពិតវាចង់ចាប់ ៗ

បូលី៖  ហើយតាម៉ុកគាត់នៅមុំណា កន្លែងធ្វើការគាត់នៅភូមិភាគ ភូមិអី?

អាតៈ  គាត់នៅជិតព្រះលានយន្តហោះ ៗ

បូលី៖  ជិតព្រលានយន្តហោះ អាផ្ទះទឹករលកមែនទេ?

អាត: បាទ! អាខាងនេះថ្នល់ ។

បូលី: ខាងនេះថ្នល់ណ៎ អឺណ៎?

អាត: បាទ! ខាងនេះថ្នល់ ជិតព្រលានយន្តហោះ ។

បូលី: អាហ្នឹងសាលកវិទ្យាល័យបាត់ដំបងចាស់មែនទេ?

អាត: បាទ! ហ្នឹងហើយ ។

បូលី: កន្លែងតាញឹមដែរ?

អាត: បាទ!

បូលី: ពេលគេចាប់តាញឹមទៅ បានតាម៉ុក គាត់មកដែរណ៎?

អាត: បាទ! តាម៉ុក គាត់មក ។

បូលី: អញ្ចឹងអឹនៅរហូតដល់?

អាត: យួនវាយចូល ។

បូលី: យួនវាយចូល ។

អាត: វាយចូលហើយ ចូលដល់បាត់ដំបងទៀត បានខ្ញុំចេញ ។

បូលី: ចូលដល់បាត់ដំបងទៀត?

អាត: បាទ!

បូលី: អឹចាំថ្ងៃទេ?

អាត: ទេ! ដូចភ្លេចហើយ ។

បូលី: ពីមុនយួនចូលភ្នំពេញថ្ងៃទី៧មករា ៧៩ណា ក្រោយ៧មករា ឬមុន៧មករា?

អាត: ប្រហែលជាចាំមើល អាចខែច្រូត ខែប្រមូលផល ខែបោកបែន(ស្តាប់ពុំបាន) ។

បូលី: ខែហ្នឹងហើយ ខែ១១ ខែ១២ ខែ១?

អាត: ប្រហែលខ្ទង់ខែ១ ។

បូលី: ខែ១?

អាត: បាទ! ខែគេប្រមូលផលអីស្រុកក្រោមណា មិនមែនដូចស្រុកនេះ ។

បូលី: ស្រុកនេះ?

អាត: ស្រុកនេះគេប្រមូលផលហើយ ។ បាទ! ខែនេះអស់ហើយ នៅនោះមិនទាន់ច្រូតផងហ្នឹង ខ្លះច្រូតអស់ហើយ ដាក់ការ៉ុងអស់ហើយ បើយើងអីក្រោមនោះគេមិនទាន់ច្រូតផងនោះ អាខ្លះស្រូវទើបតែចេញ ។

បូលីៈ យើងនោះខែ១២ ខែ១ បានគេឡើងគោមាស ។

អាតៈ អញ្ចឹងយើងអាចសន្និដ្ឋានថាខែ១ចុះ ប៉ុនមិនដឹងចាំថ្ងៃណាទេ តាមខែហ្នឹងចុះ តាមខ្ញុំចាំណា ។

បូលីៈ ម៉េចបានយើងវាយចាញ់យួនណ៎អ៊ី?

អាតៈ អាហ្នឹងមកពី តាមទស្សនៈខ្ញុំយល់គឺ ខ្ញុំក៏មិនដឹងដែលណាអូនជំនាន់នោះ អាហ្នឹងយើងនិយាយតាមដឹង តាមមើលវាមិនដឹងជាមូលហេតុអីយ៉ាងណាដែរ ព្រោះខ្ញុំវាអត់មានកងទ័ពទេ ពេលហ្នឹងវាអត់មានកងទ័ពនៅក្នុងដៃទេ វាអស់ ។ ហើយកិច្ចការនៅក្នុងកងទ័ព ក៏គេអត់ដែរហៅខ្ញុំទៅដែរ ព្រោះយើងស៊ីវិលដែរហើយ ចូលខាងផ្នែកស៊ីវិលហើយ ។

បូលីៈ ខាងសតិអប់រំ ។

អាតៈ ផ្នែកសាលាបច្ចេកទេសកសិកម្ម ធ្វើស្រែ ធ្វើអី វាលែងកើតជាកងទ័ពអីហើយ ។

បូលីៈ ចុះកងទ័ពអ៊ីហ្នឹង ៦០នាក់ហ្នឹង គ្រាន់តែសម្រាប់ការពារទេ?

អាតៈ បាទ! កងទ័ពហ្នឹងចេះ កងទ័ពដូចថាយើងសុំពីភូមិភាគមកណា ។ ភូមិភាគមក ភូមិភាគគេយកតាមស្រុកមួយៗយកមក ។ ប៉ុនមានគេ គេមកគ្រប់គ្រងផ្សេងទៀត ។

បូលីៈ មិនមែនអ៊ីគ្រប់គ្រងទេណ៎?

អាតៈ មិនមែនខ្ញុំគ្រប់គ្រងទេ ប៉ុន្តែចូលមកដល់កន្លែងខ្ញុំ ខ្ញុំជាមេបញ្ជាការ! អ្នកណាក៏ដោយឲ្យតែចូលមកកន្លែងខ្ញុំ គឺខ្ញុំជាមេបញ្ជាការ ។ ពេលអ្នកឯងត្រូវទៅប្រជុំជាមួយមេអ្នកឯងទៅៗ! ប៉ុន្តែពេលចូលមកក្នុងហ្នឹង គឺខ្ញុំមានសិទ្ធជាមេបញ្ជាការ ហៅអ្នកឯងប្រជុំធ្វើការទាំងអស់ ដាក់ផែនការឲ្យទាំងអស់ ។

បូលីៈ អ៊ីស្គាល់អនុរបស់តាម៉ុកទេពេលហ្នឹង? តាម៉ុកមេភូមិភាគណា?

អាតៈ ដឹងអីទេវ៉ៃ ភ្លេចហើយ ។ ឈ្មោះស្អីគេទេ អាគាត់ហ្នឹង ប៉ុនជំនាន់នោះគេបំបាត់អស់ហើយ ដូចថាយើងមិនហ៊ាននិយាយភាសាអ៊ីច្រើនលោកគ្រូ ពេលនោះខ្ញុំចាំដែរ គេប្រាប់ដែរ ប៉ុនដូចថាវាមិនសូវជិតស្និតជាមួយគ្នាណា ដល់អញ្ចឹងទៅវាមិនសូវបានចាំ ។

បូលីៈ ដល់ពេលតាម៉ុកមកដល់និរតីនរណាគេមើលការខុសត្រូវ?

អាតៈ និរតី ខ្ញុំក៏មិនសូវដឹងរឿង ។

បូលីៈ បាទ! ឆ្ងាយ ។

អាតៈ ដឹងតែអ្នកគ្រប់គ្រងផ្ទាល់ៗ ។

បូលីៈ ខ្ញុំសូមសួរអ៊ី ពេលវៀតណាមវាយចូលដំបូង ពេលវៀតណាមវាយចូលអ៊ីរត់ចូលទៅខាងណា?

អាតៈ ខ្ញុំទៅខាងលិចកម្ពុជា ទៅខាងព្រំដែន ។

បូលីៈ ទៅព្រំដែន?

អាតៈ បាទ!

បូលីៈ ទៅព្រំដែនទៅតាមច្រកខាងណាអឺ?

អាតៈ ច្រកបវឡាន ។

បូលីៈ ច្រកបវឡាន?

អាតៈ បាទ! សាន់ចៅ ។

បូលីៈ សាន់ចៅ! បើយើងគិតពីដីខ្មែរទល់មុខអីគេ?

អាតៈ ទល់មុខខេត្តត្រាត ។

បូលីៈ ទល់មុខខេត្តត្រាត អញ្ចឹងយើងនៅទល់មុខកោះកុង ។ កោះកុង ឬពោធិ៍សាត់?

អាតៈ កោះកុង ។

បូលីៈ មិនមែនពោធិ៍សាត់ទេ?

អាតៈ មិនមែនទេ! នៅជាប់គ្នា អាហ្នឹងជួរភ្នំក្រវាញ ជួរភ្នំ ប៉ៃលិនជាប់គ្នាមក ចន្លោះប៉ៃលិន!

បូលីៈ ភ្នំក្រវាញរត់ពីណាមក?

អាតៈ ភ្នំក្រវាញរត់ពីកោះកុងមក ។

បូលីៈ នេះកោះកុងមកនេះ ។

អាតៈ នេះជួរភ្នំប្អូន ធំណាស់ មិនមែនភ្នំតិចទេ ភ្នំរាប់រយ រាប់ពាន់មកណា៎ ភ្នំតូចភ្នំធំណាស់ ត្រង់គូសគំនូរ ឡើងទៅដល់លើអញ្ចឹង ខ្ពងមានតែ២ម៉ែត្រ ចុះទៀតចុះទៅមួយព្រឹកណាទម្រាំមកដល់អូរក្រោម ឡើងមួយទៀត១ព្រឹកទៀត ដល់កំពូលលើ មើលទៅឃើញប្រជឹកគ្នាតែម្ដង ។

បូលីៈ ឃើញដូចសមុទ្រអញ្ចឹង?

អាតៈ ទេ! មើលទៅជាប់ដូចដំបូកអញ្ចឹង ។ បានដូចកំពូលដំបូកជិតគ្នាតែម្ដងនេះ នេះអានេះភូមិសាស្ត្រ ធំណាស់ ។

បូលីៈ អញ្ចឹងបងរត់ពីបាត់ដំបងមក ពីថ្មគោលមក មកកោះកុងចេះ?

អាតៈ បាទ! មកចេះៗ មកតំបន់នេះ មកម្ដុំនេះ ។

បូលីៈ អានេះពោធិ៍សាត់ អានេះវាលវែង ។

អាតៈ អានេះបាត់ដំបង ។

បូលីៈ ភ្នំក្បាលឡាន ច្រកថ្មដា?

អាតៈ បាទ! ឯណាបាត់ដំបង? អានេះកន្លែងអី?

បូលី៖ អានេះខាងលិច អានេះសំឡូត ។

អាត៖ អានេះសំឡូតនៅសំឡូតហ្នឹង ។

បូលី៖ សំឡូតនៅហ្នឹងតែម្ដង?

អាត៖ បាទ! ច្រកសំឡូតនៅខាងលិចសំឡូតវានេះៗ នៅច្រកនេហ អានេះភ្នំ៩០ ក្រឡា៦៩ អានេះ ។ អានេះប៉ៃ លិន អានេះ៦៩ ។

បូលី៖ ក្រលា៦៩ហេ៎?

អាត៖ បាទ!

បូលី៖ បន្ទោលព្រំដែនអីអ៊ី?

អាត៖ ព្រំដែនហើយហ្នឹង រហូតមក ។ អានេះបានមកហ្នឹងថ្មដា ថ្មអី ។

បូលី៖ បាទ! អាថ្មដា បន្ទាប់ពីថ្មដាមក ពោធិ៍សាត់?

អាត៖ បាទ! ថ្មដា មកខេត្តពោធិ៍សាត់ ។

បូលី៖ ភ្នំក្បាលឡាន?

អាត៖ ភ្នំក្បាលឡាន ។ មកហ្នឹង មកកោះកុង ប៉ុល ពតនៅនេះ ។

បូលី៖ គាត់នៅមន្ទីរក-១៨?

អាត៖ បាទ! ក-១៨ ។

បូលី៖ អ៊ំនៅ ក-១៨ដែរអត់ទេ?

អាត៖ អត់ទេ!

បូលី៖ អ៊ំនៅម្តុំសំឡូតអញ្ចឹង?

អាត៖ បាទ! ម្តុំសំឡូត ។

បូលី៖ និយាយទៅពេល យួនវាយចូលមកហ្នឹងតាម៉ុកដែលនៅបាត់ដំបងហ្នឹង គាត់នាំកម្លាំងគាត់មកដែរ?

អាត៖ បាទ!

បូលី៖ មកសំឡូតដែរ ឬមកណា?

អាត៖ ដល់ពេលមុនហ្នឹងណា និយាយគាត់ប្អូនឯង មុនហ្នឹងគឺថា(ស្តាប់ពុំបាន) ក្រោយពីយួនចូលមកគាត់ធ្វើការជាមួយថ្នាក់លើហ្នឹងទៅ ដល់យួនចូលមកគាត់អាចបែងចែកការងារគាត់ទៅ ប៉ុន្តែតាម៉ុកត្រូវតែមក១០០១វិញ, ច្រក១០០១ យើងវិញ ។

បូលី៖ បាទ! នេះ១០០១ ។

អាត: គាត់ប្រចាំការនៅហ្នឹង ។

បូលី: ពូថាតាម៉ុក គាត់មកហ្នឹងច្រើន ។ ឥលូវខ្ញុំឧទាហរណ៍ឲ្យអ៊ំស្តាប់ អ្នកដែលនៅខាងស្ទឹងត្រែង ក្រចេះអីហ្នឹងពេលដែលយួនវាយចូលនាំគ្នារត់ឡើង ១០០១ មកមុំពណាអ៊ី?

អាត: បាទ! មកមុំ៣ ។

បូលី: ខ្ញុំចង់ដឹងថាប្រជាជននៅបាត់ដំបង និងពោធិ៍សាត់ពេលដែលវៀតណាមវាយចូលមក តើមានរត់ទាំងអស់គ្នានៅមុំណាឲ្យដូច១០០១ទេ? គេរត់ទៅមុំណា?

អាត: មុំឡាក់៧០ និងឡាក់៦៩ ។

បូលី: ឡាក់៧០ និងឡាក់៦៩ចន្លោះគ្នា១គីឡូដឺ ប៉ុក៏ប៉ុន្មាន?

អាត: វាបើផ្លូវវាប្រហែលជា២គីឡូ ។

បូលី: ២គីឡូ ពីគ្នា?

អាត: ២គីឡូ ពីគ្នា ត្រង់ណាប៉ុនបើត្រង់ទេវាប្រហែល ២ទៅ៣,៤គីឡូបើសិនជាមានក្រលុកក្រលាក់អីបើយើងត្រង់អីប្រហែលជា២គីឡូកន្លះអី ។

បូលី: ២គីឡូកន្លះ! ឡាក់៦៩ និងឡាក់៧០ហ្នឹងនៅក្នុងភូមិសាស្ត្រអើស្រុកអីរបស់ខ្មែរ សំឡូត ប៉ុក៏ប៉ៃលិន?

អាត: ស្រុកសំឡូតបាទ! ស្រុកសំឡូតទាំងពីរ ។

បូលី: ស្រុកសំឡូតទាំង២ហ៎អ៊ី?

អាត: បាទ! ស្រុកសំឡូត ។ ឡាក់៧០ និងឡាក់៦៩ ។

បូលី: អញ្ចឹង ខ្ញុំអាចនិយាយចេះបានទេអ៊ំ ខ្ញុំអាចនិយាយថាកម្មាភិបាលកងទ័ព និងប្រជាជនគ្រួសាររបស់កងទ័ពខ្មែរក្រហមនៅខេត្តបាត់ដំបង ពេលដែលវៀតណាមវាយចូលនាំគ្នារត់មកឡាក់៦៩ និងឡាក់៧០តាមបណ្តោយព្រំដែនខ្មែរថៃ ។

អាត: ខ្ញុំកាត់ប្រសាសន៍ប្អូនឯងតិចចុះ អានេះគឺថាផ្នែកនេះ គឺមកមួយភាគទេណាប្អូនប៉ុនមួយភាគទៀត គឺអាចទៅខាងប៉ៃលិន ទៅខាងបង្រៀន ទៅខាងអូរជ្រៅ ទៅខាងនោះ ។

បូលី: ទៅខាងម៉ាឡៃ?

អាត: បាទ! អានេះតែ១ភាគទេ ។

បូលី: ម៉ាឡៃប៉ោយប៉ែត?

អាតៈ បាទ! ម៉ាឡៃប៉ោយប៉ែតហ្នឹង ។ ភ្នំពេញយើងហ្នឹង ភាគច្រើនទៅខាងហ្នឹង បាទពីភ្នំពេញអីមក អ្នកដែលមកតាមផ្លូវទេះភ្លើងយើងហ្នឹង គឺភាគច្រើនទៅខាងហ្នឹង ខាងម៉ាឡៃ ។

បូលីៈ អញ្ចឹង បានន័យថាអ្នកភ្នំពេញ ។

អាតៈ អ្នកបាត់ដំបង ខ្លះ អ្នកសៀមរាប ។

បូលីៈ អ្នកបាត់ដំបង ខ្លះ អ្នកសៀមរាប?

អាតៈ អ្នកខេត្តពីណាៗភាគច្រើនទៅតែហ្នឹង ។

បូលីៈ ពោធិ៍សាត់អីហ្នឹង ទាំងអស់តាំងពីស្វាយរៀង ទាំងខេត្តអី?

អាតៈ បាទ! ភាគចើនទៅខាងហ្នឹង ។

បូលីៈ នាំគារត់មខាងលិច មកខាងប៉ោយប៉ែត អូរជ្រៅ ម៉ាឡៃ កម្រៀង ភ្នំព្រឹក្ស សំពៅលូន ប៉ៃលិនសំលូត កោះកុង គឺវាយបាយ៉ាយមហ្នឹង ។

អាតៈ វាយប៉ាយតាមហ្នឹង ចូលព្រំដែន ។

បូលីៈ ប៉ុន្តែអ្នកដែលនៅខាងត្បូង សាន តាមដែលខ្ញុំដឹង ខ្ញុំសម្ភាសន៍អ៊ំ សារឿនមរុលមិញអ៊ំ សា រឿន ក្រុមប្រឹក្សាស្រុកដែរហ្នឹងណា៎ គាត់ថា ក្រចេះ, កំពង់ចាម, ស្ទឹងត្រែង, មណ្ឌលគិរី, រតនៈគិរី, ព្រះវិហារ គឺនាំគ្នារត់ទៅ១០០១ ។ នៅក្នុង១០០១ ពេលដែល មកជុំគ្នា កម្លាំងហើយ បានរៀបចមកម្លាំងចុះមកវិញ ចុះមកធ្វើការតាមក្នុងណា បាទ! មកចលនាប្រជាជន មកវាយ មកអញ្ចឹងទៅណា បែកគ្នាទៅវិញ ប៉ុន្តែអ្នកបាយ់ដំបងនាំគ្នា និយាយរួមវាមិនមែនមក ទាំង ដុល បាត់ដំបងទាំងមូលមកសំឡូតនោះទេ បានន័យថាក្រុមអ៊ំមកសំឡូតនេះអញ្ចឹងទៅ ។ អាច ថាក្រុមអ្នកផ្សេងគេទៅខាងអូរជ្រៅ ប៉ោយប៉ែតអញ្ចឹងទេ ។ អ្នកខ្លះក៏គេទៅខាងភូមិដូង, ខាង សាស្តា ខាងខាប៊ីនអីអញ្ចឹង នៅកម្រៀង, ភ្នំព្រឹកអីអញ្ចឹងទៅ មិនអញ្ចឹងអ៊ំហេ៎?

អាតៈ បាទ! ព្រោះវាភូមិសាស្ត្រវាខុសគ្នា ភូមិសាស្ត្រយើងខាងកើតនោះ រតនៈគិរី មណ្ឌលគិរីហ្នឹង ភូមិសាស្ត្រជាប់ជាមួយយួន អញ្ចឹងភូមិសាស្ត្រវាខុសពីនេះ ។ ឯខាងនេះភូមិសាស្ត្រវាជាប់ ព្រំដែនបាត់ដំបងនេះណា៎ បាទ! ជាប់ព្រំដែនសៀម អញ្ចឹងវាមានអំណោយផលសន្តិសុខរបស់ បងប្អូន យើងនៅនេះ ។ ហើយជាប់អន្តរជាតិអីវាទំនាក់ទំនង ។

បូលីៈ ឮសូរថាអ្នកខាងកំពត ខាងតាកែវអី នៅកន្ទែងភ្នំដំរីរមៀល ហើយបាននាំគ្នារត់សរសៀរៗមក កាត់ខាងកំពង់ស្ពឺមកចាក់មកកោះកុង មកពោធិ៍សាត់ ។ អ្នកនៅខាងកំពង់សោម ឆ្លងទូកមក កោះកុង ជិះកបាល់មកឆ្លងទូកនៅកោះកុង ហើយមកជុំគ្នានៅកោះកុង អ្នកខ្លះមកជុំគ្នានៅ ខាងម៉ាឡៃ ។

អាតៈ ហើយខ្ញុំនេះផ្ដុំតែ២កន្លែងទេ ផ្ដុំនៅជំរុំ៧០ ហើយបានរៀបចំកម្លាំងទៅធ្វើការចលនាប្រជាជន ដូចគ្នា ។

បូលីៈ ដូចគ្នាហ្នឹងតំបន់១០០១ដែរ?

អាតៈ បាទ! ដូចគ្នា ។

បូលីៈ អញ្ចឹងតាម៉ុកលែងនៅនេះហើយ?

អាតៈ លែងនៅនេះហើយ ។

បូលីៈ គាត់លែងនៅសំឡូតហើយ ហើយទៅ១០០១ដើម្បីរៀបចំកម្លាំង ហើយក្រោយមកបានរៀប នៅ១០០៣?

អាតៈ បាទ!

បូលីៈ ទុក១០០១ ឲ្យសុន សេននៅ?

អាតៈ បាទ!

បូលីៈ អឹមានបានដឹងពីវត្តមានរបស់សុនសេននៅ១០០១ទេ?

អាតៈ ខ្ញុំដឹងមិនច្បាស់ទេគ្រូ?

បូលីៈ ខាងនេះអត់ច្បាស់ទេអឹ?

អាតៈ អត់ច្បាស់ ។

បូលីៈ បើខាងនេះអឹច្បាស់ជាង?

អាតៈ បើខាងនេះច្បាស់ជាង ច្បាស់ម្ដុំឡាក់៧០ ឡាក់៧, ៦៩ ។

បូលីៈ អញ្ចឹងខ្ញុំសូមលម្អិតអាកន្លែងនេះទេអឹអា៧៩ណា៎ ខាងសំឡូតហ្នឹង ។ អ្នកណាជាអ្នកគ្រប់គ្រងធំ?

អាតៈ ឈ្មោះ ម៉ង់ ម៉េត ។

បូលីៈ មិនមែន ស៊ូ ម៉េតទេអឹ?

អាតៈ មិនស៊ូទេ ម៉ង់ ។

បូលីៈ ស៊ូ ម៉េត, មាស មុត ណា?

អាតៈ មាស មុតហ្នឹងផ្សេង កូនប្រសារតាម៉ុក ។ មុតហ្នឹងគាត់ទទួលខាងនោះផ្សេង ។

បូលីៈ ខាងណា?

អាតៈ ខាងកោះកុង ។

បូលីៈ តាម៉ុត ខាងកោះកុង?

អាតៈ  តាម៉ុត ខាងកោះកុង(សើច) ។ ដាន នេះស្អី?

បូលីៈ  អៀង ដាន ។

អាតៈ  នៅខាងនេះ ខាងដូច ម៉ង ម៉េតអញ្ចឹងណា ។

បូលីៈ  ខាងកោះកុង?

អាតៈ  គ្រាន់តែដឹងអញ្ចឹងទេណា ប៉ុនត្រង់លម្អិតទៀតមិនដឹងយ៉ាងណា ខ្ញុំមិនដឹងទេណា ។

បូលីៈ  បាទ! អត់អីទេអ៊ឹ ។

អាតៈ  ដឹងប៉ុណ្ណា និយាយប៉ុណ្ណឹងហើយ ។

បូលីៈ  បាទ! និយាយលើសហ្នឹង ក៏អត់មានអីនិយាយដែរ ។

អាតៈ  អត់មានអីនិយាយ ព្រោះអត់មានសាច់រឿងនិយាយ ។

បូលីៈ  កុំឲ្យតែនិយាយតិចដាងហ្នឹង ។ អញ្ចឹងអ៊ីចាំថា ឈ្មោះអីគេ ម៉ង់ មេត អញ្ចឹងអ៊ឹ?

អាតៈ  បាទ!

បូលីៈ  ម៉ង់ មេត អ្នកគ្រប់គ្រងនៅសំឡូតហ្នឹង?

អាតៈ  បាទ!

បូលីៈ  មានកងពលអីខ្លះរត់មកសំឡូតហ្នឹង?

អាតៈ  កងពល មានកងពលវាចំរុះអូនពេលហ្នឹង សូមនិយាយ តិចទៅចុះ វាមានទាំង៨០១ ទាំង ៨១៧ គ្រប់កងពលទាំងអស់វាចំរុះបែកទ័ពទៅណា ដល់អញ្ចឹងយួនវាវាយបែក ខ្ចាត់ខ្ចាយ បែកបាក់ ខ្ចាត់ខ្ចាយអស់ហើយវាយកតែរួចរាងខ្លួនណា បាត់មេខ្លះទៅខត្តរទៅ មេខ្លះទៅ ១០០១ទៅ កូនចៅខ្លះក៏១០០១ទៅ បែកអញ្ចឹង ។ បាទ! អាហ្នឹងគ្រាន់តែវាយឲ្យប្អូនឯង ស្តាប់ ។ អញ្ចឹងទេ ប្រក៧០នេះ គឺកម្លាំងដែលមករស់នៅទីនេះគឺ ក្រោមការគ្រប់គ្រងរបស់ ម៉ង់ មេត ហ្នឹងឯង ។ រៀបចំ គេហៅថាចងក្រងទ័ព ដែលជាយុទ្ធជនទ័ពហ្នឹងណា បានជា យុទ្ធជនទ័ពហ្នឹង រៀបចំជាមេក្រុម, មេកង, មេពួកអីអញ្ចឹង, អនុសេនាធំ, អនុសេនាតូច អញ្ចឹងណា ។ មួយកងពលអីទៅនៅកន្លែងហ្នឹង បាទ! មានឈ្មោះនិម នៅគ្រប់គ្រង ។

បូលីៈ  និម?

អាតៈ  បាទ!

បូលីៈ  ប្រុស ឬក៏ស្រី?

អាតៈ  ប្រុស! មេទ័ព ។ មេទ័ពបញ្ជានៅកន្លែងហ្នឹង ។

បូលីៈ  កងពលលេខប៉ុន្មានអ៊ឹ?

អាតៈ កងពលលេខប៉ុន្មានទេ ដូចប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយខ្ញុំ បើកងខ្ញុំ ខ្ញុំស្គាល់៨៨ ។

បូលីៈ កង៨៨?

អាតៈ បាទ!

បូលីៈ កងពល ឬក៏វរៈ?

អាតៈ វរសេនាធំ៨៨ ។

បូលីៈ វរសេនាធំ៨៨ នៅក្នុងកងពលអី?

អាតៈ អាហ្នឹង អត់ទាន់មានកងពលទេ ព្រោះកន្លែងយើងអត់បានរៀបចំ ។

បូលីៈ អត់ទាន់រៀបចំ?

អាតៈ បាទ! អត់ទាន់រៀបចំ ព្រោះអត់ទាន់បែកបាក់ដូចបាននិយាយអំបាញ់មិញ(សើច) ស្ងាត់ត្រឹមវរសេនាធំនៅឡើយទេ អត់ទាន់មានកងពលទេ ។

បូលីៈ ហើយមុំហ្នឹង ឡាក់៦៩,៧០ហ្នឹង គេមានឈ្មោះគេអឹ ឧទាហរណ៍ថានៅខាងនេះគេមានច្រកតំបន់១០០១អញ្ចឹងទៅ ចុះខាងអឹ៦៩,៧០ហ្នឹងមានឈ្មោះទេ?

អាតៈ ច្រក៧០ហ្នឹង ។

បូលីៈ ច្រក៧០អញ្ចឹងតែម្ដង?

អាតៈ បាទ! ច្រក៧០អញ្ចឹងតែម្ដង ។

បូលីៈ យកឈ្មោះឡាក់ ធ្វើជាឈ្មោះតែម្ដង?

អាតៈ បាទ!

បូលីៈ ចេញចូលរវាងខ្មែរ ហើយហ្នឹងថៃ?

អាតៈ បាទ! បើខាងនេះ ខាង៦៩នេះគេហៅថាច្រកបរឡាង ។

បូលីៈ ច្រក?

អាតៈ បរឡាន!

បូលីៈ ច្រកបរឡាន?

អាតៈ បាទ! ឬក៏ច្រក៧០ អ៊ូនែកច្រក៦៩អញ្ចឹងតែម្ដង ។

បូលីៈ ច្រក៦៩?

អាតៈ បាទ! ច្រកបរឡានវានៅក្នុងឃុំ ស្រុកសំឡូត ព្រោះកន្លែងហ្នឹងកន្លែងត្បូងណាប្អូន!

បូលីៈ បាទ!

អាតៈ នៅត្បូងដល់ហើយប្អូនអើយ!

បូលី: ជីកត្បូងតាំងពីនោះមក?

អាត: បាទ!

បូលី: តាំងពី៧៩ហ្នឹងមក?

អាត: បាទ! រស់ដោយសារអាហ្នឹងឯង ។

បូលី: អញ្ចឹងប្រជាជន នៅសំឡូតរស់ដោយសារជីកត្បូងលក់ឲ្យថៃ?

អាត: ទេ! វាយើងនេះមិនរកអីទេ ប៉ុន្តែសៀមវាមករករបស់ខ្លះអីខ្លះ យើងក៏រកតិចតួច ។

បូលី: ដោះដូរគ្នាយកកម្ពុប១ ។

អាត: បាទ! ដោះដូរគ្នាយកម្ហូប១ ។

បូលី: ចុះច្រក៧០មានឈ្មោះទេអី?

អាត: បាទ?

បូលី: មានឈ្មោះដូចច្រក៦៩ទេ? ច្រក៦៩ គេដាក់បរឡាន!

អាត: ៧០ ឈ្មោះ ៧០តែម្តង ។

បូលី: ឈ្មោះ៧០តែម្តង! យ៉ាងម៉េចបានជាគេហៅច្រកបរឡាន?

អាត: ព្រោះមានភូមិ បរឡានយើងប្អូនឯងមើលចំណុចភូមិចាស់គេណា៎ ។ ឃើញទេ មានភូមិមួយជាប់ព្រំដែន មានចំណុចមួយជាប់ភូមិបរឡានគេ ភូមិចាស់គេពីដើម ។

បូលី: ភូមិខ្មែរ ឬក៏ភូមិថៃ?

អាត: ភូមិខ្មែរយើង តាំងពីជំនាន់ហ្នឹង ។ បាទ! គេទៅជីកត្បូងជីកអីហ្នឹង មើលខ្សែទឹកវាហ្នឹង ខ្សែទឹកហូរពីនេះមក ។

បូលី: អានេះមើលអត់ឃើញទេអី ព្រោះវាតូចពេក ។

អាត: បាទ!

បូលី: ទាល់តែដែនទីធំបន្តិច ។

អាត: មានភូមិចាស់គេមួយនៅហ្នឹង គេដាក់ឈ្មោះហ្នឹងបណ្តោយ ។

បូលី: អូ៎! យកឈ្មោះហ្នឹង ធ្វើជាឈ្មោះ?

អាត: ច្រកគេ!

បូលី: ច្រកតែម្តងអី?

អាត: បាទ! ហើយភ្នំ៧០នេះ, ភ្នំលេខចំណុះក្នុងដែនទី៧០ គេដាក់ច្រក៧០នេះបណ្តោយ ។

បូលី: បាទ! ច្រក៧០ ។

អាតៈ  រាល់អាភ្នំដែនទី៦៩នេះគេ យកច្រក៦៩ហ្នឹងបណ្តោយ ក្នុងដែនទី ។

បូលីៈ  យល់!

អាតៈ  យល់ទេអូន?

បូលីៈ  បាទ! យល់ ។ បើជាសិននៅខាងពោធិ៍សាត់ ច្រកថ្មដា ។

អាតៈ  អាហ្នឹងវាមានថ្មដាគេ គេហៅច្រកថ្មដាបណ្តោយ ។

បូលីៈ  មានភ្នំមួយគេហៅភ្នំក្បាលឡានទៀត?

អាតៈ  ក្បាលឡានទៀត! មួយទៀតពើងចេះបណ្តោយ ភ្នំហ្នឹងពើងចេះបណ្តោយ ។

បូលីៈ  ពើងចេះតែម្តងអ៊ឹ?

អាតៈ  បាទ! ពើងចេះតែម្តង ។

បូលីៈ  ដូចក្បាលឡាន?

អាតៈ  ដូចក្បាលឡានអញ្ចឹង ។ គេដាក់ក្រោយទេ ភ្នំក្បាលឡាននោះ ។

បូលីៈ  ចុះយើងនៅសំឡូតហ្នឹង យើងរស់នៅក្នុងដីខ្មែរ ឬដីថៃ?

អាតៈ  នៅដីខ្មែរ ។

បូលីៈ  ក្នុងដីខ្មែរទេ?

អាតៈ  បាទ! សៀមមិនឲ្យនៅដីគេទេ ។

បូលីៈ  ប៉ុន្មានគីឡូពីព្រំដែន?

អាតៈ  វាដូចនៅចំព្រំដែន ។

បូលីៈ  នៅលើខ្សែបន្ទាត់ព្រំដែនតែម្តង?

អាតៈ  បាទ! ១គីឡូ ពីព្រំដែនមកចូលក្នុង ។

បូលីៈ  កៀកមែនទែន នែ៎កអ៊ឹ?

អាតៈ  បាទ! កៀក ។ មានការអីឡើងព្រឹប ។

បូលីៈ  មានការអីរត់ប្រាវ ។

អាតៈ  បាទ! រត់ចូលដីថៃ ។

បូលីៈ  ហើយនៅហ្នឹងដីរាបស្មើ ឬក៏ភ្នំ?

អាតៈ  ដីខ្ពង់រាប ។ មានខ្ពង់រាបខ្លះ មាន!

បូលីៈ  អាហ្នឹងគេហៅជួរភ្នំក្រវាញមែនទេអ៊ឹ?

អាតៈ  អាហ្នឹងខ្សែភ្នំយើងវាជាប់អញ្ចឹង អានេះវាជួរភ្នំក្រវាញ បេះមកវាជាប់ភ្នំគូរហូត អត់មានដាច់ត្រង់ណាទេ ។ បាទ! មកដល់រហូត មកដល់បៃលិន មកដល់កំរៀងអញ្ចឹងតែម្ដង ។ បាទ! ប៉ុន្តែវាមិនភ្នំធំដូចជួរភ្នំក្រវាញទេ ប៉ុនអានេះក៏ភ្នំដែរ ។ ជួរភ្នំដែរប៉ុន្តែភ្នំតូចៗ អាហ្នឹងភ្នំ១ខ្នង ២ខ្នង ៣ខ្នងអីហ្នឹងណា យើងដល់ព្រំដែន ។ មានអាខ្លះតែ១ខ្នងដល់តែម្ដង ។

បូលីៈ  ហើយនៅសំឡូតហ្នឹង មានមនុស្សប្រហែលជាប៉ុន្មាននាក់នៅ សរុបទាំងអស់ ទាំងកងទ័ពកងអី?

អាតៈ  គ្រាន់តែកងខ្ញុំវា២០០នាក់ អាហ្នឹងសាច់កងទ័ព មើល២៦០នាក់ កាលចាំ៦០ឬក៏៧០ទេ ។

បូលីៈ  វរៈ៧៩?

អាតៈ  បាទ! ប៉ុនកងគេឯទៀតៗ កងចាស់គេនៅបាត់ដំបង កងខ្លះដែលគេថយមក ។

បូលីៈ  ហើយហ្នឹងនិយាយតែសាច់ទ័ពទេ?

អាតៈ  បាទ!

បូលីៈ  នៅគ្រួសារកងទ័ពទៀត?

អាតៈ  គ្រួសារកងទ័ពនៅហ្នឹងទាំងអស់ ។ មាននារីដឹកជញ្ជូន ដឹកអី នារីដឹកជញ្ជូនមានជាប់ប្រហែលជាជិត១០០០នាក់, ២០០០ទេដឹងច្រើនតាប្អូន ។

បូលីៈ  ដឹកជញ្ជូនអីគេអ៊ឹ?

អាតៈ  ដឹកជញ្ជូនគ្រាប់រំសេវ ស្បៀងអាហារ ឲ្យកងទ័ព ។

បូលីៈ  យកទៅឲ្យកងទ័ពដែលចូលមកវាយខាងក្នុងហេ៎?

អាតៈ  បាទ! ចូលមកវាយខាងក្នុង ។ ទាំងគ្រួសារអាដែង កងទ័ពកងអីនោះច្រើន ។

បូលីៈ  ហើយការស់នៅរបស់យើងសង់ជាខ្ទម សង់ជាអី ឬយ៉ាងម៉េចអ៊ឹ?

អាតៈ  សង់ជាខ្ទម ។

បូលីៈ  ប៉ុណ្ណាៗអ៊ឹ?

អាតៈ  ប៉ុនមួយសមរម្យដូចថា ។

បូលីៈ  ប៉ុនផ្ទះអ៊ឹទេ?

អាតៈ  ខ្លះគេមានប៉ុណ្ណឹង ប៉ុនភាគច្រើនធំជាងហ្នឹង ។

បូលីៈ  ភាគច្រើនធំជាងហ្នឹង?

អាតៈ  បាទ! ភាគច្រើនក្រុមនារីអី គេធ្វើដូចថាសង់រៀបជាម៉ារីយេអញ្ចឹងទៅណា ។

បូលីៈ  ជាងរោងវែង?

អាតះ   បាទ! ជាពេងវែង ៗ ដល់អញ្ចឹងទៅ មានកន្លែងសម្រាកកន្លែងពួន ស្រីៗគ្នាទៅ ៗ ហើយបើអ្នកមានគ្រួសារក៏ប៉ុនៗហ្នឹងទៅ ក្រុមគ្រួសារគេនោះ ៗ

បូលីៈ   នៅពេងវិញ អ្នកនៅលីវទេ?

អាតះ   គ្រួសារគេធ្វើមួយៗដាច់ពីគ្នា ៗ

បូលីៈ   ប៉ុន្តែ យើងរស់នៅជាមុំៗកងរបស់យើងណ៎?

អាតះ   បាទ!

បូលីៈ   មិនមែននៅរាយប៉ាយលាយគ្នាចេះទេ ៗ មិនមែនដូចថា ក្រុមប្រឹក្សាឃុំប្រាសាទនេះ អ្នកខ្លះទៅនៅដល់ទ្រនប់ដាច់អីអញ្ចឹងទៅ ៗ ហើយកាលសម័យហ្នឹង តែកងណា គឺកងហ្នឹងហើយអ៊ី?

អាតះ   បាទ! កងណា គឺកងហ្នឹងហើយ ៗ

បូលីៈ   អត់បែកខ្ញែកគ្នាទេ?

អាតះ   អត់បែកខ្ញែកគ្នាទេ ៗ

បូលីៈ   ហើយកងនៅសំឡូតបញ្ជូនទៅធ្វើការនៅខាងក្នុងនៅខេត្តណាខ្លះអ៊ី?

អាតះ   សំឡូតនេះទៅធ្វើការ ផ្លូវជាតិលេខ៥ ៗ

បូលីៈ   ផ្លូវជាតិលេខ៥មួយ ៗ ហើយអីទៀតអ៊ី?

អាតះ   ជុំវិញបាត់ដំបង ៗ

បូលីៈ   ជុំវិញបាត់ដំបង?

អាតះ   ខាងនេះ ខាងត្បូងបាត់ដំបង ៗ

បូលីៈ   ខាងត្បូងបាត់ដំបង ស្រុកអីគេអ៊ី?

អាតះ   អាហ្នឹងក្នុងស្រុកនែក៎ ភ្នំអីទេ ជិះរទេះភ្លើង មានភ្នំអីជិតបាត់ដំបងនៅផ្លូវរទេះភ្លើង ៗ ភ្នំអីទេអាហ្នឹង ដែលមានប្រាសាទនៅជិតហ្នឹង ៗ

បូលីៈ   នៅភ្នំសំពៅ? ភ្នំត្រឡោក?

អាតះ   ធិបតី!

បូលីៈ   អ៊ូ! ធិបតី?

អាតះ   បាទ! នៅខាងនេះស៊ីងបាត់ដំបងបន្តស់ ៗ

បូលីៈ   បានន័យអត់ឆ្លងទៅនៅត្រើយខាងនោះស៊ីងទេ នៅខាងនោះសាលាខេត្ត?

អាតះ   ទៅមុំពេងចក្រ ៗ

បូលីៈ   ទៅមុំពេងចក្រដែរ?

អាតៈ ឆ្លងទៅមុំរោងចក្រស្ករស ។

បូលីៈ ឆ្លងស្ពានដែរអញ្ចឹង?

អាតៈ បាទ! ឆ្លងស្ទឹង ។

បូលីៈ ឆ្លងស្ទឹង! អញ្ចឹង ខ្ញុំអាចនិយាយអញ្ចេះបានទេ ខ្ញុំអាចនិយាយគិតមិនលម្អិតដល់ស្រុកទេ យើងគិតត្រឹមខេត្តសិនចុះ ។ អ្នកដែលខ្មែរក្រហមនៅសំឡូតហ្នឹង ទៅធ្វើការនៅខេត្តបាត់ដំបង នៅតំបន់មួយចំនួននៅខេត្តបាត់ដំបង ត្រូវទេអី? ខ្ញុំនិយាយអញ្ចឹងត្រូវទេអី?

អាតៈ អត់ត្រូវទេ! ព្រោះបានតែមួយខាងទេ បានបាត់ដំបងខាងជើងខាងត្បូង មិនបានបាត់ដំបងទាំងមូលទេ ។

បូលីៈ មិនមែនបាត់ដំបងទាំងមូលទេអញ្ចឹង?

អាតៈ បាទ! អត់មានឆ្លងថ្នល់លេខ៥ ទៅខាងនោះទេ ទៅខាងទន្លេសាបទេ ។

បូលីៈ អូ! អត់ឆ្លងផ្លូវទៅខាងទន្លេសាបលេខ៥ទេ?

អាតៈ បាទ! អត់ឆ្លងមកនេះទេនេះ អត់ឆ្លងមកតំបន់ទេនេះណា៎!

បូលីៈ អញ្ចឹងមកនៅខាងនេះទន្លេសាប?

អាតៈ ខាងនេះថ្នល់ទាំងអស់ ។

បូលីៈ ខាងនេះថ្នល់ទាំងអស់ មកដល់ទន្លេសាបអញ្ចឹង?

អាតៈ បាទ! ប៉ុនអត់ចូលទៅខាងពោធិ៍សាត់ដែរ ព្រោះពោធិ៍សាត់ពួកខាងថ្មដាកោះកុងមកធ្វើ ។

បូលីៈ អញ្ចឹងហ៎អឺ?

អាតៈ បាទ!

បូលីៈ អ្នកនៅពោធិ៍សាត់នៅខាងថ្មដាទេ គេអ្នកធ្វើនែក?

អាតៈ បាទ!

បូលីៈ អ្នកថ្មដា គេធ្វើការនៅក្នុងខេត្តពោធិ៍សាត់ទាំងមូល?

អាតៈ បាទ!

បូលីៈ អញ្ចឹងអ្នកសំឡូតធ្វើការនៅខាងនេះផ្លូវជាតិលេខ៥?

អាតៈ បាទ! អាហ្នឹង ខាងណាខាងត្បូងណា៎?

បូលីៈ ខាងត្បូង!

អាតៈ បាទ!ខាងត្បូង ។

បូលីៈ អានេះអឺ អានេះអឺ! ពាក់វែនតាបានមើលឃើញអឺ! នេះខ្ញុំបង្ហាញអឺផ្លូវជាតិ នេះផ្លូវជាតិលេខ ៥ នេះអឺនេះ ។ នេះផ្លូវជាតិលេខ៥ វាចាក់មកប៉ោយប៉ែតនេះៗ ខេត្តបាត់ដំបងណា!

អាតៈ បាទៗ ឃើញ ។

បូលីៈ អានេះ ខ្ញុំចង្អុល អានេះទីរួមខេត្តពោធិ៍សាត់ ហើយបានចាក់មកនេះ ចាក់មកនេះកំពង់ឆ្នាំង ណាអឺ ចាក់មកដល់កំពង់ឆ្នាំង ហើយបានចាក់មកដល់ភ្នំពេញ?

អាតៈ បាទ!

បូលីៈ នេះខ្សែខ្មៅនេះផ្លូវជាតិលេខ៥អឺ អានេះពោធិ៍សាត់ បាត់ដំបង ហើយនេះបន្ទាយមានជ័យ បន្ទាយមានជ័យ ហើយនេះប៉ោយប៉ែត ។ អញ្ចឹងអ្នកនៅសំឡូតនេះមកធ្វើការ មកខាងមួយ ជំនាវនេះលោកគ្រូ?

អាតៈ បាទៗ!

បូលីៈ មួយជំនាវ បាត់ដំបង ប៉ុន្តែនៅខាងផ្លូវជាតិលេខ៥?

អាតៈ បាទ! ខាងលិចផ្លូវជាតិលេខ៥ ។

បូលីៈ នេះផ្លូវជាតិលេខ៥អឺ ។

អាតៈ ខាងលិចផ្លូវជាតិលេខ៥ ។

បូលីៈ អត់មានឆ្លងទៅទេអឺ?

អាតៈ អត់ទេឆ្លងទេ!

បូលីៈ ចុះពីណាគេធ្វើការខាងឆ្លងខាងនេះ?

អាតៈ អាហ្នឹង អាចខាងហ្នឹង អាចខាងនេះក៏មិនដឹង ខ្ញុំអត់ដឹងច្បាស់ដែរ?

បូលីៈ អាចបែប១០០៣ ខាងតាម៉ុក?

អាតៈ បាទ! អាច១០០៣ ខាងតាម៉ុក ។

បូលីៈ ខាងតាម៉ុក គាត់បញ្ជូនមកបឹងទន្លេសាបនេះ អញ្ចឹងអឺធ្វើការនៅសំឡូតនេះធ្វើការតែ១ខែ ខាង ផ្លូវជាតិលេខ៥នេះទេ?

អាតៈ បាទ!

បូលីៈ ក្នុងធិបតីអីអឺ?

អាតៈ បាទ!

បូលីៈ ក្នុងស្រុកអីធិបតី?

អាតៈ ទេ! ដូចស្រុកធិបតីអញ្ចឹងតែម្តង មែនណាំអូន!

បូលីៈ  អត់មានទេ ស្រុកធីបតី ។

អាតៈ  មិនដឹងស្រុកអីអាហ្នឹង ។ ពិសេសមែនទែនហើយអ្នកធ្វើការនៅជុំវិញសំឡូត ។

បូលីៈ  ជុំវិញសំឡូត នែ៎កអឺនែក?

អាតៈ  ធ្វើការជុំវិញសំឡូត ។

បូលីៈ  ពីអ្នកមកឡាក់៦០, ៩៧០ហ្នឹង?

អាតៈ  បាទ! ធ្វើការជុំវិញសំឡូត ។

បូលីៈ  គាត់ទៅធ្វើការនៅជុំវិញហ្នឹងហេ៎?

អាតៈ  បាទ!

បូលីៈ  ខាងលិចផ្លូវជាតិលេខ៥ ។ ប៉ុន្តែអត់ឆ្លងដល់ពោធិ៍សាត់ទេ?

អាតៈ  បាទ! អត់ដល់ពោធិ៍សាត់ទេ ។

បូលីៈ  ចុះឆ្ងាយទៅបន្ទាយមានជ័យទេមើលទៅ?

អាតៈ  អត់ទេ!

បូលីៈ  អត់ឆ្ងាយទេណ៎?

អាតៈ  អត់ទេ! ធ្វើការតែម្តុំហ្នឹង ។

បូលីៈ  ប៉ៃលិន?

អាតៈ  បើមានការសហការពីខាងបៃលិន អាហ្នឹងបានយើងសហការ ធ្វើតាមផ្លូវជាតិលេខ១០ ។

បូលីៈ  តាមផ្លូវជាតិលេខ១០ទៀត?

អាតៈ  បាទ! បើមានការសហការ បើអត់សហការទេ មុខសញ្ញារបស់ប៉ៃលិន របស់គេទេ ។

បូលីៈ  ប៉ៃលិន គេធ្វើការមួយជំនារខាងនេះគេទៅ?

អាតៈ  បាទ!

បូលីៈ  អញ្ចឹងនិយាយរួមទៅ អ្នកដែលនៅមួយជំនារនេះ ប៉ៃលិន អើម៉ាឡៃ សំឡូតនេះធ្វើការតែមួយក្រវិលតែម្តុំនេះទេ?

អាតៈ  បាទៗ! ក្រវិលតែម្តុំនេះទេ ។

បូលីៈ  អ្នកកោះកុងអ្នកថ្មដាអីក៏ធ្វើការនៅមួយក្រវិលពោធិ៍សាត់កោះកុងដែរ?

អាតៈ  បាទ!

បូលីៈ  អត់ចាក់ដល់នេះទេ? អត់ចាក់ដល់កំពង់ស្ពឺ ដល់កំពតទេ គាកែវអីអឹ?

អាតៈ  ខ្ញុំអត់ដឹងច្បាស់ទេ!

បូលី៖ អ្នកកំពង់ស្ពឺ! អ្នកកំពត អ្នកតាកែវនេះ១០០៣ដែរ ទីតាំងធំរបស់តាម៉ុក? ហើយមួយជំនាវខាងត្បូងសាន១០០១?

អាត៖ អាហ្នឹង ខាងហ្នឹងគេចាត់ចែងហើយ ។

បូលី៖ បាទ!

អាត៖ ខាងតាម៉ុក គាត់ចាត់ចែងទៅដែរ ខាត្បូងសានណាំ ។

បូលី៖ អានេះគ្រាន់តែជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ អើបឋមសិនទេណាអ៊ំ មិនទាន់ជ្រាលជ្រៅថាយ៉ាងម៉េចទេ ។ នៅខាងខេត្តព្រះវិហារ គេ១, ២, ៣, ៤, ៥, ៦,៧ ខេត្ត ។ អ្នកនៅ១០០១ហ្នឹង គេកាន់កាប់៧ខេត្ត ដែលបញ្ជូនកងទ័ពមកធ្វើការខាងក្នុងចលនាណាអ៊ំ? អញ្ចឹងអ៊ំ ខ្ញុំសុំបន្តបន្តិចតិចទៀតអ៊ំ អំពីយើងចល័តធ្វើការហ្នឹង ការដែលទៅធ្វើការហ្នឹង ធ្វើការនៅខាងក្នុងហ្នឹងយើងបែងចែកកម្លាំងប៉ុន្មាន បែងចែកប៉ុន្មានកង ប៉ុន្មានអី?

អាត៖ អាហ្នឹងគេចែកជាក្រុម ។

បូលី៖ ចែកយ៉ាងម៉េចអ៊ំ?

អាត៖ ក្រុមហ្នឹងឧបមាថា មួយអនុសេនាតូចគេហ្នឹង គេត្រូវទទួលមុខសញ្ញាខាងណា ឧបមាថាក្រុមហ្នឹងត្រូវចុះមកផ្លូវជាតិ ភ្នំធិបតី មុខសញ្ញានេះគឺទទួលធិបតី ហើយមួយក្រុមទៀត ទទួលសំឡូតមកមួយក្រុមទៀតទទួលសំឡូតដូចគ្នាតែអាមួយខាងជើង អាមួយខាងត្បូង ដល់មួយក្រុមទៀតទទួខាងលិច ។

បូលី៖ មួយក្រុមប៉ុន្មាននាក់?

អាត៖ ១២នាក់ ។

បូលី៖ ១២នាក់ ។ កិច្ចការរបស់ក្រុមនីមួយៗធ្វើអីខ្លះ?

អាត៖ បាទ! មួយជំនាន់នោះទិសសំខាន់គឺកំទេច ដូចថាវាមួយខាងនេះខ្លាំងហើយណា កាលនោះគេថាខ្លាំងដូចគ្នា អញ្ចឹងទិសទៅគឺកំទេចខ្លាំងនោះឯង ខ្លាំងយួនណា បាទ! កំទេចយួនណា ។

បូលី៖ ក្រៅពីកំទេចខ្លាំងយួនមានកសាងកម្លាំងទេអ៊ំ?

អាត៖ កសាងកម្លាំង!

បូលី៖ កសាងដែរ ។

អាត៖ ជួបប្រជាជន ។ ទី១ គឺកសាងកម្លាំង ជាមូលដ្ឋាន អ្នកទៅធ្វើការហ្នឹងគេកំណត់ អ្នកឯងត្រូវទៅ១០ថ្ងៃ ។ ទី១គឺកសាងកម្លាំងប្រជាពលរដ្ឋ ដើម្បីជាព្រៃ គេថាព្រៃ ប្រជាពលរដ្ឋជាព្រៃ ជាប្រភពស្បៀងដែលអត់ចេះរីងស្ងួត ព្រោះយើងមិនងាយស្ពាយស្បៀងទៅព្រំដែនទេអូន ។

បូលីៈ សំខាន់ណាស់! ប្រជាពលរដ្ឋជាព្រៃ ហើយជាប្រភពស្បៀងទៀត ។

អាតៈ ជាប្រភពស្បៀងទៀត បាទ! អត់ចេះរើសសួតទេ ។ អញ្ចឹងគេណែនាំធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ប្រជាពលរដ្ឋឲ្យសោះ ទោះបីជាករណីណាក៏ដោយ អ្នកលើគេណែនាំអញ្ចឹងណា ហើយខំកសាងគាត់ ឲ្យគាត់ជួយបំរើការងារយើងលាក់បំពួនយើង និងផ្តល់ស្បៀងឲ្យយើង ហើយបំពាក់ គាត់ឲ្យជាស្នូលរបស់យើង ហើយអាស្នូលទៅព្រៃ ។ ហើយគិតថាសំខាន់ដែលទៅធ្វើការនៅក្នុង ។

បូលីៈ អាហ្នឹងកំទេចខ្មាំងយួន?

អាតៈ ហើយទី២ទៀត គឺសំខាន់ ឲ្យព័ត៌មានយើង ។

បូលីៈ ឲ្យព័ត៌មានយើងទៀត?

អាតៈ ឲ្យព័ត៌មានយើង ដូចថាយួនឡើងយួនចុះអញ្ចឹងទៅណា បន្ថែមកម្លាំងអីៗអញ្ចឹង ឲ្យមានរាយការណ៍អីអញ្ចឹង ។

បូលីៈ មុនចុះទៅមានរៀនសូត្រសិនអីទេអឺ? មុនពេលគេបញ្ជូនទៅមានរៀនសូត្រ បំពាក់បំប៉នអីអញ្ចឹងទេ?

អាតៈ បាទ! មានគេរៀនសូត្រខាងផ្នែកនយោបាយ ។

បូលីៈ ពីណាគេបង្រៀន?

អាតៈ ម៉េត! ម៉ង់ ម៉េត ។

បូលីៈ ម៉េត?

អាតៈ បាទ! មេបញ្ជាការ ។

បូលីៈ ខ្ញុំចេះសង្ស័យថា ស៊ូ ម៉េត! ស៊ូ មេត គាត់សេនាធិការនៅក្រោមតែស៊ុន សេនមួយទេ កាលនៅភ្នំពេញមួយណាអឹ ។ ស៊ូ ម៉េត ហើយហ្នឹងមាស មុំត ។

អាតៈ កាលនោះគាត់ទទួលព្រលានយន្តហោះ ។

បូលីៈ បាទ! ហ្នឹងឯង ស៊ូ ម៉េត ។

អាតៈ បាទ! ប៉ុនឈ្មោះនៅខាងខ្ញុំគេហៅម៉ង់ ម៉េត ។

បូលីៈ ម៉ង់ ម៉េត អឺ?

អាតៈ បាទ! ម៉ង់ ម៉េត គឺជាឪពុករបស់គាត់ ដែលគាត់តស៊ូ ។

បូលីៈ ម៉ា ម៉ង់?

អាតៈ បាទ! គាត់ឈ្មោះ មង់ ម៉េតអញ្ចឹងតែម្តង ។

បូលី៖ បាទ!អញ្ចឹងច្បាស់ហើយ ។ ស៊ូ ម៉េតហ្នឹងកូនតា ម៉ា ម៉ង់ណាអ៊ី ។ ម៉ា ម៉ង់ដែលនៅនិរតីមុន តាម៉ុកទៀត ទាំងពីរស្បូវ?

អាត៖ តាំងពីរស្បូវ ។

បូលី៖ អញ្ចឹង តាស៊ូម៉េតនេះនៅសំឡូតអ៊ីនែក៎?

អាត៖ បាទ! គាត់ទទួលឡាក់៧០ ។

បូលី៖ គាត់ទទួលឡាក់៧០ ។

អាត៖ គាត់ទទួលតាំងពី៧០,៦៩អីទាំងអស់ហ្នឹង ។ មុខព្រួញហ្នឹង គឺគាត់មុខព្រួញសំឡូតគឺគាត់ហើយ ។

បូលី៖ មុខព្រួញសំឡូតគឺគាត់ហើយ?

អាត៖ បាទ!ទាំង៧០,៦៩ ។

បូលី៖ គាត់កាន់កងពលលេខប៉ុន្មាន តាម៉េត?

អាត៖ តាម៉េត ពីជំនាន់មុនគាត់៦០០ប៉ុន្មានទេនេះ!

បូលី៖ កាលដែលគាត់ទៅសំឡូត?

អាត៖ កាលគាត់នៅសំឡូត គាត់គេហៅថាគាត់ប្រធានមុខព្រួញទាំងពីនេះឯង ទាំង៧០ និង៦៩ ។ ប្រធានមុខព្រួញ ។

បូលី៖ ដល់កោះកុង តា ម៉ុត?

អាត៖ តា ម៉ុត គាត់ប្រធានមុខព្រួញ ។

បូលី៖ ចុះថ្មដាពីណាអ៊ី?

អាត៖ ថ្មដា! ខ្ញុំមិនដឹងច្បាស់ដែរ ប៉ុន្តែតាមដឹងដូចអាចតាម៉ុត ។

បូលី៖ តាម៉ុតដែរ ទាំងកោះកុង និងពោធិ៍សាត់?

អាត៖ បាទ! ព្រោះគាត់មេញ្ញាកាមុខព្រួញ ដូចតាម៉េតអញ្ចឹង ដោយឡែកទីតាំងគាត់នៅ៧០នោះទេ ប៉ុន្តែគាត់បញ្ជាបានទាំង៦៩ ព្រោះមុខព្រួញគាត់ត្រូវបញ្ជា ។

បូលី៖ ចុះប៉ៃលិន?

អាត៖ អ៊ី ឈាន ។

បូលី៖ អ៊ី ឈាន ។

អាត៖ ប៉ុន្តែកាលហ្នឹង ដូចមិនមែនអ៊ី ឈានទេ ។

បូលី៖ ពីណាវិញទៅអ៊ី?

អាត៖ កាលហ្នឹង ដូចជា ស៊ិន សេន ។

បូលីៈ ស៊ុន សេន! គាត់នៅ១០០១ហើយ?

អាតៈ ១០០១នេះមកនៅក្រោយទេ។ មិនដូចពីណាគេទេ ប៉ៃលិន ដូចមិនមែនអ៊ី ឈានទេ។ អ៊ី ឈាន ទើបតែមកក្រោយទេ។

បូលីៈ អ៊ី ឈានពីឆ្នាំមក?

អាតៈ អ៊ី ឈាននៅយូរតាំងពីជំនាន់ខ្ញុំពីដើមនោះមក ប៉ុនកាលនោះគាត់ ប្រធានកងដូចជាប្រធានកង ពលអីក៏មិនដឹង។ បាទ! ខ្ញុំមិនដូចមិនសូវច្បាស់ទេមិនដឹង កាលនោះអ៊ី ឈាន។ វាមិនច្បាស់ទេ! ប៉ុនដូចអ្នកដឹកនាំ មិនមែនអ៊ី ឈានទេ។

បូលីៈ មិនមែនអ៊ី ឈានទេ?

អាតៈ មិនមែនទេ។ មានមេគេថាជាងនេះទៅទៀត ក្នុងគណបក្សអចិន្ត្រៃរបស់គេហ្នឹង ដូចគេបែកគ្នាអញ្ចឹងទៅណា។ ដូចឧទាហរណ៍ថា តាម៉ុក ត្រូវទៅនៅឯណា នៅប្រចាំការឯណាហ៎ នែក៎តាអីកាត់ទោសនោះ?

បូលីៈ ខៀវ សំផន, នួន ជា។

អាតៈ ខៀវ សំផន, នួន ជា គាត់នៅណា? ហើយខៀវ សំផន មិនដឹងគាត់កាន់កាប់នៅណាទេ។

បូលីៈ មិនមែនអៀង សារីទេ ប៉ៃលិន?

អាតៈ មិនមែនអៀង សារី។

បូលីៈ អៀង សារី គាត់នៅម៉ាឡៃទេកាលហ្នឹង?

អាតៈ នៅម៉ាឡៃ ណា ដូចមិនច្បាស់ទេណាអូន! មិនដាក់ កុំដាក់ ខ្ញុំអត់ច្បាស់ទេ។

បូលីៈ ឥលូវយើងច្បាស់តែតាម៉ង់ ម៉េត តែមួយទេ?

អាតៈ បាទ!

បូលីៈ នៅខាងសំឡូត!

អាតៈ សំឡូត។

បូលីៈ ហើយតាម៉ុត នៅកោះកុងពើសាត់?

អាតៈ បាទ!

បូលីៈ គ្រាន់តែថាមេធំនៅលើតាមុតហ្នឹង មានតាប៉ុល ពត តាអីនៅហ្នឹងធ្វើរឿងនយោបាយកាទូត ហើយបញ្ជាទ័ព រឿងតាម៉ុតហើយ។ តា ម៉ុត, តាម៉េត?

អាតៈ បាទ! តែឯងរាជ្យ តាម៉េតទេ។ ក្រោយមក បានតានេះមកនៅជាមួយ។

បូលីៈ តាណា?

អាត: តានួនជា ។

បូលី: គាត់ឯករាជ្យរបស់គាត់ ។

អាត: ក្រោយមកបាននួនគាត់ឡើងមកជាទីប្រឹក្សា ។

បូលី: ទាក់ទងទៅហ្នឹង កម្លាំងកសាងបន្តទៀតអ៊ី យើងចុះទៅហ្នឹង គឺដើម្បីចលនាប្រជាជនឲ្យចុះចូលជាមួយយើង ឲ្យជួយលាក់បំពួនយើងណា ឲ្យជួយផ្គត់ផ្គង់ចំណីអាហារដែលមិនចេះរីងស្ងួតទេ ឲ្យគាត់ធ្វើជាស្នូលរបស់យើង ។ ហើយគាត់ផ្ដល់ព័ត៌មានពីខ្មាំង ដើម្បីកំទេចខ្មាំងឃួនមិនអញ្ចឹងអ៊ីណេ៎?

អាត: បាទ!

បូលី: ហើយពេលចុះទៅយើងត្រូវរៀនសូត្រមុនសិន ។ នរណាគេអ្នកបង្រៀន?

អាត: តាម៉េត!

បូលី: ក្រៅពីតាម៉េតមាននរណាគេទៀតទេ?

អាត: អត់មានទេ! ព្រោះគាត់រួចដៃហើយ ឯងឯករាជ្យហើយ ។

បូលី: ហើយអ៊ីចុះទៅខាងណា?

អាត: ខ្ញុំនៅប្រចាំការ ។

បូលី: អ៊ីប្រចាំការនៅណាវិញ?

អាត: ខ្ញុំប្រចាំការនៅឡាក់ នៅបរឡាន ។

បូលី: នៅបរឡាន?

អាត: នៅបរឡាន នៅឡាក់៧០ អ៊ូឡាក់៦៩ ច្រក៦៩ ប្រចាំការនៅហ្នឹង ។

បូលី: នៅបរឡាន ។ តំណែងជាអីនៅប្រចាំការហ្នឹង?

អាត: ទទួលផ្គត់ផ្គង់ភស្តុភា ។

បូលី: ទទួលផ្គត់ផ្គង់ភស្តុភា?

អាត: បាទ! ផ្គត់ផ្គង់ភស្តុភាស្បៀងអាហារ ។

បូលី: បើយើងគិតពីតំណែងតាម៉េត គាត់តំណែងធំណាស់ណា អ៊ីប៉ុន្មានតពីតាម៉េតមក?

អាត: ហ៊ូ! ខ្ញុំឆ្ងាយតណាស់ ។

បូលី: មិនមែនអនុតាម៉េតទេអី?

អាត: អត់ទេ!

បូលី: អត់ដល់អនុទេណេ៎?

អាតៈ   បាទ! ដូចថាយើងជាផ្នែកមួយ ។

បូលីៈ   គេមានផ្នែកអ្វីខ្លះនៅម្ដុំសំឡូតហ្នឹង?

អាតៈ   សំឡូតហ្នឹងមានផ្នែកដូចថាធ្លាប់ដឹង មានផ្នែកកងទ័ព មានដែកដឹកជញ្ជូន ។

បូលីៈ   ចុះភស្តុភានៅផ្នែក ខាងណា?

អាតៈ   ភស្តុភានៅជួរខាងកងទ័ព ។

បូលីៈ   ជួរកងទ័ពដែរ?

អាតៈ   បាទ!

បូលីៈ   នារី?

អាតៈ   នារីក៏ចូលក្នុងភស្តុភាដែរ សមាជិកដឹកជញ្ជូន អាដឹកជញ្ជូននោះភស្តុភាហើយ ។

បូលីៈ   ហើយយើងផ្គត់ផ្គង់ហ្នឹង ផ្គត់ផ្គង់អីខ្លះ?

អាតៈ   ផ្គត់ផ្គង់ហ្នឹងមានស្បៀង ដែលតាមថ្នាក់លើឲ្យមក ដូចជាមីអីអញ្ចឹងទៅ ម្ហូបអាហារ ត្រីខ ត្រីអី អញ្ចឹងទៅទឹកដោះគោ គ្រាប់រំសេវ របស់អីដែលថ្នាក់លើផ្ដល់មក គឺត្រូវផ្ដល់ឲ្យកងទ័ពគឺភារកិច្ច ខ្ញុំបញ្ជូនឲ្យកងទ័ពទាំងអស់ ។ ហើយអ្នកដែលត្រូវបញ្ជូនឲ្យកងទ័ព គឺអ្នកដែលនារីដឹកជញ្ជូនហ្នឹងឯង ។ យុវជនយុវនារី អ្នកដែលគ្នាមិនដែលធ្វើយោធាអី ដូចជាយុទ្ធជនខ្លះ គ្នាមិនដែលធ្វើយោធាមន្ទីរអញ្ចឹងណា ឲ្យចូលរួមដឹកនាំនារី ដឹកនាំជូនសម្ភារទៅមុខ ។

បូលីៈ   ឲ្យកងទ័ពនៅជួរមុខ ទៅវាយ?

អាតៈ   ស្នាក់ការគេទេ មិនមែនកន្លែងវាយទេ ។

បូលីៈ   ហ៊ូ! ត្រឹមស្នាក់ការទេ?

អាតៈ   បាទ! ឧបមាថាប៉ុន្មានគីឡូខ្ញុំនៅឯមុខអញ្ចឹងទៅ វាស្នាក់ការមួយរបស់គេនៅហ្នឹង យើងដឹកឲ្យគេនៅហ្នឹងទៅ ។

បូលីៈ   ដល់ពីស្នាក់ការទៅកន្លែងវាយ កងទ័ពគេដឹកខ្លួនឯង?

អាតៈ   គេដឹកខ្លួនឯង ។

បូលីៈ   អានេះបានច្បាស់ ។

អាតៈ   បាទ! មិនមែនយើងទៅដឹកឲ្យគេទៅដល់សមរភូមិ ស្លាប់បណ្ដោយ ខ្មាំងវាយស្លាប់ ។

បូលីៈ   ដែលដឹកទៅហ្នឹង យើងប្រើមធ្យោបាយអី? ឡាន ឬក៏ដើរ?

អាតៈ   ជិនាន់ហ្នឹង គ្មានទេមានតែស្ពាយនិងខ្នង ។

បូលីៈ   ស្ពាយនឹងខ្នង?

អាតៈ  បាទ! មានសាក់កាដូរដែលចិនគេបើឲ្យ គេយកទៅតិចទាំងប្រុសទាំងស្រី អត់មានរែក អត់មានអីទេ មានស្ពាយ ។

បូលីៈ  ទៅម្តងចំណាយពេលប៉ុន្មានថ្ងៃ បានទៅដល់?

អាតៈ  អាហ្នឹងដោយកន្លែងដែរ អាកន្លែងខ្លះទៅ២ថ្ងៃទៅបានមកវិញ កន្លែងខ្លះទៅមួយព្រឹក តាមកន្លែងជិតសំឡូត ដូចសំឡូតយើងទៅមួយព្រឹក ។

បូលីៈ  សំឡូតមួយព្រឹកទេ?

អាតៈ  បាទ!មួយព្រឹកមកវិញ ។

បូលីៈ  អាហ្នឹងដោយសារសំឡូតវាជិត ចុះបើទៅដល់ផ្លូវជាតិលេខ៥ ។

អាតៈ  ផ្លូវជាតិលេខ៥អាហ្នឹង២ថ្ងៃ ព្រោះយើងវាងសំឡូតចេះទៅឆ្ងាយ ។

បូលីៈ  ដែលដើរហ្នឹង គឺ យើងដើរកាត់ព្រៃ ឬមានថ្នល់ដែរ?

អាតៈ  ទេ! កាត់ក្នុងព្រៃ ប៉ុន្តែព្រៃដែលគេធ្វើផ្លូវណាំ សម្រាប់ទ័ពដែលគេដើរ ដើរតាមនោះ ។

បូលីៈ  មានដែលជួបវៀតណាម វាយស្ទាក់ផ្លូវទេ?

អាតៈ  ពួកដឹកជញ្ជូនរបស់ពួកខ្ញុំមិនដែរទេ បើម៉េចៗកងទ័ពខាងមុខគេឲ្យដឹង ឧបមាថាថ្ងៃនេះត្រូវដឹកស្បៀង យើងសួរសភាពការណ៍ខាងមុខយ៉ាងម៉េចៗ បើខាងមុខគេអត់អីទេ(ស្តាប់ពុំបាន) ខ្ញុំថាឲ្យបងប្អូនទៅ បើថ្ងៃនេះគេថាហ៉ឺយួនឡើងមិនបាច់មកទេ ខាងមុខគេប្រាប់ថាកុំឲ្យមក បើដឹងយួនឡើង យើងអត់បាត់ទៅទេ ។

បូលីៈ  គេឲ្យដំណឹងដែរអញ្ចឹង?

អាតៈ  គេឲ្យដំណឹង ។ ប្រព័ន្ធទាក់ទងគេជាប់គ្នា ។

បូលីៈ  ចុះបើមានទាហានរបួស ធ្វើយ៉ាងម៉េចទៅអី?

អាតៈ  បើទាហានរបួសយើងទៅជួយយក ពួកដឹកគេជួយសែង ។

បូលីៈ  ជួយសែងអ្នករបួសមក?

អាតៈ  បាទ! ពួកអ្នកធ្វើការ គេមានភារកិច្ចដឹកមកដល់ស្នាក់ការ ។ ដល់តែយើងទៅយកនៅស្នាក់ការមកដាក់នៅមន្ទីរពេទ្យ ។ អ្នកធ្វើការខាងជួរមុខនោះគេ យកមកត្រឹមស្នាក់ការគេ យើងដឹកជញ្ជូនហ្នឹងទៅយកមកដាក់មន្ទីរពេទ្យបង្អែកអី ។ វះកាត់ពោះវៀនខ្នែងអី មិនបាច់អស់លុយ១រៀលទេ គ្មាននរណាចាយលុយជំនាន់ហ្នឹង ។

បូលីៈ  មិនដូចឥលូវទេអី?

អាតៈ មិនដូចឥលូវទេ ។ ពោះវៀនដុះខ្នែងអីដូនការ ដូតអីនេះនោះហើយវះខ្វោក ដាក់ថ្នាំស្ពឹកអីទៅ ហើយបាត់ ទើបដឹកគេវះបាត់មាត់បាត់ករ ។

បូលីៈ ពេលចុង៨៤, ឆ្នាំ៨៥មិនអើ! កងទ័ពយួន និងកងទ័ពក្នុងរដ្ឋាភិបាលក្នុងនេះធ្វើការបោសសំអាតខ្មែរក្រហមបើតាមព្រំដែនទាំងអស់, មិនអញ្ចឹងអីអ៊ី? យើងវាយធំណា បាទ! ពេលហ្នឹង១០០១ ក៏រលំ,១០០២នេះក៏រលំ, ១០០៣នេះក៏រលំ ហើយកោះកុងថ្មដាបរឡានអីនេះ រហូតដល់កំរៀងភ្នំព្រឹក ម៉ាឡៃ ប៉ោយប៉ែតគឺថា ខ្ទាតមកដីថៃអស់ហើយ កម្លាំងខ្មែរក្រហមណា ត្រូវទេអ៊ី?

អាតៈ បាទ! ត្រូវហើយ ។

បូលីៈ ឬក៏អាចមានកម្លាំងខ្លះនៅក្នុងទឹកដីខ្មែរដែរ ពេលដែលវៀតណាមវាយខ្លាំងណា?

អាតៈ បាទ!

បូលីៈ អត់មានទេណ៎អ៊ី?

អាតៈ បាទ!

បូលីៈ ខ្ទាតមកដីថៃទាំងអស់ ។ ពេលហ្នឹងយើងលែងមានទីតាំងនៅក្នុងដីខ្មែរឈរជើងហើយ ពេលហ្នឹង ។ ពេលហ្នឹងតើក្រុមសំឡូតមកឈរជើងនៅម្ដុំណា?

អាតៈ ឈរជើងនៅចម្រេះភ្នំក្រោម ។

បូលីៈ ភ្នំដីថៃហ៎?

អាតៈ បាទ!

បូលីៈ បានន័យថាភ្នំហ្នឹងវានៅក្នុងដីខ្មែរផង ដីថៃផង?

អាតៈ បាទ! ដល់ពេលហ្នឹងយើងមិននៅក្នុងដីៃ ។

បូលីៈ នៅក្នុងដីថៃ?

អាតៈ ដល់ពេលបោសសំអាតធំ យើងមិននៅក្នុងដីថៃបណ្ដោះអាសន្ន ។

បូលីៈ យើងមានឈ្មោះគេហៅទេអ៊ី?

អាតៈ គេហៅសាន់ចៅ ។

បូលីៈ សាន់ចៅហ៎?

អាតៈ បាទ! តំបន់សាន់ចៅ ។

បូលីៈ តំបន់សាន់ចៅ ។

អាតៈ បាទ! ដីថៃសានចៅ រស់នៅក្រោមក្នុងហ្នឹង គ្រាន់តែចុះរមៀលទៅ ។

បូលី៖ ប៉ុន្មានគីឡូពិដីខ្មែរទៅអ៊ី?

អាត៖ ទេ! អត់មានច្រើនគីឡូទេ យើងនៅតែ២គីឡូ ពីកំពុលភ្នំចេះទៅ។

បូលី៖ យួនអត់មាមកវាយដល់ហ្នឹងទេអ៊ី?

អាត៖ អត់ទេ!

បូលី៖ ម៉េអញ្ចឹង?

អាត៖ ខ្លាចមីន។ មកហ្នឹងក៏មិនស្រួលដែរ ផាប់មិនស៊ើទេអាអូន ទាក់មីនផាប់មិនចេះស៊ើរ មេវាបញ្ជាដាច់ខាត នរណាមិនទៅបាញ់ចោលនិយាយរួម មិនមែនធម្មតាទេ។ មក១ហ្នឹងទាក់មីនផាប់មិនស៊ើរទេ។

បូលី៖ មុនហ្នឹងយើងតេ់ចេញមកយើងដាក់មីនច្រើនដែរ?

អាត៖ បាទ! ដាក់ច្រើនណា៎ មិនមែនធម្មតាទេ។

បូលី៖ តាមព្រំដែនរហូតណា៎?

អាត៖ ផាប់មិនចេះតិចទេ។ ក្បាលរលាក្បាលយួនទៅអីទៅ ខាងយើងនេះក៏ស្លាប់ច្រើន ខាងយើងអត់មានអីទេ។

បូលី៖ ខាងយើងអត់មានអីទេ?

អាត៖ បាទ! ព្រោះយើងដឹងតែសភាពការណ៍ធំ ដកទ័ព។

បូលី៖ យើងមានដាន់មីនខ្លួនឯងទេអ៊ី?

អាត៖ មាន។

បូលី៖ មានដែរ?

អាត៖ បាទ! ជួនការទៅដាក់ទៅច្រលំកន្លែង ច្រលំដែនទី។

បូលី៖ គេដាក់ហ្នឹង គេមានដែនទីត្រឹមត្រូវអ៊ី?

អាត៖ បាទ! មានដែនទីត្រឹមត្រូវ។

បូលី៖ គេមិនមែនចេះតែដាក់ទេ?

អាត៖ បាទ!

បូលី៖ ប៉ុន្តែអ្នកដែលយល់ដែនទីមិនប្រាកដយល់ទាំងអស់គ្នាទេ?

អាត៖ បាទ!

បូលី៖ ប្រជាជនសាមញ្ញ កងទ័ពផ្សេង១ ម៉េចមិនដឹងថាដែនទីយ៉ាងម៉េចទៅ?

អាត៖ ព្រោះគេដាក់ហ្នឹង គេមានក្រុមរបស់គេៗ ឧបមាថានៅក្នុងមួយក្រុមគ្នា១២នាក់ ត្រូវដឹងទាំងអស់គ្នា។ អញ្ចឹងគេត្រូវរៀបគូខ្សែដែនទីដាក់ចំណុះនេះ ចំណុចនេះ គេនិយាយគ្នា ស្រាចបានគេទៅដាក់ៗ អញ្ចឹងក្រុមគេហ្នឹង ឧបមាពលីកម្មម្នាក់ ក៏អ្នក១០, ១៦គេដឹង ដឹងដំណឹងគេមិនមែនដឹងដំណឹងតែម្នាក់ៗទេ។

បូលី៖ ដាទូទៅមីនគេមីនយ៉ាងម៉េចអឺ? ឧទាហរណ៍ថាផ្លូវ នេះផ្លូវដើរណាអឺណា គេដាក់នៅចំផ្លូវដើរតែម្តង ឬក៏ដាក់យ៉ាងម៉េចអឺ?

អាត៖ អានេះគេហៅហៅថាយុទ្ធវិធីសង្គ្រាម វាមានច្រើនយ៉ាងណា៎ ហៅថាបច្ចេកទេសមាន ផ្លូវដើរអញ្ចឹងមែន វាមានដក់ទឹកអញ្ចេះ ដាក់ដាក់អញ្ចឹង គេដាក់ក្នុងទឹក យើងមើលឃើញនៅក្នុងទឹក។ បើម្យ៉ាងទៀត គេមើលស្ថានភាពបើមានព្រៃ មានស្មៅមានអីជិតអញ្ចឹង គេយកទៅដាក់ជិតព្រៃហើយដាក់ខ្សែមួយ ខ្សែបង្កប់ដី ដើរឈូសដីបន្តិចផ្ទុះភ្លឹង! វាខ្ទាត់អំបែងមកត្រូវ ឆាប់ៗ

បូលី៖ មិនបាច់ទាល់តែជាន់ពីលើទេ ទាក់តែខ្សែក៏ផ្ទុះដែរ?

អាត៖ ហើយមួយទៀតគេដាក់ចោលអញ្ចឹង ដាក់ចោលលើគោក។

បូលី៖ ដាក់លើគោកតែម្តងៗ មើលឃើញ?

អាត៖ ព្រោះគេមានយុទ្ធសាស្ត្រ ដាក់លើគោកឲ្យយើងឃើញ ឲ្យខ្ញុំងឃើញណា៎ បាទ! ដាក់លើថ្នល់ចោល។

បូលី៖ ឃើញគេមិនដើរគេច?

អាត៖ ឃើញដើរគេចប៉ុន្តែអ្នកខ្លះគេ វាមានបច្ចេកទេសដោះរបស់វាទៅ តែចាប់ផ្ទុះ។

បូលី៖ ហ្ហ៎! អាហ្នឹងចាប់អត់បានទេអាហ្នឹង?

អាត៖ ចាប់អត់បានទេ! តែចាប់ផ្ទុះភ្លូង។

បូលី៖ ចុះបើយើងគប់ពីចម្ងាយ?

អាត៖ គប់ពីចម្ងាយក៏ផ្ទុះដែរ។

បូលី៖ ប៉ុនត្រូវយើងទេ?

អាត៖ បើជិតត្រូវ បើឆ្ងាយអត់ត្រូវទេ។

បូលី៖ តើចម្ងាយណាដែលកុំឲ្យត្រូវមកដល់យើង ប៉ុន្មានម៉ែត្រ?

អាត៖ វា១៥ម៉ែត្រ។

បូលី៖ ១៥ម៉ែត្រណា៎! ពីហ្នឹងទៅថ្នល់?

អាត៖ បាទ!

បូលី:　លែងដល់យើងហើយណ៎?

អាត:　លែងដល់យើងហើយទៅក្រាបបន្តិច ។

បូលី:　យើងក្រាបបន្តិចបន្តួច ។ បាំងដើមបាំងដើមអីទៅ ប៉ុណ្ណឹងអាចគប់ត្រូវ យើងអាចគប់ប្រហែលជា៤,១០,២០ដងទៅណា?

អាត:　ប៉ុន្តែបើអាពួកថ្មីៗ យួនវាអត់ដឹង វាចាប់ ផ្ទុះភ្លាំង ។ ចាប់ផ្ទុះតែម្តង ព្រោះអាហ្នឹងថាធ្វើបាតុកម្មជាមួយ(ស្តាប់ពុំបាន) គេហៅថាប្រតិកម្មរហ័ស ។

បូលី:　តែប៉ះសាច់ផ្ទុះហើយ?

អាត:　តែប៉ះផ្ទុះភឹង(ស្តាប់ពុំបាន) ដាច់ដៃដាច់ជើងអស់ហើយ(ស្តាប់ពុំបាន) ។

បូលី:　ចុះគេមានដែលកប់នៅផ្លូវដើរទេ?

អាត:　កប់ដែរ ។

បូលី:　ទោះបីជាអ្នកកប់ក្តី យើងដឹងដែនទីក្តី យើងអត់ខ្លាចច្រលំពេលណាមួយទេ?

អាត:　ឧបមាថាដីមួយគីឡូវា១០០ម៉ែត្រណា គេដាក់ហើយពីគោលនេះទៅគោលនោះដី១០០ម៉ែត្រហ្នឹង គេដាក់ក្នុងដីហ្នឹងចោល ។

បូលី:　លែងដើរហើយ?

អាត:　គេដាក់(ស្តាប់ពុំបាន) ។ ពិធីដាក់វាមានច្រើន ដូចខ្ញុំនិយាយមានអាដាក់ជិតមាត់ព្រែក អាដាក់ក្នុងទឹក បើអាមួយទៀតគេដាក់ក្នុងទឹកជ្រៅ បានគេជីករណ្តៅជ្រៅទៅ គេដាក់បង្គោលគេអញ្ចេះ(ស្តាប់ពុំបាន) ចងថ្លាស្ទីក២ទៅ៣ជាន់ កុំឲ្យចូលទឹក ហើយគេជីកជ្រៅអញ្ចឹងទៅដាក់ជ្រៅ (ស្តាប់ពុំបាន) ។

បូលី:　បរកិន បុកទៅតែម្តងអឺ?

អាត:　បរកិន បុកទៅ ។

បូលី:　សង្កត់អាឈើហ្នឹងទៅ?

អាត:　អត់ទេ! ដាក់មីនទៅក្រោម ហើយដាក់បង្គោលទៅលើ ហើយកាលណារថក្រោះជាន់បង្គោលវាសង្កត់ទៅ អាអ្នកដែលមានម៉ាស៊ីនមកភាវ ក៏ភាវមិនអស់ដែរ ។

បូលី:　ភាវអីគេអឺ?

អាត:　ប្រដាប់ភាវមីន ។

បូលី:　អ៊ូ ភាវអត់ដល់!

អាគៈ ព្រោះវាជីកជ្រៅ ហើយដាក់សុទ្ធបង្គោលឡើងទៅលើចេះ ចុះបង្គោលឈើវាមានទៅស្រុតអីវា ឈើ ។ ដល់រថក្រោះមកជាន់ពីប ចុះឈើមិនស្រុតទៅក្រោម មិនផ្ទុះ ។

បូលីៈ អាហ្នឹងរថក្រោះតែម្ដងអី?

អាគៈ មកហើយមិនដាច់ខ្ទេចមីនដល់តែ២នោះ ។ មីនគោនដាក់ដល់តែពីរជាន់នោះ ២មីន២ជាន់ ហើយបង្គោល ប្រវែង១នេះ ដាក់ប៉ុននេះរួចហើយរាវទៅ កន្ទះម៉ែត្រអី ឯងរាវដល់អី ។

បូលីៈ ចុះបើមនុស្សជាន់ ផ្ទុះទេមីនគោន?

អាគៈ មនុស្សជាន់ អត់ទេ!

បូលីៈ ទាល់តែដល់គីឡូវា?

អាគៈ ដល់គីឡូ ។

បូលីៈ ប្រហែលជាប៉ុន្មានគីឡូឡើង បានផ្ទុះអឹ?

អាគៈ មានវិធីវា បើចង់ដាក់ពីមុខ វាមានកម្រិតវា ខ្នាតវាមូលកអី បើចង់ប្រមូលដាក់មនុស្សមូលឲ្យតឹង ទុកតែ៣ខ្នាតបានហើយ (ស្ដាប់ពុំបាន) អាហ្នឹងជាន់ទៅដល់ទម្ងន់ទៅដល់គោនតែម្ដង ផ្ទុះប៊ឹង!

បូលីៈ ប៉ុនយកអាមីនគោនទៅដាក់ឲ្យផ្ទុះវា ចំណាយច្រើនពេកណ៎ អាហ្នឹងទុករថក្រោះ ទុកអី ទុកឡាន ទុកអី ។

អាគៈ អញ្ចឹងបានគេចៀសវាង កុំឲ្យក្រោះថ្នាក់ដល់មនុស្ស ដូចប្អូនឯងនិយាយអំបាញ់មិញ យកអារបស់ថ្លៃ១ទៅប្រើជាមួយមនុស្ស វាមិនសម ។ អញ្ចឹងយើងចំណាយទុកសម្រាប់រថក្រោះ ទុកឡាន ភស្តុភាធំ១ អញ្ចឹងគេចៀសវាងកុំឲ្យក្រោះថ្នាក់ដល់ទាហានផង អ្នកបច្ចេកទេសដែលដាក់មីនផងអញ្ចឹងគេមូលកំណត់ដុំប៉ុណ្ណា១ ។ ជួនកាលតែភាំងបន្តិចគេមូលហួស ផ្ទុះនៅហ្នឹងដៃក៏មាន ។

បូលីៈ មានដែលករណីហ្នឹង?

អាគៈ មាន! នៅជួរកង់ទ័ព ។

បូលីៈ ផ្ទុះមីនគោនមិនសល់សាច់ទេ?

អាគៈ គ្មានសល់សាច់ទេ! ក្រមាអីក៏គ្មានសល់ដែរ ។

បូលីៈ ឆេះខ្ទេចតែម្ដង ។

អាត: រលីងតែម្ដង គ្មានឃើញមនុស្សតែម្ដង ដើងដៃអីគ្មានសល់ទេ បាត់អស់ ខ្ទេចតែម្ដងគ្មានសល់មនុស្ស រកតែសព្វមិនឃើញ ខ្ទាតដល់ចុងឈើ ។ បើនៅក្រោមដើមឈើចេះបាក់អាមែកខ្ទេច ។

បូលី: អ៊ូ! ខ្លាំងណាណេះ ។ រំសេវធ្វើអំពីអី បានខ្លាំងម្ល៉េះ! បើយើងលើកវាប្រហែលជាប៉ុន្មានគីឡូទៅ?

អាត: ប៉ុន្មានគីឡូទេ! កាលនោះបានខ្ញុំចាំ ឥលូវភ្លេចហើយប្អូន ភ្លេចអស់ហើយ ។

បូលី: អ៊ឹនៅសំឡូតហ្នឹងប្រហែល កិច្ចព្រមព្រៀងទីក្រុងបារីស៩១ ឬក៏ដូរទៅណាទៀត?

អាត: បាទដូរចេញមក១០០១វិញ ។

បូលី: ១០០១ហេ៎?

អាត: បាទ!

បូលី: ឆ្នាំណាអ៊ឹមក១០០១?

អាត: ឆ្នាំ៨០,៨៥ ។

បូលី: ៨៥?

អាត: បាទ!

បូលី: ប៉ុនបើ៨៥, ១០០១ គេវាយដាច់ហើយហ្នឹង វៀតណាមវាយដាច់ហើយហ្នឹង ។

អាត: ក្រោមមកគេរៀបចំ ដូចនេះអញ្ចឹង ប្អូនឯងមើលដូច៧០អញ្ចឹងវាយដាច់មែន ប៉ុនក្រោយមកគេមកនៅដែលតា គេរៀបចមកម្ដាំងវាយ ពួកនោះចុះអស់វិញ ដែលហានទៅ គេវាយដាច់ផ្លូវដាច់ជញ្ជូន ហើយហានទៅនៅព្រំដែនយ៉ាងម៉េចកើត ចុះមកនៅក្រោមដូចគ អញ្ចឹងគេវាយផ្ដាច់ផ្លូវ គេនៅលើហ្នឹងវិញដដែរ មកក្នុងនេះដដែរ យើងនៅទៅគេវាយឯនេះ ។

បូលី: ១០០១ដូចគ្នាមែនទេអ៊ឹ?

អាត: ដូចគ្នា គេរៀបចំនោះវាយនោះទេ ហែងនៅហ្នឹងក៏នៅទៅ គេមកនេះក្នុងមានមនុស្សឯណាដកថយ ។

បូលី: វាយទៅពេលហើយមកវិញ យួនមិនអាចទៅហ្នឹងរហូតទេ ។ វាអត់ស្បៀង វាអត់អីហើយម្យ៉ាង!

អាត: គេវាយផ្ដាច់ផ្លូវផ្ដាច់ស្ពានឯងទៅនៅយ៉ាងម៉េចបាន(សើច) ។ គេនៅតែនៅហ្នឹងដដែល។ ដែលនៅបាន!

បូលីៈ អ៊ឹខ្លះគាត់និយាយអញ្ចេះ គាត់ថាពេលដែលបែក១០០១ហ្នឹង សុន សេនដឹកនាំកម្លាំងមក១០០៣ របស់១០០១ចោលណាអ៊ឹ ឬក៏អាចទុកតែកងទ័ពតិចតួចអីអញ្ចឹង ប៉ុន្តែប្រជាជនគ្រួសារ កងទ័ពពូមីងកូនក្មេងអីពូដឹកមក១០០៣អស់ហើយ អញ្ចឹង១០០១នៅសល់អីវិញ?

អាតៈ ១០០១វា យើងបោះបង់ចោល, ១០០១ហ្នឹងវានៅក្នុងទឹកដីថៃ ក្រោយមកយើងបោះបង់អាហ្នឹងចោល យើងមកនៅទីនេះ ។

បូលីៈ នេះ១០០៣នេះ ជាំស្រងាំ ។

អាតៈ ប្អូនឯងមើលដែនទីនេះដឹងហើយ អានេះវាចំណុចកណ្តាល ។

បូលីៈ អានេះជាមស្រងាំអ៊ឹ, អានេះឈូករុន, ជាំស្លា,ជប់ម្ហូ, អូរស្មាច់នៅនេះ ។

អាតៈ នេះចំណុចកណ្តាល គេចាត់ចែងបានទាំងអស់ មេបញ្ជាការចាត់ចែងផ្ទាល់ ។

បូលីៈ អញ្ចឹងអ៊ឹចេញពីសំឡូត មកនៅ១០០១ ។ ដល់ពេលបែក១០០១ អ៊ឹមកនៅឯណាវិញ?

អាតៈ ខ្ញុំមកនៅ១០០៣ ។

បូលីៈ នៅ១០០៣ហ្នឹងអ៊ឹ ។ នៅជាមួយតាម៉ុកអ៊ឹ?

អាតៈ អត់ទេ! នៅជាមួយតានេះមិញ!

បូលីៈ តាពក?

អាតៈ តាពក ។

បូលីៈ នៅកងពល៤១៧?

អាតៈ ជាមួយតាម៉េតហ្នឹង ជាមួយម៉េតពីមុនដំបូង ។

បូលីៈ អ្ហូ! អ៊ឹក្រុមប្រឹក្សាស្រុកដែរ?

អាតៈ បាទៗ!

បូលីៈ កងពលដូចគ្នា ។ ៤១៧ហ្នឹង នៅឈរជើងនៅម្តុំណា? កម្លាំងគ្រួសារកងទ័ព? វាមានអូរត្រាវ, ជប់ម្ហូ,ស្ទឹងចាន់, ដងទង់, វាមានអី ហើយអ៊ឹកាន់ដំណែងជាអីនៅក្នុង៤១៧ហ្នឹង?

អាតៈ ខ្ញុំអនុកងពល!

បូលីៈ ហែ៎! មិនមែនតូចណា សមាជិកកងពល បើមកឥលូវផ្កាយ២ហើយ ។ អញ្ចឹងតាពក មេកងពល?

អាតៈ តាពកមេទិស!

បូលីៈ មេទិស?

អាតៈ បាទ!

បូលីៈ បានន័យថាម៉េចមេទិសនោះ?

អាតៈ បានន័យថាឧបមាថា ឧទាហរណ៍គឺគាត់ទទួលខាងខេត្តរ ។ ទិសឧបមាថាមេទិស១ គាពេកហ្នឹង គាត់ទទួលខេត្តប៉ុន្មានអចិន្ត្រៃ ទទួលកំពង់ចាមអញ្ចឹងណា កំពង់ធំ កំពង់ចាម ក្រចេះ គាត់មេទិស ។

បូលីៈ គាត់មេទិសហើយហ្នឹងណ៎?

អាតៈ បាទ!

បូលីៈ យល់! វាមានមេទិស និងមេកងពល តែគាត់មេកងពលដែរអឹ?

អាតៈ គាត់វាថ្នាក់មជ្ឈិម ។

បូលីៈ ចូលមជ្ឈិមហើយណ៎?

អាតៈ ចូលមជ្ឈិមហើយ ដូចជាតាម៉ុក គាត់ក្តាប់ គាត់មេទិសតែម្តង ។

បូលីៈ តាម៉ុក គាត់មេទិសមួយដែរ?

អាតៈ បាទ! គាត់មេទិស គាត់អ្នកដឹកនាំរួម ។

បូលីៈ តាកែពកមេទិសខាងណាខ្លះ?

អាតៈ កែពកហ្នឹងគាត់ទិសទៅ(ស្តាប់ពុំបាន) ។

បូលីៈ វាមាន៤១៧នេះអឺនេះ? ៤៤១៧ វាចូលមកខេត្តណាខ្លះអឺ?

អាតៈ មកខាង?

បូលីៈ កំពង់ធំខ្លះទៅ?

អាតៈ កំពង់ធំ ។

បូលីៈ កំពង់ចេះធំ នេះមួយ តើខេត្តណាខ្លះទៀតអឺ?

អាតៈ វាមានកំពង់ដែរអឺ?

បូលីៈ វាមកកំពង់ចាមដែរ?

អាតៈ បាទ!

បូលីៈ កំពង់ចាមស្រុកណាខ្លះ?

អាតៈ កំពង់ចាម វាស្រុកចម្ការលើ ។

បូលីៈ នៅខាងចម្ការលើមែនទេ?

អាតៈ បាទ!

បូលី៖ ទៅពីចម្ការហើយនៅឯណាទៀតទៅ?

អាត៖ ចម្ការលើហើយ ស៊ីងត្រង់ ៗ

បូលី៖ អាហ្នឹង៨១៧ដែរ?

អាត៖ បាទ!

បូលី៖ ព្រោះ១០០១នេះក៏គេនេះដែរ ក៏គេមានកម្លាំងនេះដែរ ៨០១, ៩២០នេះគេ! ចូលមកនៅក្នុងនេះដែរ ចូលមកកំពង់ចាម ៗ

អាត៖ ចូលមកកំពង់ចាម ប៉ុនគេត្រើយខាងនោះទន្លេ ៗ

បូលី៖ ប៉ុន៨១៧ ពីមុននៅ១០០១គាអីអឹ?

អាត៖ ដូចគ្នា! តែក្រោយមកយួនវាយបែកទីហ្នឹងទៅ មកនៅឯនេះវិញ ប៉ុន្តែខ្ញុំអត់នៅទីតាំងជិតគ្នាទេ ៗ ១០០១គេនៅនេះ គាម៉ុកគាត់នៅនេះ ៗ

បូលី៖ ដល់តែពេលបែក១០០១ មកនៅ១០០៣?

អាត៖ បាទ!

បូលី៖ ៨០១ មកនៅឯហ្នឹងដែរអឹ?

អាត៖ គ្រប់កងពលទាំងអស់មូលដ្ឋានធំ មូលដ្ឋានទាំងអស់ ពង្រាយទាំងពីនោះមកណា ពង្រាយកម្លាំងមក មកនៅ១០០៣នោះ តាមមូលដ្ឋានកងទ័ព ៗ

បូលី៖ វាយដល់ប្រាសាទព្រះវិហារអត់អឹ?

អាត៖ អត់ទេ!

បូលី៖ អត់ដល់ទេណ៎! ត្រឹមឈូករុនទេអឹណ៎?

អាត៖ បាទ! ខាងនោះឈូករុន ៗ

បូលី៖ ខាងនោះឈូករុនបន្តិច? អូរ៥០ហ៎?

អាត៖ បាទ!

បូលី៖ អូរ៥០មកដល់ ខាងអន្លង់វែងណ៎?

អាត៖ បាទ!

បូលី៖ អញ្ចឹង! នៅក្នុងខេត្តឧត្តរមានជ័យណ៎? អត់ដល់ ស្រអែម, ដាំក្បាន្តអី?

អាត៖ ទេ! អត់ទេ!

បូលី៖ បែកអស់ហើយអាហ្នឹង? ដាច់អស់ហើយ?

អាត: បាទ! នៅតែម្តុំខាងលើហ្នឹង តស៊ូនៅម្តុំខាងនេះ មកខាងស្រអែម មកខាងកម្ចាំងគេរៀបចំគេធ្វើតា ។

បូលី: អាហ្នឹងកម្លាំងតូចៗទេ?

អាត: បាទ!

បូលី: ប៉ុន្តែមូលដ្ឋានធំគឺទីហ្នឹងឯង ។

អាត: នៅម្តុំនេះ! ១០០៣ (ស្តាប់ពុំបាន) ។

បូលី: ហើយបញ្ចូនពីហ្នឹង មកខាងមណ្ឌលគិរី រតនគិរីអញ្ចឹងទៅ?

អាត: បាទ! កំពង់ធំ កំពង់ចាមអីអញ្ចឹងទៅ ហើយមកទន្លេសាបនេះមក ។

បូលី: អញ្ចឹងយើងត្រូវបែងចែកជា២, ដែនទីត្រូវបែកចែកជា២បានយើងនិយាយកើត ទីគឺ៧៩-៨៥ ព្រោះពេលហ្នឹង១០០១ វានៅណាអ៊ី ហើយទី២ ពី៨៥មកឆ្នាំ៩០ ។ ពី៨៥ មក ៩០, ១០០១នេះអស់ហើយ! ១០០២អស់ហើយ! មកដុំគ្នា ១០០៣ ហើយបានពីម្តុំហ្នឹងមកបានចាប់ផ្តើមបែកគ្នា មកទូទាំងប្រទេស ។

អាត: បែកជាចង្កោមៗ ។

បូលី: បែកជាចង្កោមៗ មិនអញ្ចឹងអីអ៊ីនែក? ប៉ុន្តែពី៨៥ មក៧៩ ខាងកោះកុងគេនៅទេ មិនទាន់បែកទេមែនទេ! មិនអញ្ចឹងអីអ៊ី?

អាត: កោះកុងក្រោយគេ ។

បូលី: ខាង?

អាត: សូមកាត់ប្រសាសន៍ប្អូនឯងបន្តិច! ក្នុងចំនោម(ស្តាប់ពុំបាន) ដែលប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជាបោសសម្អាតតាមព្រំដែន គឺចាប់តាំងពី១០០១មុនៗ មក១០០១ មក ១០០៣មករហូតមក បានមកខាងសំឡូត ។ ខាងសំឡូតខាងប៉ៃលិនមក បានចុងក្រោយគេបំផុតគឺ កោះកុង ។

បូលី: ប៉ុន្តែដែលបោះបង់ទីតាំងចោលនោះគឺ មានតែ១០០១ទេ?

អាត: បាទ!

បូលី: ខាងកោះកុង គេមិនបានបោះបង់ទីតាំងចោលទេ គេនៅតស៊ូរហូតដល់៩០ ទម្រាំប៉ុល ពត គាត់មកដល់ក្បាលទន្សោង?

អាត: បាទ!

បូលីៈ អើ! ខាងម៉ាឡៃ ខាងអីក៏គេមិនបោះបង់ទីតាំងមកនៅ១០០៣ដែរ? មានតែពួកខាង១០០២ទេ ដែលមក១០០៣? តែខាងនេះអត់មានរត់មក១០០៣ទេ?

អាតៈ ខាងនេះមកជីថៃទាំងអស់ អាកន្លែងខ្ញុំនៅចាស់អីក៏នៅជីថៃដែរ ។

បូលីៈ អានេះក៏ជីថៃដែរ ប៉ុន្តែគ្រាន់តែគេនៅមានទីតាំងនៅតាមព្រំដែនរបស់គេ ។

អាតៈ ទីតាំងព្រំដែនរបស់គេ ។

បូលីៈ គេមានទីតាំងនៅប្រក៥០ នៅឈូករុន នៅងីអញ្ចឹងណាអ៊ឹ ចំនែកនៅឯ១០០១ គឺសូន្យតែម្តង ។

អាតៈ សូន្យ!

បូលីៈ នាំគ្នារត់ទៅនេះអស់ហើយ ក្រោយ៨៩ណាអ៊ឹ?

អាតៈ ដើម្បីទី១វាឆ្ងាយផ្លូវខាងជើង, ទី២អានេះវាជិត ហើយផ្ទុកម្ហូបចែកចាយគ្នា ។ អញ្ចឹងគេសុខចិត្ត គេមកនៅចំណុចកណ្តាល ។

បូលីៈ ទីតាំងធំតែម្តង ។

អាតៈ ទីតាំងធំហា ។

បូលីៈ បែងចែកទូទាំងប្រទេស ចំណុចនេះគ្រាន់តែតូចៗទេ?

អាតៈ បាទ!

បូលីៈ តាអៀង សារីទៅអញ្ចឹងទៅ, តាម៉េត, តាមុតអីគាត់នៅអញ្ចឹងទៅ ។

អាតៈ នៅអញ្ចឹងទៅ តាម៉េត, តាម៉ុតអីអញ្ចឹងទៅ ។

បូលីៈ តា នូ កន អីៗ អីទៀតដែលមេធំៗ ណោះម្តុំនេះ? អ៊ី ឈាង, សុខ ភាពអី?

អាតៈ បាទ! សុខ ភាព ។

បូលីៈ សុខ ភាព! ម៉ាឡៃអីអញ្ចឹងណាអ៊ឹ?

អាតៈ បាទ!

បូលីៈ អ៊ី ឈាន! ប៉ៃលិនណ៎អ៊ឹ?

អាតៈ បាទ!

បូលីៈ ហើយ នូ កន? គាត់ខាងណាអ៊ឹ ភ្នំព្រឹក្សអីអ៊ឹ? សំពៅលូន, កំរៀងណា?

អាតៈ បាទ!

បូលីៈ អាហ្នឹង ខាងនូ កន ខាងប្អូនតាសុន សេន?

អាតៈ បាទ!

បូលីៈ ដល់តែសុន សេន មកនៅ១០០៣ដែរ?

អាតៈ បាទ!

បូលីៈ តា ប៉ុល ពត គាត់នៅកោះកុងនេះ?

អាតៈ បាទ!

បូលីៈ ប៉ុន្តែ! មន្ទីរក-១៨ គាត់នៅក្នុងដៃថៃនេះ នៅខេត្តត្រាតនេះ មិនមែននៅក្នុងដីខ្មែរនេះទេ!

អាតៈ បាទ!

បូលីៈ អញ្ចឹង ខ្ញុំត្រូវគូរដែនទី២ ។ ទី១ ចន្លោះពី៧៩ មក៨៥ ហើយ ដែនទីទី២ ពី៨៥មក៩០ បាទ! ពីព្រោះអានេះមកនៅផ្តុំគ្នាលើកនេះមកដាក់នេះបាត់ហើយ ហើយបានចែកកម្លាំងមកតាម?

អាតៈ បាទ!

បូលីៈ អានេះបើសិនជាខ្ញុំ អាចយកអានេះធ្វើជាទីតាំង១០០៣ កាពិត១០០៣ វាវាយតាមនេះអឺមិនអញ្ចឹងណា៎! វាមិនមែនតែ១ចំណុចទេណា៎?

អាតៈ បាទ!

បូលីៈ តែ ខ្ញុំសូមដៅវាចុះ ខ្ញុំដៅពីចំណុចធំមួយ ។

អាតៈ ត្រៅជូរ, ត្រៅអីណានោះ! ដូចនិយាយអំបាញ់មិញណា ។

បូលីៈ វានៅចន្លោះអើ និយាយរួមអា នេះព្រំដែនស្រុកលង្វែកជាមួយខេត្តអើ ស្រុកអន្លង់វែងជាមួយសម្រោងណា៎អឺ ។ អានេះអ៎ ព្រំដែនត្រពាំងប្រាសាទ និងព្រះវិហារ ។ អញ្ចឹង១០០៣នៅចន្លោះនេះ ជុំវិញហ្នឹងវាមាន ដាំស្វា, វាមានអូរត្រាវ, ស៊ីងចាន់, ដងទង់, ដប់ម្ហូ, ខៃដន, ណន់សុងណាអឺ! ប្រកអូរ៩០អី គឺ វានៅម៉ុំហ្នឹងហើយ ។ អញ្ចឹងវាអាចជាទីតាំងធំមួយ ដែលបញ្ជូនកម្លាំងមកវាយនៅត្រពាំងប្រាសាទ មកវាយអន្លង់វែងណាអឺ ។ បាទ! មកខាងស្រអែមអើ! ដាំក្សាន្ត សៀមរាប ។

អាតៈ និយាយរួមគឺ ទូទាំងប្រទេសទៅ មកខាងនេះអស់តែម្តង ព្រោះវាអស់អានេះៗ អស់ហើយ!

បូលីៈ មកសៀមរាប!

អាតៈ មកនេះដែរ ទន្លេសាបនេះដែរ ។

បូលីៈ ទន្លេសាបទៀតណា៎អឺ?

អាតៈ ឆ្លងថ្នល់នេះមកទន្លេសាប ។

បូលីៈ ជុំវិញទន្លេសាបទៀត មែនទេអឺ?

អាត: បាទ! គាម៉ុកគាត់បញ្ឈូទាំងអស់ បើទន្លេសាបគាត់បញ្ឈូផ្ទាល់តែម្តង ។

បូលី: ពួកទន្លេសាបណ៎ អ៊ីណ៎ ។ ដាក់ព្រួញចេះមក វាស្រួលមើលណាអ៊ី ដូចភ្លើងហ្វាបាញ់មកអញ្ចឹង, មកកំពង់ឆ្នាំងទៀត មិនអញ្ចឹងអ៊ី? កំពង់ឆ្នាំង កំពង់ស្ពឺ កំពត តាកែវ អាកន្លែងនេះ កោះស្លា កោះស្លាមិនកម្លាំងរបស់តាប៊ិន តាឈូករុន តាអ៊ី ហើយកម្លាំងរបស់កែ ពក មិនកំពង់ស្ពឺ នៅ ភ្នំឱរ៉ាល់ ភ្នំស្រួចណាអ៊ី? កម្លាំងរបស់កែវ ពង្ស ដល់អញ្ចឹងវាមានខាងកំពង់ស្ពឺ វារត់មក កំពត ។

អាត: អានេះបានត្រូវ ។

បូលី: ពីណាទៅអ៊ី?

អាត: ពីនេះហ៎? (មើលផែនទី ពេលកំពុងនិយាយ ) ។

បូលី: បាទ! ព្រោះអានេះ១០០៣ណាអ៊ី ។

អាត: អានេះ១០០៣ ពេលបញ្ឈូមកអានេះ ។

បូលី: អានេះមកខាងជប់គគីហើយហ្នឹង អូរស្មាច់?

អាត: អ៊ីណាយើងខាងកោះកុង នេះវាបញ្ឈូមក វាត្រូវចូលមកខាង កែវ ពង្ស កែវអ៊ី ។

បូលី: កោះ កុងអ៊ីហ៎?

អាត: បាទ!

បូលី: អ៊ូ! អញ្ចឹង កោះ កុង មកខាងកែវ ពង្សវិញហ៎?

អាត: បាទ! ខាងកែវ ពង្ស កែវអ៊ី! ភ្នំអ៊ីនេះ ។

បូលី: ភ្នំវល្លិ៍ នៅកំពត?

អាត: បាទ! ព្រោះអាហ្នឹងវាមក មូលដ្ឋានអានេះ ។

បូលី: វាអត់មកនេះទេអញ្ចឹង?

អាត: អត់មានមកពីនេះអញ្ចឹង អានេះទៅពីអានេះ ។

បូលី: ពួកនេះមកតែទន្លេសាបទេអញ្ចឹង?

អាត: ទន្លេសាបទេអាអស់នេះ អត់មានឆ្លងទៅនោះទេ ។

បូលី: អត់មានឆ្លងទៅនេះទេ?

អាត: បាទ! ពីនេះទៅនោះ ។

បូលី: ពីកោះកុងទៅទៀត មកខាងកំពង់ស្ពឺហ៎អ៊ី?

អាត: កំពង់ស្ពឺ, កំពតនែក ។

បូលីៈ កំពង់ស្ពឺ កំពត់នែក?

អាតៈ បាទ! អានេះមិនដឹងទៅណាទេ ឆ្ងងបេះទៅ ។

បូលីៈ ឆ្ងងអីឆ្ងាយស្លាប់ ។

អាតៈ អានេះ វាឆ្ងងភ្នំ ។

បូលីៈ អញ្ចឹង១០០៣ អឺមកត្រឹមតែជុំវិញ បឹងទន្លេសាបទេ?

អាតៈ បាទ!

បូលីៈ អានេះលុបចោលវិញ ។ ពីខាងកោះកុងមកវិញទេ កោះកុងមិនសំឡូតទេអឹណ៎ ផ្លូវជាតិលេខ ៥?

អាតៈ បាទ!

បូលីៈ បើកោះកុង គេបញ្ជូនមកភ្នំវល្លិ៍ មកកំពង់ស្ពឺនេះ ។

អាតៈ ខាងកំពង់សោម កំពង់អីនែអឹណ៎?

បូលីៈ ល្អណាស់! អានេះបានច្បាស់អឹ ។

អាតៈ ចុះគ្នាតិចណាស់ ចុះសមុទ្រនោះណា នរណាដើរពីទីនេះទៅស្លាប់បណ្ដោយ ។

បូលីៈ ដើរមួយប្រទេសហើយ ទាល់ជិះយន្តហោះ! ចុះតាកែវមានទេអឺ មានបញ្ជូនមកទេ?

អាតៈ តាកែវយកពីនេះទៅហ្នឹង ។

បូលីៈ ពីអាហ្នឹងដែរ?

អាតៈ បាទ!

បូលីៈ តាកែវទៅធ្វើការនៅម្តុំណាតាកែវ ម្តុំណាទៅ?

អាតៈ ទេ! ខ្ញុំមិនដឹងទេ! ប៉ុនគ្រាន់តែដឹងថា ពេលគេបញ្ជូន គេបញ្ជូនអញ្ចឹង អាហ្នឹងកម្លាំងគេខាងនេះអញ្ចឹង ។ បើខ្ញុំ ខ្ញុំមិនដឹងទេ ។

បូលីៈ បើតាមខ្ញុំស្មានចេះទេអឺ ប៉ុនមិនទាន់ដឹងច្បាស់ទេអឺ ខ្ញុំគ្រាន់តែនិយាយចោលសិន អាចតាកែវ ព្រៃវែង, ស្វាយរៀង ប្រហែលជាមិនមានកម្លាំងខ្មែរក្រហមចូលមកធ្វើការដល់នេះ?

អាតៈ ស្វាយរៀង ។

បូលីៈ ព្រោះវាជាប់ជាមួយវៀតណាមហើយហ្នឹង ។

អាតៈ ស្វាយរៀងពីនេះទៅ ។

បូលីៈ ពីណាទៅវិញ?

អាតៈ ពីនេះទៅស្វាយរៀង ។

បូលី៖ កម្លាំង១០០ពាមកវិញ?

អាត៖ បាទ! ខាងកើតភ្នំ ។

បូលី៖ មានដែរអ៊ីមអញ្ចឹង?

អាត៖ មាន!

បូលី៖ ស្វាយរៀង មានទៀត?

អាត៖ មាន!

បូលី៖ បានឆ្ងាយណាស់ណ៎?

អាត៖ អ្នកស្វាយរៀង ។

បូលី៖ ប៉ុន្តែកំពង់ស្ពឺ, កំពត, និងកំពង់សោម គឺខាងកោះកុងទេ? មិនអាចពីនេះទៅទេណ៎អ៊ីណ៎?

អាត៖ តាកែវ ខាងលិច និយាយខាងលិចភ្នំពេញគឺ គួសពីខាងនេះទៅទាំងអស់ ។

បូលី៖ គួសពីនេះទៅទាំងអស់?

អាត៖ បាទ! អត់មានយកពីអានេះ នេះតែជុំវិញហ្នឹងទៅ អានេះចាប់ជុំវិញហ្នឹងជាប់ នៅជុំវិញ សំឡូត ហើយអានេះជុំវិញផ្លូវលេខ១០ ។

បូលី៖ ចុះពោធិ៍សាត់ ពីណាទៅធ្វើការ?

អាត៖ ពោធិ៍សាត់ពីអាហ្នឹងទៅ ។

បូលី៖ អានេះបានច្បាស់ ។

អាត៖ មិនមែនអានេះទៅហ្នឹងទេ ។

បូលី៖ មានអានេះអត់មានទេ?

អាត៖ បាទ! បើមានអាហ្នឹងទៅទៀតស្លាប់ហើយ ។

បូលី៖ វេទនាណាស់ ដើរកាត់ព្រៃកាត់ផ្សៃ ។

អាត៖ វាទៅតែពីនេះទេ អានេះផ្នែកនីមួយៗ អាមេធំវាបញ្ជា ។

បូលី៖ អានេះមកត្រឹមតែកំពង់ឆ្នាំង ព្រោះនៅជាប់បឹងទន្លេសាប?

អាត៖ បាទ!

បូលី៖ កំពង់ឆ្នាំង, កំពង់ចាម, កំពង់ធំ ។ ភ្នំពេញចូលមិនដល់ទេអ៊ី?

អាត៖ ខាងកើតភ្នំពេញ?

បូលី៖ ខាងកើតភ្នំពេញបានហ៎? បើភ្នំពេញមិនអាចទេ?

អាត៖ បាទ!

បូលីៈ គេការពារមាំទាំណាស់ ។ កំពង់ស្ពឺ មានត្រឹមឪរ៉ាល់នែ៎កអ៊ឹ?

អាតៈ បាទ!

បូលីៈ កំពង់ស្ពឺ បានត្រឹមឪរ៉ាល់ ។ នេះបើយើងមានដែនទី ស្រុកបានយើងស្រួលគួរ យើងទាញខ្សែមក មកតែម្តង ។

អាតៈ អាហ្នឹង! គ្រាន់តែបឋម ប្អូនឯងត្រូវយល់ឲ្យដឹងថា អានេះវាបញ្ឈរទៅខាងណាហើយអានេះបញ្ឈរទៅខាងណា មិនអាចបញ្ឈរទៅនេះបានទេ ។ ដល់ពេលអានេះបញ្ឈរបានត្រឹមនេះទេ អានេះយើងដឹងអញ្ចឹង បានស្រណុកបែងចែកដែនទី ។

បូលីៈ ចុះពួម៉ាឡៃ បញ្ឈរទៅណាវិញ?

អាតៈ ពួកម៉ាឡៃនេះគ្នាមកធ្វើការនៅបាត់ដំបង បាត់អីហ្នឹង មកស៊ីសុដនអីហ្នឹង នៅបាត់ដំបង ។

បូលីៈ នៅស៊ីសុដនស៊ីអីដែរ?

អាតៈ នៅស៊ីសុដនអី ខាងអីហ្នឹង ខេត្តបន្ទាយមានជ័យ ។

បូលីៈ បន្ទាយមានជ័យនេះ?

អាតៈ បាទ! ឯណាស៊ីសុដន ។

បូលីៈ ស៊ីសុដន នេះនៅម្តុំនេះ ។

អាតៈ អើ! អាហ្នឹងធ្វើការនៅហ្នឹង ម្តុំពួកវាហ្នឹង ។

បូលីៈ មួយជិនារផ្លូវជាតិលេខ៥ដែរ?

អាតៈ បាទ! មួយជិនារផ្លូវជាត់លេខ៥ដែរ ម៉ាឡៃ មិនមែនដូច ស៊ីសុដនណា ។

បូលីៈ សំពៅឡូនអីនែ៎អ៊ឹ?

អាតៈ បាទ!

បូលីៈ ធ្វើការខាងបាត់ដំបងដែរ?

អាតៈ បាទ!

បូលីៈ ចុះសម្រោងចុងកាល់ ។ ខាងនៅទៅអ៊ឹ? សម្រោងចុងកាល់ ឧត្តរមានជ័យ?

អាតៈ សម្រោងចុងកាល់ ឧត្តរមានជ័យ ១០០៣ដែរ ។

បូលីៈ ១០០៣ណ៎?

អាតៈ បាទ!

បូលីៈ ខាងឧត្តរមានជ័យ?

អាតៈ បាទ!

បូលីៈ ច្រើនក្រុមចុះមកធ្វើការអញ្ចឹង?

អាតៈ បាទ! ច្រើនក្រុម ។

បូលីៈ រយ?

អាតៈ បាទ! រាប់ម៉ឺនណ៎ា រយម៉ើចមនុស្ស ។

បូលីៈ ក្រុមរាប់រយ រាប់ពាន់ក្រុម?

អាតៈ បាទ!

បូលីៈ បានអឹបញ្ជាក់អញ្ចឹងដូចច្បាស់តិចអ៊ំ ។

អាតៈ អាហ្នឹង បានស្រួលមើល ស្រួលធ្វើ ស្រួលយល់ទៀត អាមេធំវាដុំគ្នានៅត្រង់ហ្នឹងទាំងអស់ហើយ ។

បូលីៈ ១០០៣?

អាតៈ បាទ! ដល់អញ្ចឹងអាធំវាបញ្ជាទៅតាមហ្នឹង ។ អានេះបញ្ជាមកមេធំ អាមេធំនេះចាត់ចែងតាមហ្នឹង អានេះបញ្ជាមកមេធំ អាមេធំនេះចាត់ចែង មកប៉ៃលិន ប៉ៃអ៊ី ។ អាហ្នឹងវាបញ្ជាមកឲ្យទៅតាមមុខសញ្ញាវាហ្នឹងតា ។

បូលីៈ តាម៉ុកវាបញ្ជាមកតាម៉េត, តាម៉ុត ហើយធ្វើការចែកតំបន់រៀងៗខ្លួនទៅ ។

អាតៈ រៀងៗខ្លួនទៅ! មិនមែនអានេះវាចុះមកដល់អាហ្នឹងទេ ។

បូលីៈ បើពួកនេះបានចុះមកបានត្រឹមទន្លេសាប ជុំវិញបឹងទន្លេសាប ។

អាតៈ អានេះមុខសញ្ញាវាបានត្រឹមនេះទេ ។

បូលីៈ ហើយបើមានផែនទីសេសសល់តាំងពីសម័យតាម៉ុក មិនដឹងថាល្អយ៉ាងណាទេអ៊ំ បានយកផែនទីនោះមកមើលណា ។ ទេ! ខ្ញុំដូចរំខានអ៊ំពេលយូរដែរហើយ ។

អាតៈ ទេ! អត់បញ្ហាអីទេ ឲ្យតែប្អូនឯងយល់ ។

បូលីៈ បាទ!

អាតៈ បើខ្ញុំឆ្លើយបាន អ៊ីដែលខ្ញុំដឹងទេណា កន្លែងដែលមិនដឹង មិនស្គាល់គឺ អត់ដឹង ។

បូលីៈ ពេលដែលឆ្នាំ៩០ អ៊ំនៅណា?

អាតៈ បាទ!

បូលីៈ ឆ្នាំ៩០?

អាតៈ ឆ្នាំ៩០ ខ្ញុំនៅ១០០៣ ។

បូលីៈ ពេលដែលតាម៉ុក រៀបចំកម្លាំងមកអន្លង់វែងត្រពាំងប្រាសាទ អ៊ំចុះមកជាមួយគេដែរ ឬទេ?

អាតៈ បាទ! ចុះមក ។

បូលីៈ ចុះតាមច្រកណា?

អាតៈ ចុះតាមជាំស្រនាំ ។

បូលីៈ ពេលហ្នឹងអឹមិនយកអាអីយកមកឈូសឆាយផ្លូវ? គេហៅស្អី?

អាតៈ អាបុល ។

បូលីៈ យកមកឈូសចុះមកតាមច្រកជាំស្រនាំ មិនអញ្ជឹងអីអឹ?

អាតៈ បាទ!

បូលីៈ អឹចុះមកនៅដំបូង មកនៅឯណា?

អាតៈ នៅផ្អាត!

បូលីៈ ឃុំផ្អាតយើង?

អាតៈ ផ្អាត!

បូលីៈ អាហ្នឹងនៅស្រុកអីផ្អាត?

អាតៈ នៅស្រុកអន្លង់វែង ។

បូលីៈ ហើយមកដល់ផ្អាតដំបូងយើងមកនៅតាមកងពល ឬក៏នៅតាមភូមិ?

អាតៈ នៅតាមកងពល ។

បូលីៈ ៨១៧នៅផ្អាត?

អាតៈ បាទ!

បូលីៈ ពេលហ្នឹងគេហៅភូមិអី?

អាតៈ ភូមិផ្អាតអញ្ចឹងតែម្តង ។

បូលីៈ មានឈ្មោះផ្អាតអញ្ចឹងតែម្តង?

អាតៈ បាទ! ពីដើមគេហៅឈ្មោះផ្អាត ។

បូលីៈ មិនមែនភូមិ៨១៧ អីអញ្ចឹងសិនទេ?

អាតៈ គេហៅភូមិផ្អាត ។

បូលីៈ ភូមិខ្លះហៅភូមិ៩៨០?

អាតៈ បាទ! ភូមិ៩៨០ គេហៅភូមិ៩៨០ ។ តែ៨១៧ គេដាក់អញ្ចឹងផ្អាត ។ ភូមិចាស់ វាមានភូមិចាស់យើងមួយនៅហ្នឹង ភូមិផ្អាត ។

បូលីៈ ហ៎ ភូមិចាស់ស្រាប់ហើយ?

អាត៖ បាទ! គេយកភូមិចាស់!

បូលី៖ តាពកគាត់នៅឯណាហ្នឹង?

អាត៖ បាទ! នៅហ្នឹង ។

បូលី៖ ៤១៧?

អាត៖ បាទ!

បូលី៖ ពេលណាអ៊ីមមកនៅត្រពាំងប្រាសាទ?

អាត៖ បន្ទាប់ពីផ្តាច់ខ្លួនហើយ ។

បូលី៖ ៩៨? ចុង៩៨? ចុង៩៨ បានមកនៅត្រពាំងប្រាសាទវិញ?

អាត៖ បាទ!

បូលី៖ ម៉េចអ៊ី មិនបន្តនៅផ្សាតទៅ?

អាត៖ នៅផ្សាតអីពេលនោះ ខ្ញុំសមាហរណកម្មកងទ័ព ថ្នាក់លើប្រាប់ឲ្យមកនៅ ។

បូលី៖ គេបែងចែកកម្លាំង?

អាត៖ បែងចែកកម្លាំង ។ ពេលនោះកងទ័ព ទាំងអស់គេប្រុបាច់ចូលគ្នា ៣០១, ៦០៧,៤១៧, ៨០២ ប្រុបាច់ចូលគ្នាតែមួយកងពល ឈ្មោះថាកងពល២៤ ។

បូលី៖ កងពល២៤ហេ៎?

អាត៖ បាទ! សមាហរណកម្មហើយណា?

បូលី៖ ពីណាមេកងពល២៤?

អាត៖ ឈ្មោះ តា លាង ។ ឥលូវគាត់រំសាយហើយ ។

បូលី៖ ចុះមិនមែន យឹម ដាន់ណា, យឹម គុមអីទេ?

អាត៖ (ស្តាប់ពុំបាន) ។

បូលី៖ កងពលលេខប៉ុន្មាន?

អាត៖ អាននោះកងពលគេ វាម្តៃប៉ុន្មានទេកាលនោះ ។

បូលី៖ ក្រែងបង្កើត២កងពលអីអ៊ឹ?

អាត៖ គេ២៣ ។

បូលី៖ គេ២៣ណ៎?

អាត៖ បាទ!

បូលី៖ អញ្ចឹងមាន២កងពល ។ កងពលអន្លង់វែង១ កងពលត្រពាំងប្រាសាទ១ ។

អាត៖ ដល់ដំណាក់កាលបន្តមកទៀតបានប្រាប់ចូលគ្នាតែមួយកងពលទេ ។

បូលី៖ កងពលលេខប៉ុន្មាន?

អាត៖ កងពលលេខ៨៣ ។

បូលី៖ លេខ៨៣ ។ មិនមែនលេខ៨៨ទេ?

អាត៖ អត់ទេ! លេខ៨៨ទៅនៅឯនោះទៀតបាន លុបពីអា៨៣ ទៅលេខ៨៨ ក្រោយពីសៀមវាយហើយ ។

បូលី៖ អូ៎! លុបកងពល៨៣ បង្កើតលេខ៨៨ ។

អាត៖ លេខ៨៨! ក្រោយពីសៀមវាយប្រាសាទព្រះវិហារ ។ អាហ្នឹង វាមានដមណាក់កាលវាអញ្ចឹង ។

បូលី៖ បាទ! អញ្ចឹងអើ ពេលដែលសមាហរណកម្មហើយ វាមាន២កងពល ។ ២៣,២៨?

អាត៖ បាទ!

បូលី៖ ២៣ អន្លង់វែង ហើយ២៨ ត្រពាំងប្រាសាទ! ២៨តាលាងអ្នកមេ ពីណាអនុ?

អាត៖ អនុ! តាសាន ។

បូលី៖ តាសាន, អីសានទៅ?

អាត៖ តាសានភ្លេចហើយ?

បូលី៖ មិនមែនយឹមសានទេ?

អាត៖ មិនមែនទេ ។

បូលី៖ យឹមសាន គាត់ចៅហ្វាយស្រុកចាស់ ។

អាត៖ គាត់ចៅហ្វាយស្រុកចាស់ ។

បូលី៖ចុះតាជុំជាតិធ្វើអី?

អាត៖ ជុំជាតិគាត់ចៅហ្វាយស្រុក កាលនោះគាត់កាន់កាប់ស្រុក ។

បូលី៖ លែងជាទាហានហើយ? ជាមេកងពលវិញ?

អាត៖ ៨០១ គាត់ប្រធានកងពល ។

បូលី៖ ពីមុនតាលាង គាត់ធ្វើអី?

អាត៖ ពីមុនគាត់នៅកងពល៨០១ ។

បូលី៖ ៨០១!

អាត៖ ដល់ក្រោយមក គាត់ប្រាប់ចូលគ្នា ៤១៧, ៨០១អីទៅ ហើយប្រាប់ចូលគ្នាទៅគាត់ទៅជាមេគេ២៨ ។

បូលី: កាលដែលគាត់នៅ៨០១ គាត់ធ្វើជាអីតាលាង?

អាត: ដឹង! មិនច្បាស់ដែរ ។

បូលី: អនុហ៎?

អាត: ប្រហែលជាអនុទេមើលទៅ?

បូលី: ប្រហែលជាអនុរបស់តាសាន ហ៎ូតាសារឿន ។ ៨០១, ៩២០ ប្រហាច់ចូលគ្នាទាំងអស់ ។

អាត: ៩២០ បែកជា២ទៀត ។ ទៅខាងអន្លង់វែងខ្លះ កម្លាំងមកនេះ មកកើតជាកងពល ។

បូលី: កម្លាំងអន្លង់វែង និងកម្លាំងត្រពាំងប្រាសាទ ស្តាប់ទៅដូចជាមិនសូវត្រូវគ្នា?

អាត: (ស្តាប់ពុំបាន) ប៉ុនគ្រាន់តែថា នៅនោះគេបញ្ចូលទៅខាងនោះទៅ តែប៉ុណ្ណឹង ។ ប៉ុនកន្លងទៅដែលកើតជាការបែកបាក់គ្នា ខាងនោះប្រកាន់ខាងនេះអញ្ចឹងទៅណា ។ ប្រកាន់រឿងដូចថា អើវាប្រកាន់មេវារៀងៗខ្លួនណា! អាមួយថាមេខាងនោះល្អ អាមួយថាមេខាងនេះត្រឹមត្រូវ ។

បូលី: មេខាងនេះពីណាគេ?

អាត: ខាងនេះ ប៉ុល ពត ។

បូលី: ប៉ុល ពត នេះ?

អាត: តាម៉ុក ខាងនោះណា ។ ប៉ុន្តែកងទ័ព មិនកងទ័ព មិនដឹងទេ បញ្ហាអញ្ចឹង ប៉ុន្តែមេដឹកនាំចេះតែប្រកាន់ អញ្ចឹងបានវាកើតបែកបាក់ ។ ខាងនេះវាចូលរដ្ឋាភិបាលទៅ ខាងនោះនៅ ។

បូលី: ហ៎ូខាងនេះចូលមុនហ៎?

អាត: បាទ! ខាងនេះចូលមុន ខាងត្រពាំងប្រាសាទ ។

បូលី: ពីណាអ្នកដឹកនាំចូល?

អាត: កាលនោះ ជា កែវ, ជា ជុំ ហើយនឹង អ៊ុំលាង ។

បូលី: អ៊ុំលាង ! មិនមែនតាលាងនៅ?

អាត: តាលាងមិញហ្នឹងឯង ។

បូលី: ហ៎ូតាលាង មេ២៨ហ្នឹងហ៎?

អាត: បាទ! គាត់អ៊ុំលាង ។

បូលី: ឥលូវខ្ញុំសុំឈ្មោះ គាត់បន្តិច អ៊ុំលាងណ៎? អ៊ុំលាងហ្នឹង គាត់មុនមកដល់ឥលូវ ពីមុនត្រូវជាអី?

អាត: យើងអនុទៅ ព្រោះមិនដឹងច្បាស់ថាកងពល៨០១ ក្រោមតាសារឿន ។

បូលី៖ ក្រោមតាសារឿន! ៨០១ បន្ទាប់ក្លាយទៅជាមេកងពល២៨នែក?

អាត៖ បាទ!២៨ ។

បូលី៖ ហើយទី១ ទី២ ជា កែវ?

អាត៖ ជា កែវគាត់!

បូលី៖ អតីតជាអី?

អាត៖ គ្រាន់តែផ្ដាច់ខ្លួនហើយ គាត់ជានែក!

បូលី៖ មុនៗ ផ្ដាច់ខ្លួន គាត់ជាអី?

អាត៖ គាត់អនុកងពល៨០១ ។

បូលី៖ អាចនៅហ្នឹងដែលណា៎អឹ?

អាត៖ បាទ! អនុទី១ណា៎ ។ ក្រោយ ជា កែវហ្នឹងមួយឲ្យឈឺន បន្ទាប់មកបាន ជាតិ ជុំ ។

បូលី៖ ជាតិ ជុំ?

អាត៖ កងពល៤១៧ ។

បូលី៖ ជាតិ ជុំ ជាមេ ឬក៏ជាអនុ?

អាត៖ ជាមេ៤១៧ ។

បូលី៖ ជាមេនៅកងពល៤១៧នែក?

អាត៖ បាទ!

បូលី៖ អញ្ចឹងពានាក់ហ្នឹង ជាមេផ្ដាច់ខ្លួន នៅត្រពាំងប្រាសាទ ឬក៏មានអ្នកផ្សេងទៀតអឹ?

អាត៖ មានច្រើនតែខ្ញុំចាំវាមិនអស់ទេ មានកងគាត់ទៅទាំងអស់ហ្នឹង ។

បូលី៖ ទៅណាអឹ?

អាត៖ ផ្ដាច់ខ្លួន ជាមួយរដ្ឋាភិបាល ។

បូលី៖ ចេញដំបូង ចេញតាមណា?

អាត៖ ព្រះវិហារហ្នឹង ។

បូលី៖ ព្រះវិហារយើង?

អាត៖ បាទ! ជាំក្សាន្ត ។ ជុំ កែវ ហ្នឹងក៏ទៅ ហើយតា(ស្ដាប់ពុំបាន) ។

បូលី៖ តាអី?

អាត៖ តា(ស្ដាប់ពុំបាន) ដើងព្រឹកមិញ ។

បូលី៖ ហ៎ូ!បាទ!

អាត: តាសយ ។

បូលី: តាសយ មិញហ្នឹង ។

អាត: គាត់ទៅជាមួយ ជាតិ ជុំ ។

បូលី: សារី សយ អីហ្នឹង មួយជួរគ្នាគាត់ហ្នឹងទៅខាងព្រះវិហារជាំក្សាន្ត ហើយបានវាយបកមក ។ ហើយបានវាយមកកងទ័ពរដ្ឋាភិបាល ។

អាត: វាយមកកងទ័ពរដ្ឋាភិបាល ហើយបានវាយហូសមក ខ្ញុំនៅនេះគាំទ្រជាកម្លាំង ។

បូលី: ចូលទាំងអស់គ្នាតែម្ដង?

អាត: បាទ! ហើយបានទៅចេះទៅ ដេញ ចេះតែដេញតាមនេះទៅ ។

បូលី: ដេញខាងណា?

អាត: ដេញខាងតាម៉ុកនៅលើភ្នំនោះ ។

បូលី: ពេលហ្នឹងហើយ ដែលតាម៉ុក រត់ឡើងទៅហូណយ ។ កម្លាំងខាងនោះ គេមានមួយខ្សែរបស់គេផ្ដាច់ដែរ?

អាត: មួយខ្សែហ្នឹង យឹម ពឹមហ្នឹងគេទៅនោះ ។

បូលី: យឹម ពឹម, យឹម ផាន់ណា អីហ្នឹងទៅខាងនោះ អូរ បៃតាប់ ហើយខាងនេះ ទៅជាំក្សាន្ត ។

អាត: ខាងនោះគេទៅអូរបៃតាប់ ហើយខាងនេះទៅជាំក្សាន្ត ។

បូលី: អញ្ចឹងនៅអាកណ្ដាល គឺថាតាម៉ុកវិលវល់ហើយ អត់ដឹងទៅខាងណាទេ បើគេឃុំព័ទ្ធសងខាងហើយ អញ្ចឹងរត់ទៅលើភ្នំ ទៅខាងអូរបៃតាប់ ។

អាត: អាហ្នឹងរឿងមិនត្រូវគ្នា រឿង យឹម ពឹម រឿង ផាន់ ណានេះ គឺមកពីរឿងតាម៉ុកដែរ ។

បូលី: រឿងយ៉ាងម៉េចអ៊ី?

អាត: រឿងតាម៉ុក មិនទុកចិត្តដូចគ្នា ដូចជាពួកខាងនេះអញ្ចឹង ។ អញ្ចឹងបានគេខ្លាចតាម៉ុកធ្វើឃាតគេ គេក៏ទៅជាមួយរដ្ឋាភិបាលទៅ ដូចគ្នាអញ្ចឹង រឿងហ្នឹងដូចគ្នា អាខាងនេះក៏អញ្ចឹងដែរ ពួកនេះតាអស់នេះកុំទៅនៅ តាម៉ុកទៅវាយចោលអស់ ខ្លាចណាស់តាម៉ុក ។

បូលី: ប៉ុន្តែអ្នកទាំងអស់នេះបានទាក់ទងទៅខាងអូរបៃតាប់ ដើម្បីសហការគ្នាវាយតាម៉ុកទេ? មានបានទាក់ទងគ្នាមុនទេ?

អាត: បាទ! ក្រោយមកបាននាំរដ្ឋាភិបាលសហការគ្នាវាយ ។

បូលី: មុនពេលផ្ដាច់ខ្លួនណា មានបានពិភាក្សាគ្នា?

អាត: ទាល់តែមានខ្លួនបង្អែករៀងខ្លួនសិន ។

បូលីៈ ហ៊ូ រកខ្នងបង្អែករៀងខ្លួន ខាងនោះគេទៅសៀមរាប ។

អាតៈ បាទ! យើងមិនអាចវាយបាន ព្រោះយើងអត់មានខ្នងបង្អែក ។

បូលីៈ ខាងនេះគេមករកខ្នងបង្អែក ខាងព្រះវិហារ ដាំក្បាន្ត នោះគេទៅខាងសៀមរាប ។

អាតៈ បាទ! នៅពេលណាមានយុទ្ធជន របួសឈឺគ្រុនអីគេមានខ្នងបង្អែក ។

បូលីៈ ខ្នងបង្អែក ម្ហូបអាហារ ។

អាតៈ ចុះបើយើងអត់មានខ្នងបង្អែក ចុះវាយគេរបួស បានថ្នាំពេទ្យថ្នាំអីឯណាលេប ។ បើរដ្ឋភិបាលវាយទៀត កុនបណ្ដោយ ។

បូលីៈ យើងត្រូវចុះចូលសិន ហើយបាននាំកម្លាំងមកនាំតាមក្រោយ ហើយកម្លាំងដែលនាំមកវាយតាម៉ុកគាត់ទៅហ្វូណយហ្នឹង កម្លាំងខាងណាខ្លះ?

អាតៈ កម្លាំងទាំងសងខាង ។

បូលីៈ ទាំងសងខាងហ៊ើ?

អាតៈ បាទ!

បូលីៈ មិនមែនតែខាងយឹម ផាន់ណា មួយទេ?

អាតៈ បាទ! ខាងនេះដែរ ។

បូលីៈ យើងដឹងហើយថារដ្ឋាភិបាលគាំទ្រណាស់ ជួយវាយ ប៉ុន្តែចង់ដឹងថាកម្លាំងណាដែលសហការជាមួយរដ្ឋាភិបាល វាយជាមួយតាម៉ុក ឡើងហ្វូណយហ្នឹង?

អាតៈ ខាងនោះក៏វាយ ខាងនេះក៏វាយ ។

បូលីៈ ខាងនេះក៏វាយដែរ?

អាតៈ បាទ!

បូលីៈ អញ្ចឹងទាំងពីរសហការគ្នាអញ្ចឹង?

អាតៈ បាទ!

បូលីៈ ហើយមានរដ្ឋាភិបាលគាំទ្រទៀត?

អាតៈ បាទ!

បូលីៈ តាម៉ុក រលំគ្រាំងបណ្ដោយ ។

អាតៈ ពេលហ្នឹងតែម្ដង ។

បូលីៈ ពេលដែលគេចាប់ខ្លួនតាម៉ុក គេចាប់ខ្លួន គេចាប់ខ្លួននៅកន្លែងណា?

អាតៈ ខ្ញុំដឹងមិនច្បាស់ដែរ! ក្រោយមកគាត់ដូចថាចាញ់នយោបាយគេយ៉ាងម៉េច ឲ្យគេចាប់ស្រួល ចុះមកចាប់ស្រុកខ្មែរ នៅព្រំដែន ចាប់នាំមក ។

បូលីៈ មិនគេចាប់នៅដីថៃទេ នៅហ្នឹងណានអីទេ?

អាតៈ ចុះមកចាប់ ។

បូលីៈ ចុះមកចាប់នៅម្តុំណា? អន្លង់វែង ឬក៏?

អាតៈ មិនដឹងណាទេលោកគ្រូ គ្រាន់តែយើងស្តាប់បាន ឮថាគេចាប់តាម៉ុក ចាប់តាម៉ុក បានហើយ ។

បូលីៈ ពីណាអ្នកទៅចាប់តាម៉ុក?

អាតៈ ចាប់តាម៉ុក កាលនោះ ខាងអន្លង់វែងហ្នឹងគេចាប់ ព្រោះគ្នាគេ ។

បូលីៈ ខាងតា ផាន់ណា?

អាតៈ ព្រោះ ខ្ញុំគេការពារខាងនេះ ខាងតាឃឹម ផាន់ណា, តាឃឹម ពឹម, ឃឹម ផាន់ណា ដូចថាមិត្តភក្តិគេប្រាប់នោះ ។

បូលីៈ ឃឹម សានមួយទៀត?

អាតៈ បាទ! ឃឹម សាន មួយទៀត! ហើយតាម៉ុក ស្អប់ ឃឹមពឹម ហ្នឹងខ្លាំងណាស់ ។

បូលីៈ មូលហេតុអី?

អាតៈ ឃឹម ពឹម ដូចថាគាត់មិនសូវពេញចិត្ត អញ្ជឹងគាត់ស្អប់ មិនសូវទទួលបញ្ជាគាត់ ។

បូលីៈ ខ្ញុំដូចជាចង់រំខានអ៊ំត្រឹមប៉ុណ្ណឹងចុះ កុំអ៊ំហត់ពេក ព្រោះវា២ម៉ោងកន្លះទៅហើយ ។

អាតៈ អត់អីទេ ដើម្បីឲ្យជ្រះស្រឡះ ។

បូលីៈ ខ្ញុំចុងក្រោយនេះ ខ្ញុំអគុណអ៊ំមែនទែន អ៊ំបានផ្តល់ព័ត៌មាននេះគឺថា ច្បាស់លាស់បានច្រើនណាស់បញ្ជាក់នូវអ្វីដែលខ្ញុំបានដឹងពីមុនមកណាអ៊ំ ខ្ញុំបានគួរដែនទី ទី១ តាមរយៈការរៀបរាប់ប្រាប់របស់អ៊ំហ្នឹង នឹងចូលរួមចំណែកធ្វើឲ្យសៀវភៅប្រវត្តិសាស្ត្រ អន្លង់វែង ត្រពាំងប្រាសាទនេះ នឹងមានភាពច្បាស់លាស់ ហើយសៀវភៅនេះហ្នឹង បម្រើមកសហគមន៍វិញទេ បានយកមកឲ្យកូនចៅជំនាន់ក្រោយ នឹងបានរៀនសូត្រ មិនមែនជាយកទៅធ្វើស្អីទៅផ្សព្វផ្សាយដើម្បីផ្នែកនយោបាយអីទេ ទាក់ទងទៅហ្នឹងរឿងអប់រំ និងការសិក្សា និងសន្តិភាពយូរអង្វែងណាអ៊ំ ។ បាទ! អញ្ជឹងការអប់រំរបស់អ៊ំ គឺមានតម្លៃមានន័យធំធេងណាស់ ។ អញ្ជឹងខ្ញុំសូមអគុណខ្ញុំ ច្រើនណាអ៊ំ ។

«ចប់»